SATHAPANA BANK

របាយការណ៍ប្រចាំឆ្នាំ ២០២៥





ខ្លឹមសារ

០៤ អំពីធនាគារ ស្ថាបនា

០៦ ចក្ខុវិស័យ និងបេសកកម្ម

០៧ គុណតម្លៃ RIGHT

០៨ ការវិវឌ្ឍនៃ ធនាគារ ស្ថាបនា

១០ ផលិតផល និង សេវាកម្ម

១៤ សារពីប្រធាន ក្រុមប្រឹក្សាភិបាល

១៦ សារពីប្រធាន នាយកប្រតិបត្តិ

១៨ រចនាសម្ព័ន្ធធនាគារ

២០ ក្រុមប្រឹក្សាភិបាល

២៤ គណៈគ្រប់គ្រងប្រតិបត្តិ

២៩ របាយការណ៍ ហិរញ្ញវត្ថុសង្ខេប

៣០ របាយការណ៍ ប្រាក់បញ្ញើអតិថិជន

៣១ របាយការណ៍ ឥណទានអាជីវកម្ម

៣២ ធនាគារ ឌីជីថល

៣៤ ប័ណ្ណ ស្ថាបនា

៣៦ ការអភិវឌ្ឍធនធានមនុស្ស

៣៨ ការគ្រប់គ្រងហានិភ័យ អភិបាលកិច្ចសាជីវកម្ម និងការប្រតិបត្តិតាម

៤២ ការគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម

៤៦ ការងារទំនួលខុសត្រូវសង្គម

៤៨ ពានរង្វាន់ និងវិញ្ញាបនបត្រ

៥០ របាយការណ៍ ហិរញ្ញវត្ថុសវនកម្ម

អំពីធនាគារ ស្ថាបនា



ទ្រព្យសកម្មសរុប
២.៧៨០ លានដុល្លារអាមេរិក

ប្រាក់ចំណេញសុទ្ធ
៦ លានដុល្លារអាមេរិក

ធនាគារ ស្ថាបនា ភីអិលស៊ី ក្លាយជាធនាគារពាណិជ្ជនៅឆ្នាំ ២០១៦ ដោយមានការរួមបញ្ចូលរវាងម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី ដែលជាធនាគារជប៉ុនមានវត្តមានមុនគេបង្អស់នៅកម្ពុជាដែលទទួលបានអាជ្ញាប័ណ្ណពេញលេញជាធនាគារពាណិជ្ជនៅក្នុងឆ្នាំ ២០០៨ និងស្ថាបនា លីមីតធីតដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើតឡើងក្នុងឆ្នាំ ១៩៩៥។

ចាប់តាំងពីការរួមបញ្ចូលគ្នា ធនាគារ ស្ថាបនា បានក្លាយជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា ដែលមានទ្រព្យសកម្មសរុបជាង ២.៧៨០ លានដុល្លារអាមេរិក និងមានបុគ្គលិក ៣.៤៦៤ នាក់។ ធនាគារ មានបណ្តាញសាខាយ៉ាងទូលំទូលាយនៅទូទាំងប្រទេសដែលមានសាខាចំនួន១៧៥ ស្ថាបនា ព្រីមារណ៍ ចំនួន៤ និងម៉ាស៊ីនអេធីអឹមជាង ២៨០កន្លែង។ បន្ថែមពីលើនេះ ធនាគារ ផ្តល់ជូននូវសេវាធនាគារយ៉ាងពេញលេញដូចជា៖ សេវាឥណទាន សេវាដាក់ប្រាក់បញ្ញើ សេវាធនាគារចល័ត សេវាធនាគារអេឡិចត្រូនិក ម៉ាស៊ីនឆូតប័ណ្ណ eCommerce និងICCP ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន សេវាផ្ទេរប្រាក់ក្នុងប្រទេស និងក្រៅប្រទេស សេវាបើកប្រាក់បៀវត្សរ៍ សេវាផ្ទេរប្រាក់ឆ្លងប្រទេសជាមួយ SWIFT Visa B2B Connect Visa Direct បាគង សេវាហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត។

ក្នុងនាមជាធនាគារឈានមុខមួយ ធនាគារ ស្ថាបនា បានទទួលវិញ្ញាបនបត្រកម្រិតមាសក្នុងការអនុវត្តយ៉ាងពេញលេញទៅតាមគោលការណ៍ការពារអតិថិជន និងទទួលវិញ្ញាបនបត្រទទួលស្គាល់ស្តង់ដារការពារទិន្នន័យ PCI-DSS និងPCI PIN ក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាពខ្ពស់។ បន្ថែមពីលើនេះធនាគារក៏ទទួលបានពានរង្វាន់ឆ្នើម “កម្មវិធីធនាគារចល័តដែលមានភាពច្នៃប្រឌិតក្នុងប្រទេសកម្ពុជា” បីឆ្នាំជាប់ៗគ្នា។



ប្រាក់បញ្ញើពីអតិថិជន
១.៩៧៤ លានដុល្លារអាមេរិក

ឥណទានផ្តល់ជូនអតិថិជន
២.០៦០ លានដុល្លារអាមេរិក

បុគ្គលិក
៣.៤៦៤ នាក់

ចំនួនអ្នកប្រើប្រាស់ឌីជីថល
៤៦៣.០០០ នាក់

ចក្ខុវិស័យ

- ជាជម្រើសធនាគារសម្រាប់អតិថិជន
- ជាជម្រើសកន្លែងការងារសម្រាប់បុគ្គលិក

បេសកកម្ម

កសាងអនាគតដ៏ល្អប្រសើរជាងមុនដោយផ្តោតលើអតិថិជនជាអាទិភាព ផ្តល់សេវាកម្មឱ្យបានល្អលើសពី ការរំពឹងទុករបស់អតិថិជន ជាមួយនឹងការផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងពង្រឹងទំនាក់ទំនងសហគមន៍ប្រកបដោយនិរន្តរភាព។

RIGHT
តុណតម្លៃ

R
ការគោរព
យើងទាំងអស់គ្នាសម្តែងការយោគយល់ ការគោរព និងតម្លាភាពទៅវិញទៅមក។

I
សុចរិតភាព
យើងទាំងអស់គ្នាប្តេជ្ញាក្នុងការប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ តម្លាភាព សីលធម៌ល្អក្នុងការបំពេញកាតព្វកិច្ចរបស់យើង។

G
ផ្តួតគំនិតរីកចម្រើន
យើងទាំងអស់គ្នាទទួលយកមតិស្ថាបនាដែលជួយយើងក្នុងការបង្កើតភាពច្នៃប្រឌិត និងរីកចម្រើនជាក្រុម។

H
គុណភាព
យើងទាំងអស់គ្នាត្រូវផ្តោតលើគុណភាពល្អឥតខ្ចោះលើរាល់ការងារដែលយើងបំពេញ ធ្វើឱ្យមានតុល្យភាពល្អរវាងប្រសិទ្ធភាពចំណាយ និងប្រសិទ្ធភាពការងារ។

T
ទំនុកចិត្ត
យើងផ្តល់ទំនុកចិត្តឱ្យគ្នាទៅវិញទៅមកតាមរយៈ ការសហការ ដើម្បីសម្រេចឱ្យបាននូវការប្តេជ្ញាចិត្ត របស់យើងចំពោះអតិថិជន។



ការរិរដ្ឋរៃធនាគារ សុាបនា

២០១៦

ធនាគារ ជប៉ុន ម៉ារ៉ូហាន់
រួមហ្ជុលគ្នាជាមួយសុាបនា
លីមីតធីត។



២០១៧

ដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាថ្មី
របស់ ធនាគារ សុាបនា។



២០១៨

សម្ពោធជាផ្លូវការនូវកម្មវិធី
ស្លាបនា ម៉ូបាល និង
ម៉ាស៊ីនដាក់ប្រាក់។



២០១៩

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប័ណ្ណ
តណពន្ធវីសា និងប័ណ្ណតណទានវីសា។



២០២០

សម្ពោធស្នាក់ការកណ្តាលថ្មី
«អគារ សុាបនា»។



២០២៥

ដាក់ដំណើរការនូវ Sathapana Anakot Lab
ការដាក់ឱ្យប្រើប្រាស់ប្រតិបត្តិការទូទាត់រាងប្រទេស
កម្ពុជា និងជប៉ុន



២០២៤

ដាក់ឱ្យដំណើរការបំណ្ណតណពន្ធ
ស្ថាបនា CSS ម៉ាស្ទ័រកាត ដំបូងគេនៅ
កម្ពុជា eCommerce និងICCP។



២០២៣

ដាក់ដំណើរការនូវ
ស្ថាបនា eBusiness



២០២២

សម្ពោធសាខាប្មី
សាខាផ្សារធំប្មី។



២០២១

ដាក់ដំណើរការជាផ្លូវការនូវ
ធនាគារ ស្ថាបនា ព្រីមាណ៍។



ផលិតផល និងសេវាកម្ម

សេវាធនាគារបុគ្គល

ប្រតិបត្តិការហិរញ្ញវត្ថុជាមួយអត្ថប្រយោជន៍កាន់តែប្រសើរ



សេវាអាជីវកម្ម

លើសពីធនាគារ គឺជាដៃគូអាជីវកម្ម



ទូទាត់បង់វិក្កយបត្រ

ចុចតែមួយប៉ក់

អាចទូទាត់វិក្កយបត្ររបស់អ្នកទាំងអស់





ប័ណ្ណ ស្ថាបនា

ទំនុកចិត្តរាល់ប្រតិបត្តិការ





សេវាផ្ទេរប្រាក់

ផ្ទេរប្រាក់ប្រកបដោយសុវត្ថិភាព។

ទទួលបានភ្លាមៗ



គម្រោងការពារអាយុជីវិត និងគម្រោងការពារទូទៅ

ការពារមនុស្សជាទីស្រលាញ់ និងពង្រឹងសុខភាពហិរញ្ញវត្ថុ

Manulife Forte



ការទូទាត់តាមបែបឌីជីថល

ប្រតិបត្តិការហិរញ្ញវត្ថុកាន់តែងាយស្រួល



អាទិភាព និងឯកសិទ្ធិ
ពោរពេញដោយប្រណិតភាព



សារពីប្រធានក្រុមប្រឹក្សាភិបាល

តាមរយៈការពង្រឹងតារាង
តុល្យការ និងការកំណត់អាទិភាព
សន្ទនីយភាព យើងបានជំរុញ
ឱ្យមានកំណើនមូលធនភាគទុនិក
យ៉ាងច្រើនដោយកើនឡើងពី
៤៣៨ លានដុល្លារអាមេរិក ទៅ
៤៤៩ លានដុល្លារអាមេរិក



បណ្ឌិត HAN CHANG-WOO
ប្រធានក្រុមប្រឹក្សាភិបាល

ទោះបីជាស្ថានភាពទីផ្សារសកលមានភាពមិនប្រាកដប្រជាយ៉ាងណាក្តី ប៉ុន្តែខឿនសេដ្ឋកិច្ចកម្ពុជានៅតែមានភាពរឹងមាំ។ ឆ្នាំនេះគឺជាឆ្នាំនៃបរិវត្តកម្ម ដោយយើងបានតម្រង់ទិសធនាគារ ស្តាបនា ឱ្យស្ថិតនៅលើដំណើរឆ្ពោះទៅរកកំណើនរយៈពេលវែង និងភាពជោគជ័យប្រកបដោយចីរភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់របស់យើង និងប្រជាជនកម្ពុជា។

ទោះបីឆ្នាំ២០២៥ គឺជាឆ្នាំដែលពោរពេញទៅដោយបញ្ហាប្រឈមយ៉ាងណាក្តី ប៉ុន្តែយើងនៅតែបន្តសម្រេចបានលទ្ធផលហិរញ្ញវត្ថុដ៏ល្អប្រសើរ តាមរយៈការពង្រឹងតារាងតុល្យការ និងរក្សាភាពរឹងមាំនៃសន្ទនីយភាព។ តាមរយៈការគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន និងការគ្រប់គ្រងមូលធនប្រកបដោយបុរេសកម្ម យើងសម្រេចបានកំណើនមូលធនភាគទុនិកដ៏ខ្ពស់ ដែលមានការកើនឡើងពី ៤៣៨ លានដុល្លារអាមេរិក ទៅ ៤៤៩ លានដុល្លារអាមេរិក។ កំណើននេះគឺជាសក្ខីភាពដ៏ច្បាស់លាស់អំពីមូលដ្ឋានហិរញ្ញវត្ថុដ៏រឹងមាំ និងប្រសិទ្ធភាពនៃយុទ្ធសាស្ត្ររយៈពេលវែងរបស់យើង។

ទោះបីទ្រព្យសកម្ម និងប្រាក់បញ្ញើរបស់យើងមានការកើនឡើងយ៉ាងណាក្តី ប៉ុន្តែគុណភាពទ្រព្យសកម្មរបស់យើងមិនទាន់បំពេញតាមគោលដៅរបស់យើងនៅឡើយទេ ដោយសារតែឥណទានមិនដំណើរការ (NPL) មានការកើនឡើង ដែលនេះជាបញ្ហាប្រឈមដ៏ខ្លាំងក្លាដែលវិស័យធនាគារទាំងមូលកំពុងជួបប្រទះ។ ការដោះស្រាយបញ្ហានេះនៅតែជាសសរស្តម្ភចម្បងនៃក្របខណ្ឌឥណទានរបស់យើង។ យើងកំពុងជំរុញការកែលម្អនៅក្នុងផ្នែកនេះប្រកបដោយភាពបុរេសកម្ម ដោយជានាថា ការកាត់បន្ថយហានិភ័យប្រកបដោយភាពច្បាស់លាស់ត្រូវបានដាក់ឱ្យអនុវត្តដោយជោគជ័យនៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់របស់យើង ។

យុទ្ធសាស្ត្ររបស់យើងនៅតែផ្តោតទៅលើប្រសិទ្ធភាពប្រតិបត្តិការ និងសនិទានកម្មចំណាយ។ តាមរយៈការពង្រឹងដំណើរការ និងការពង្រីកសមត្ថភាព យើងកំពុងធ្វើឱ្យប្រសើរឡើងនូវបទពិសោធរបស់អតិថិជន និងបង្កើនផលិតភាពជាបណ្តើរៗ។ អាទិភាពសំខាន់នៅក្នុងបរិវត្តកម្មគឺការផ្តល់នូវបច្ចេកវិទ្យាឌីជីថល front-end ដែលនឹងធ្វើឱ្យប្រសើរឡើងនូវអនុបាតចំណាយធៀបនឹងចំណូលរបស់យើង និងធានានូវកំណើនប្រកបដោយចីរភាព និងទទួលបានផលចំណេញ។

នៅក្នុងទីផ្សារដែលមានការវិវត្តយ៉ាងឆាប់រហ័សនេះ ការពង្រឹងអត្តសញ្ញាណម៉ាកសញ្ញា និងការបង្ហាញអំពីគុណតម្លៃរបស់យើងគឺជាមូលដ្ឋានដែលនាំយើងឆ្ពោះទៅរកភាពជោគជ័យ។ ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែងរបស់យើង យើងកំពុងសម្រួចការប្តេជ្ញាចិត្តរបស់យើងឆ្ពោះទៅការផ្តោតលើអតិថិជន។ យើងជានាថា រាល់ចំណុចទំនាក់ទំនងទាំងអស់ឆ្លុះបញ្ចាំងអំពីភាពជឿទុកចិត្តដែលជាកេរ្តិ៍ឈ្មោះរបស់ធនាគារ ស្តាបនា ខណៈវិនិយោគទៅលើដំណោះស្រាយឌីជីថលជាអាទិភាពដែលផ្តល់នូវបទពិសោធសេវាធនាគារងាយស្រួលប្រើប្រាស់ និងផ្តោតលើតម្រូវការបុគ្គលសម្រាប់ប្រជាជនកម្ពុជា។

ធនាគារ ស្តាបនា នៅតែប្តេជ្ញាចូលរួមចំណែកក្នុងការជំរុញការរីកចម្រើនរបស់ប្រទេសកម្ពុជាតាមរយៈគំនិតផ្តួចផ្តើមប្រកបដោយចីរភាព និងមានទំនួលខុសត្រូវសង្គម។ តាមរយៈសហការជាមួយធនាគារជាតិ នៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជា យើងគាំទ្រចំពោះបរិយាបន្ន និងអក្ខរកម្មហិរញ្ញវត្ថុ។ រាប់ចាប់ពីការផ្តល់ភាគទានថែទាំសុខភាព និងជំនួយមនុស្សធម៌ រហូតដល់ការផ្តល់កុំព្យូទ័រយួរដៃ និងការឧបត្ថម្ភដល់កាកបាទក្រហមកម្ពុជា យើងនៅតែផ្តល់អាទិភាពចំពោះការគាំទ្រដល់សហគមន៍ដោយផ្ទាល់ផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជនរបស់យើងចំពោះការជឿទុកចិត្ត បុគ្គលិករបស់យើងដែលបានប្តេជ្ញាចូលរួមក្នុងដំណើរការផ្លាស់ប្តូរប្រកបដោយយុទ្ធសាស្ត្រ ព្រមទាំងភាគហ៊ុនិករបស់យើងដែលនៅតែបន្តគាំទ្រស្ថាប័នរបស់យើង។ ជាពិសេស ខ្ញុំសូមសម្តែងការដឹងគុណចំពោះធនាគារជាតិ នៃកម្ពុជា និងនិយ័តករបស់យើងដែលតែងតែផ្តល់ការណែនាំជាមៀងរហូតមក។ ខ្ញុំជឿជាក់ថា យុទ្ធសាស្ត្រឆ្នាំ២០២៦ របស់យើងនឹងនាំមកនូវភាពជោគជ័យ និងពង្រឹងសមត្ថភាពស្ថាប័នរបស់យើងនៅក្នុងការបង្កើនគុណតម្លៃសម្រាប់ឆ្នាំខាងមុខៗជាបន្តបន្ទាប់។

បណ្ឌិត HAN CHANG-WOO
ប្រធានក្រុមប្រឹក្សាភិបាល



លោក ហែន ហ្គី. ម៉ូលដឺ
ប្រធាននាយកប្រតិបត្តិ

នៅឆ្នាំ២០២៥ បរិយាកាសប្រតិបត្តិការរបស់ប្រទេសកម្ពុជានៅតែមានជវភាពនៅឡើយ ដែលបណ្តាលមកពីការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ចសកល ការប្រែប្រួលការរំពឹងទុករបស់អតិថិជន និងស្ថានភាពវិស័យធនាគារដែលកាន់តែមានការប្រកួតប្រជែងជាងមុន។ ទោះបីជាជួបប្រទះនូវប្រឈមទាំងនេះក្តី សេដ្ឋកិច្ចកម្ពុជានៅតែមានភាពធន់ ដោយសារការងើបឡើងវិញនៃវិស័យទេសចរណ៍ ការបន្តសកម្មភាពពាណិជ្ជកម្ម និងកម្លាំងដ៏សំខាន់នៃការប្រើប្រាស់ក្នុងស្រុក។

ស្ថិតនៅក្នុងស្ថានភាពនេះ ធនាគារ ស្ថាបនា នៅតែបន្តផ្តោតទៅលើការរក្សាស្ថានភាពហិរញ្ញវត្ថុឱ្យមានភាពល្អប្រសើរ គាំទ្រដល់អតិថិជនប្រកបដោយការទទួលខុសត្រូវ និងបន្តអភិវឌ្ឍស្ថាប័នក្នុងរយៈពេលវែង។ ក្នុងរយៈពេលពេញមួយឆ្នាំនេះ យើងនៅតែផ្តោតអាទិភាពទៅលើវិន័យ ភាពធន់ ការគ្រប់គ្រងហានិភ័យដោយការប្រុងប្រយ័ត្ន និងកំណើនប្រកបដោយចីរភាព។

គិតត្រឹមដំណាច់ឆ្នាំ២០២៥ ទ្រព្យសកម្មសរុបរបស់ធនាគារ បានកើនឡើងដល់ ២.៧៨០ លានដុល្លារអាមេរិក ចំណែកឯប្រាក់បញ្ញើអតិថិជនមានចំនួន ១.៩៧៤ លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងអំពីការបន្តផ្តល់ទំនុកចិត្ត និងភាពជឿជាក់របស់អតិថិជន និងដៃគូរបស់យើង។ ផលបត្រឥណទានរបស់ធនាគារបានកើនឡើងដល់ ២.០៦០ លានដុល្លារអាមេរិក ដោយសារស្តង់ដាវាយតម្លៃដោយប្រុងប្រយ័ត្ន និងការបន្តផ្តោតទៅលើការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវនៅក្នុងចំណែកទីផ្សារលក់រាយ សហគ្រាសធុនតូច និងមធ្យម និង ពាណិជ្ជកម្ម។

ធនាគារ ក៏បានពង្រឹងបន្ថែមនូវស្ថានភាពមូលធនរបស់ខ្លួន ដោយមូលធនភាគទុនិកកើនឡើងដល់ ៤៤៩ លានដុល្លារអាមេរិក។ ជាមួយគ្នានេះ ធនាគារ នៅតែបន្តផ្តោតទៅលើការរក្សាស្តង់ដាសន្ទនីយភាព មូលធន និងការគ្រប់គ្រងហានិភ័យដោយការយកចិត្តទុកដាក់នៅក្នុងស្ថានភាពទីផ្សារដែលវិវត្តឥតឈប់ឈរនេះ។ មូលដ្ឋានហិរញ្ញវត្ថុដ៏រឹងមាំនេះបានបន្តពង្រឹងស្ថិរភាពរយៈពេលវែងរបស់ធនាគារ និងគាំទ្រការប្តេជ្ញាចិត្តរបស់យើងនៅក្នុងការពង្រឹងអភិបាលកិច្ចល្អ វិន័យប្រតិបត្តិការ និងការបង្កើតគុណតម្លៃប្រកបដោយចីរភាព។

នៅក្នុងឆ្នាំនេះ យើងបានបន្តវិនិយោគទៅលើការធ្វើឱ្យប្រសើរឡើងនូវបទពិសោធអតិថិជន និងសមត្ថភាពឌីជីថលនៅក្នុងអាជីវកម្មរបស់ធនាគារទាំងមូល។ ការធ្វើឱ្យប្រសើរឡើងនូវកម្មវិធី Sathapana Mobile និង Sathapana eBusiness ត្រូវបានអនុវត្តដោយផ្តោតទៅលើភាពងាយស្រួល សុវត្ថិភាព និងទំនុកចិត្តសម្រាប់ទាំងអតិថិជនជាបុគ្គល និងជាអាជីវកម្ម។ យើងក៏បានដាក់ឱ្យប្រើប្រាស់នូវ Sathapana Anakot ដែលជាកន្លែងសម្រាប់ធ្វើការគិតពីការច្នៃប្រឌិតដែលមានគោលដៅលើកទឹកចិត្តឱ្យមានកិច្ចសហការ គំនិតថ្មីៗ និងការគិតគូរអំពីអនាគតនៅក្នុងស្ថាប័នធនាគារទាំងមូល។

ជាមួយគ្នានេះដែរ ធនាគារ ក៏នៅតែបន្តពង្រឹងភាពធន់ប្រតិបត្តិការ ក្របខណ្ឌអភិបាលកិច្ច សមត្ថភាពគ្រប់គ្រងហានិភ័យ ការត្រៀមរួចរាល់សម្រាប់សន្តិសុខសាយប័រ (Cyber Security) មូលដ្ឋានបច្ចេកវិទ្យាដើម្បីគាំទ្រដល់កំណើនប្រកបដោយចីរភាពនៅក្នុងស្ថានភាពប្រតិបត្តិការដែលកាន់តែស្មុគស្មាញ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបញ្ជាក់អំពីការប្តេជ្ញាចិត្តរយៈពេលវែងរបស់យើងនៅក្នុងការកសាងស្ថាប័នដែលកាន់តែរឹងមាំ កាន់តែហ៊ាសរហួន និងត្រៀមខ្លួនរួចរាល់សម្រាប់អនាគត។

ខណៈពេលដែលធនាគារ ស្ថាបនា ត្រូវបានទទួលស្គាល់ និងពានរង្វាន់ពីស្ថាប័នខាងក្រៅ ដែលជាកត្តាមួយក្នុងការជំរុញកម្លាំងចិត្ត ហើយធនាគារនៅតែបន្តផ្តោតលើការពង្រឹងទំនុកចិត្តរបស់អតិថិជនរយៈពេលវែង សមត្ថភាពស្ថាប័ន និងភាពធន់នៃប្រតិបត្តិការ។ យើងនៅតែប្តេជ្ញាក្នុងការរក្សាស្តង់ដាខ្ពស់នៃការការពារអតិថិជន គុណភាពសេវាកម្ម និងការផ្តល់សេវាធនាគារប្រកបដោយការទទួលខុសត្រូវនៅទូទាំងស្ថាប័ន។

ក្រៅពីវិស័យធនាគារ យើងបានបន្តគាំទ្រគំនិតផ្តួចផ្តើមសហគមន៍ទាំងក្នុងវិស័យការអប់រំ ជំនួយមនុស្សធម៌ និងការអភិវឌ្ឍសង្គម ដែលឆ្លុះបញ្ចាំងពីជំនឿរបស់យើងថាភាពជោគជ័យរបស់ស្ថាប័នរយៈពេលវែងត្រូវតែផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការអភិវឌ្ឍសង្គមកម្ពុជាឱ្យកាន់តែទូលំទូលាយ។

តាងនាមឱ្យគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអតិថិជន បុគ្គលិក ភាគហ៊ុនិក ដៃគូអាជីវកម្ម និងធនាគារជាតិ នៃកម្ពុជា ដែលបានផ្តល់ការជឿទុកចិត្ត ភាពជាដៃគូ និងការគាំទ្រជាបន្តបន្ទាប់អស់រយៈពេលពេញមួយឆ្នាំកន្លងមកនេះ។

ឈានចូលដល់ឆ្នាំ២០២៦ នេះ ធនាគារ ស្ថាបនា នៅតែប្តេជ្ញាពង្រឹងភាពធន់របស់ស្ថាប័ន ពង្រឹងទំនុកចិត្តរបស់អតិថិជន ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច និងវិន័យប្រតិបត្តិការ ព្រមទាំងបន្តពង្រឹងដំណើរការផ្តល់សេវាកម្មឱ្យកាន់តែរឹងមាំ និងប្រកបដោយចីរភាពសម្រាប់រយៈពេលវែង។



លោក ហែន ហ្គី. ម៉ូលដឺ
ប្រធាននាយកប្រតិបត្តិ

ការកសាងគ្រឹះស្ថានដែលកាន់តែរឹងមាំ និងមានភាពធន់

ការពង្រឹងទំនុកចិត្តរបស់អតិថិជន

បន្តបង្កើនបទពិសោធអតិថិជន ភាពងាយស្រួលទទួលបាន និងភាពទុកចិត្តនៃសេវាកម្មនៅទូទាំងបណ្តាញរូបវន្ត និងឌីជីថល ដោយរក្សាបាននូវការអនុវត្តប្រកបដោយការទំនួលខុសត្រូវ និងផ្តោតលើអតិថិជន។

ការលើកកម្ពស់អភិបាលកិច្ច និងវិន័យប្រតិបត្តិការ

ការពង្រឹងក្របខណ្ឌអភិបាលកិច្ច សមត្ថភាពគ្រប់គ្រងហានិភ័យ ការត្រៀមរួចរាល់សម្រាប់សន្តិសុខសាយប័រ (Cyber Security) និងភាពធន់ផ្នែកប្រតិបត្តិការ ដើម្បីគាំទ្រដល់កំណើនរយៈពេលវែងប្រកបដោយចីរភាព និងស្ថិរភាពស្ថាប័ន។

ការពន្លឿនបរិវត្តកម្មឌីជីថល និងស្ថាប័ន

ការវិនិយោគលើសមត្ថភាពឌីជីថល ការធ្វើទំនើបកម្មប្រតិបត្តិការ និងភាពរៀសរៅរបស់ស្ថាប័ន ដើម្បីបំពេញតម្រូវការដែលកំពុងមានការវិវត្តរបស់អតិថិជន និងវិស័យហិរញ្ញវត្ថុកម្ពុជាឱ្យបានកាន់តែល្អប្រសើរ។

ការរក្សាភាពរឹងមាំ និងស្ថិរភាពហិរញ្ញវត្ថុ

ការរក្សាស្តង់ដាគ្រប់គ្រងសន្ទនីយភាព ដើមទុន និងហានិភ័យដោយប្រុងប្រយ័ត្ន ខណៈបន្តគាំទ្រអតិថិជន អាជីវកម្ម និងសហគមន៍ប្រកបដោយការទទួលខុសត្រូវនៅទូទាំងប្រទេសកម្ពុជា។

រចនាសម្ព័ន្ធធនាគារ




គណៈកម្មការគ្រប់គ្រងហានិភ័យ
គណៈកម្មការសវនកម្ម
អនុប្រធាននាយកប្រតិបត្តិ
អគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសកម្ម
នាយកដ្ឋានសុវត្ថិភាពព័ត៌មានវិទ្យា
អគ្គនាយកដ្ឋានរដ្ឋបាល
អគ្គនាយកដ្ឋានហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាននីតិកម្ម និងលេខាធិការ
អគ្គនាយកដ្ឋានប្រតិបត្តិការឥណទាន
អគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យ
អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
នាយកដ្ឋានប្រតិបត្តិតាម

ក្រុមប្រឹក្សាភិបាល

លោកបណ្ឌិត HAN CHANG-WOO ជាស្ថាបនិក និងជាប្រធានក្រុមហ៊ុន MARUHAN Corporation ក្នុងប្រទេសជប៉ុនដែលកំពុងធ្វើការផ្គត់ផ្គង់ និងរៀបចំសម្ភារកម្សាន្តជាច្រើនប្រភេទដូចជា៖ ទីលានវាយកូនហ្គោល ទីលានហាត់វាយកូនហ្គោល កន្លែងបោះបូលីង មជ្ឈមណ្ឌលហ្គេម ភោជនីយដ្ឋាន និង Pachinko Parlors។ លោកបណ្ឌិត បានបង្កើតក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ ១៩៥៧ និងបានធ្វើឱ្យអាជីវកម្មមួយនេះមានការវិវឌ្ឍយ៉ាងលឿនដែលបានទទួលចំណូលក្នុងការលក់សរុបជាង ១០ ពាន់លានដុល្លារក្នុងមួយឆ្នាំ។ ក្រុមហ៊ុន MARUHAN Corporation ត្រូវបានស្គាល់ថាជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យឧស្សាហកម្មក្នុងប្រទេសជប៉ុន។ ភាពជោគជ័យនៃការរីកចម្រើនផ្នែកអាជីវកម្មរបស់ក្រុមហ៊ុន គឺកើតចេញពីការប្តេជ្ញាចិត្តក្នុងការប្រកួតប្រជែងខ្ពស់របស់លោកបណ្ឌិត HAN CHANG-WOO និងជំនឿចិត្តដ៏រឹងមាំក្នុងការបំពេញតាមតម្រូវចិត្តរបស់អតិថិជន។

បច្ចុប្បន្ន លោកបណ្ឌិត កំពុងចូលរួមយ៉ាងសកម្មជាមួយសមាគមមួយចំនួនក្នុងនាមជាប្រធានរដ្ឋបាលនៃមូលនិធិវប្បធម៌ Han Chang Woo - Tetsu Foundation (Public Interest Incorporated Foundation) ប្រធានសមាគម Kyoto UNESCO Association ប្រធានសមាគម United Nations Association of Japan (Public Interest Incorporated Foundation) ប្រធាន Tokyo Philharmonic Orchestra (Public Interest Incorporated Foundation) ប្រធានក្រុមប្រឹក្សាភិបាល World Federation of Korean Associations of Commerce និងទីប្រឹក្សាកិត្តិយសនៃ Japan-Korea Friendship Association និងជាប្រធាន Han Chang Woo Nagako Foundation ។ ចាប់តាំងពីខែមិថុនា ឆ្នាំ ២០២៣ លោកជាអភិបាលតំណាង និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Taiheiyo Club, Inc. ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន MARUHAN Corporation ទទួលបន្ទុកលើការគ្រប់គ្រងទីលានវាយកូនហ្គោលចំនួន ១៨ នៅប្រទេសជប៉ុន និងជាទីកន្លែងសម្រាប់ប្រារព្ធការប្រកួតជើងឯកវាយកូនហ្គោលលំដាប់ពិភពលោក។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនយោបាយពីសាកលវិទ្យាល័យ Hosei នៅឆ្នាំ ១៩៥៣។

បណ្ឌិត HAN CHANG-WOO

ប្រធានក្រុមប្រឹក្សាភិបាល



លោក HAN KEN បានបម្រើការជាមួយក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ ២០០០ បន្ទាប់ពីលោកបានធ្វើការនៅក្រុមហ៊ុនមូលធនប័ត្រ Nomura តាំងពីឆ្នាំ ១៩៩៨។ នៅឆ្នាំ ២០០៧ លោកត្រូវបានតែងតាំងជាអភិបាលនៃក្រុមហ៊ុន MARUHAN Corporation ហើយនៅឆ្នាំ ២០១៤ លោកបានឡើងទៅជាអភិបាលប្រតិបត្តិ។ នៅឆ្នាំ ២០២០ លោកត្រូវបានចាត់តាំងជាតំណាងអភិបាលប្រចាំតំបន់។

នៅឆ្នាំ ២០២១ លោកត្រូវបានចាត់តាំងជាប្រធានក្រុមហ៊ុនហិរញ្ញវត្ថុនៃ MARUHAN Corporation។ លោកក៏មានតួនាទីជាអភិបាលផ្នែកគ្រប់គ្រង និងជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន MARUHAN Investment Asia Pte. Ltd ដែលមានស្នាក់ការកណ្តាលស្ថិតនៅក្នុងប្រទេសសិង្ហបុរី។ លោកគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធហិរញ្ញវត្ថុដូចជា ធនាគារ ស្ថាបនា តីអិលស៊ី នៅកម្ពុជា និងម៉ារូហាន់ ធនាគារ ជប៉ុន នៅប្រទេសឡាវក្នុងនាមជាអនុប្រធានក្រុមប្រឹក្សាភិបាល ក្នុងខែកក្កដាឆ្នាំ ២០២៣ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនាលីមីតធីត នៅប្រទេសមីយ៉ាន់ម៉ាដែលមានតួនាទីជានាយក គ្រប់គ្រង។

នៅខែមិថុនា ឆ្នាំ ២០២៣ លោកត្រូវបានតែងតាំងជាអភិបាល នៃក្រុមហ៊ុន Taiheiyo Club, Inc. ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន MARUHAN Corporation ទទួលបន្ទុកលើការគ្រប់គ្រងទីលានវាយកូនហ្គោលចំនួន ១៨ នៅប្រទេសជប៉ុន។ លោកក៏បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យ Doshisha នៅឆ្នាំ ១៩៩៧។

លោក **HAN KEN**

អនុប្រធានក្រុមប្រឹក្សាភិបាល





លោក NAOYA HIRAMATSU

អភិបាល

លោក Naoya Hiramatsu បានចាប់ផ្តើមអាជីពការងារនៅធនាគារ Mitsubishi UFJ ក្នុងទីក្រុងតូក្យូក្នុងឆ្នាំ ១៩៨៨។ ក្នុងរយៈពេល ៣៥ ឆ្នាំ លោកមានបទពិសោធការងារយ៉ាងច្រើនក្នុងនាមជានាយកប្រតិបត្តិនៅក្នុងវិស័យធនាគារ និងផ្នែកសាជីវកម្ម។ អាជីពការងាររបស់លោកនៅ MUFG រាប់បញ្ចូលទាំងបទពិសោធការងារក្រៅប្រទេសមានរយៈពេល ១៦ ឆ្នាំនៅទីក្រុងញូវយ៉ក និងប្រទេសសិង្ហបុរី ដែលលោកបានកាន់មុខតំណែងផ្នែករតនាគារ ផ្នែកផែនការសាជីវកម្ម ផ្នែកហិរញ្ញវត្ថុ ផ្នែកធនធានមនុស្ស ផ្នែកគ្រប់គ្រងព័ត៌មានវិទ្យា និងផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។ លើសពីនេះ លោកបានបង្កើតយុទ្ធសាស្ត្រ ដើម្បីឱ្យបុគ្គលិកក្នុងស្រុកចូលរួម ក្នុងដំណើរការគ្រប់គ្រង អនុវត្តកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ និងធ្វើឱ្យវត្តមានធនាគារលើឆាកអន្តរជាតិកាន់តែលេចធ្លោ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់ធនាគារ ដែលជាផ្នែកដ៏សំខាន់ក្នុងការរួមចំណែកដល់ការពង្រីកប្រតិបត្តិការ។

នៅឆ្នាំ ២០១៩ លោក Hiramatsu បានផ្លាស់ទៅបម្រើការងារនៅ Nippon Paint Group ដែលលោកបានដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់គ្រុបឱ្យទៅកាន់សកលភាវូបនីយកម្ម។ ក្នុងនាមជាអនុប្រធាន និងជានាយកប្រតិបត្តិសាជីវកម្ម នៅ Nippon Paint Automotive Coatings Co., Ltd. លោកបានដឹកនាំកំណែទម្រង់ហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធបង្កើតតំបន់អាជីវកម្មថ្មីៗ និងពង្រឹងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង។ លើសពីនេះ តាមរយៈការប្រើប្រាស់បញ្ញាសិប្បនិមិត្ត និងការផ្លាស់ប្តូរឌីជីថលក្នុងប្រតិបត្តិការអាជីវកម្ម លោក Hiramatsu បានបង្កើនផលិតភាព បង្វែរក្រុមហ៊ុនឱ្យទទួលបានប្រាក់ចំណេញ និងសម្រេចបាននូវកំណើនយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

នៅឆ្នាំ ២០២៤ លោកបានចូលរួមជាមួយក្រុមហ៊ុន MARUHAN Corporation ជាមន្ត្រីសាជីវកម្ម ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យស្ថាប័នហិរញ្ញវត្ថុសាខានៅក្រៅប្រទេស និងផ្តល់ការគាំទ្រសម្រាប់ការផ្លូចផ្តើមយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍអាជីវកម្ម និងកំណែទម្រង់ស្ថាប័ន។

នៅក្នុងឆ្នាំ ២០២៥ លោក ត្រូវបានតែងតាំង ជាមន្ត្រីសាជីវកម្មជាន់ខ្ពស់ នៅក្រុមហ៊ុន MARUHAN Corporation។



លោក HIROHISA MATSUYAMA

អភិបាល

លោក Hirohisa Matsuyama បានចាប់ផ្តើមអាជីពការងារនៅធនាគារ MUFG ក្នុងទីក្រុង Kyoto នាឆ្នាំ ១៩៨៨។ អស់រយៈពេល ៣០ ឆ្នាំនៅធនាគារ MUFG លោកមានបទពិសោធជាច្រើនដូចជា ផ្នែកលក់ សាជីវកម្មជប៉ុន ផែនការឥណទាន ផែនការសាជីវកម្ម និងការត្រួតពិនិត្យឥណទាន។ល។ ក្នុងអាជីពការងារនៅ ធនាគារ MUFG លោកបានចំណាយពេល ១៣.៥ ឆ្នាំ ក្នុងការធ្វើការនៅប្រទេសសិង្ហបុរី ដែលលោកបានកាន់តំណែងជាច្រើន រួមមាន នាយកគ្រប់គ្រងទូទៅផ្នែកឥណទានអន្តរជាតិ (សិង្ហបុរី) ដែលមើលការខុសត្រូវលើឥណទានមិនមែនជប៉ុននៅក្នុងតំបន់អាស៊ី និងអូសេអានី។

នៅឆ្នាំ ២០១៨ លោកបានផ្លាស់ប្តូរការងារទៅក្រុមហ៊ុន BOT Lease Co., Ltd. ដែលជាក្រុមហ៊ុនសម្ព័ន្ធមិត្ត MUFG ដោយលោកមានតួនាទីជានាយកប្រតិបត្តិ និងចំណាយពេលជាង ៧ឆ្នាំ គ្រប់គ្រងលើផែនការឥណទាន ផ្នែកសាជីវកម្ម ហិរញ្ញវត្ថុ និងតតិសន្យាជាមួយក្រុមហ៊ុនជប៉ុន/មិនមែនជប៉ុន ផ្នែកកប៉ាល់/យន្តហោះ និងផ្នែកអចលនទ្រព្យ ជាដើម។

នៅឆ្នាំ ២០២៥ លោកបានចូលរួមជាមួយ MARUHAN Corporation មានតួនាទីជាមន្ត្រីសាជីវកម្មដែលទទួលខុសត្រូវលើ ការត្រួតពិនិត្យផែនការឥណទាន និងការគ្រប់គ្រងហានិភ័យនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្រៅប្រទេសជាមួយនឹង ជំនាញរបស់លោក។

លោកបានទទួលបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Hitotsubashi ក្នុងឆ្នាំ ១៩៨៨។



ឯកឧត្តម SHINOHARA KATSUHIRO

អភិបាលឯករាជ្យ

ឯកឧត្តម SHINOHARA KATSUHIRO ធ្លាប់មានប្រវត្តិរស់នៅប្រទេសកម្ពុជាជាង ៥០ ឆ្នាំកន្លងមកហើយ។ នៅឆ្នាំ១៩៦៧ គាត់បានមកដល់ប្រទេសកម្ពុជាលើកដំបូងក្នុងនាមជាមន្ត្រីការទូតរបស់ជប៉ុន និងបានចំណាយពេល២ឆ្នាំដំបូងរស់នៅក្នុងវត្តឧណ្ណាលោមក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះលោកបានចំណាយពេល៧ខែបួសជាព្រះសង្ឃ ដើម្បីសិក្សាភាសា និងវប្បធម៌ខ្មែរមុនពេលចូលកាន់មុខតំណែងជាមន្ត្រីលេខានៅស្ថានទូតជប៉ុនក្នុងប្រទេសកម្ពុជា។

បន្ទាប់ពីឯកឧត្តមបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាក្នុងនាមជាអគ្គទីប្រឹក្សាស្ថានទូតជប៉ុន (ពីឆ្នាំ ១៩៩១ ដល់ ១៩៩៤ និងពីឆ្នាំ២០០១ ដល់ ២០០៤) ឯកឧត្តមបានបង្កើតចំណងមិត្តភាពជាមួយប្រទេសកម្ពុជាយ៉ាងរឹងមាំក្នុងតួនាទីជាឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០០៧ រហូតដល់ឆ្នាំ ២០០៩។

ចាប់ពីខែធ្នូឆ្នាំ២០១២មក ឯកឧត្តម គឺជាអភិបាលឯករាជ្យរបស់ ធនាគារ ស្ថាបនា ហើយលោកក៏ជាសមាជិកគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល។ បច្ចុប្បន្ន លោកជាប្រធានតំណាងនៃអង្គការ NGO មូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា(CIESF) នៃប្រទេសជប៉ុនដែលមានទីតាំងនៅរាជធានីភ្នំពេញ។

ឯកឧត្តម គិម វ៉ាដា មានបទពិសោធការងារយ:ពេលជាង ៣៧ ឆ្នាំ នៅធនាគារជាតិ នៃកម្ពុជា ដោយចាប់ផ្តើមពីតំណែងជាប្រធានការិយាល័យ នៅសាខាខេត្តកណ្តាលរបស់ធនាគារជាតិ នៃកម្ពុជា រហូតក្លាយជាអគ្គនាយក នៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិ នៃកម្ពុជា។ ក្នុងអំឡុងពេលបំពេញការងារនៅធនាគារជាតិ ឯកឧត្តមបានទទួលបន្ទុក និងមានតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនជាមួយនឹងបទពិសោធទូលំទូលាយក្នុងវិស័យធនាគារ ដោយរួមបញ្ចូលទាំងផ្នែកគ្រប់គ្រងហានិភ័យ (ហានិភ័យទីផ្សារ ហានិភ័យឥណទាន ហានិភ័យសន្ធនីយភាព និងហានិភ័យប្រតិបត្តិការជាដើម) អតិបាលកិច្ច និងយុទ្ធសាស្ត្រអាជីវកម្ម។ ឯកឧត្តមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំប្រព័ន្ធធនាគារនៅកម្ពុជាឡើងវិញយ៉ាងជោគជ័យក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០ ក្នុងការបង្កើតឱ្យមានប្រព័ន្ធធនាគារមួយដែលមានលក្ខណៈប្រកួតប្រជែង និងប្រកបដោយសុវត្ថិភាពក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងបានយ៉ាងល្អ ព្រមទាំងបានបង្កើតឱ្យមានការកេណ្ឌប្រមូលប្រាក់បញ្ញើយ៉ាងមានប្រសិទ្ធភាពសម្រាប់ផ្តល់ហិរញ្ញប្បទាន ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។



ឯកឧត្តម គិម វ៉ាដា
អភិបាលឯករាជ្យ

ឯកឧត្តម គិម វ៉ាដា ទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ក្នុងឆ្នាំ ១៩៧៥ បរិញ្ញាបត្រផ្នែកធនាគារ ក្នុងឆ្នាំ ១៩៨៥ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងពុរកិច្ច ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី នៅឆ្នាំ ២០០៣។ ឯកឧត្តមធ្លាប់ធ្វើជាសាស្ត្រាចារ្យ និងជាវាគ្មិននៅសាកលវិទ្យាល័យល្បីៗមួយចំនួននៅក្នុងប្រទេសកម្ពុជា។

លើសពីនេះ ក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយនេះ លោកបានចូលរួមយ៉ាងសកម្មក្នុងនាមជាវាគ្មិនក្នុងសន្និសីទសិក្ខាសាលាជាតិ និងអន្តរជាតិជាច្រើនដែលទាក់ទងនឹងក្របខណ្ឌបទប្បញ្ញត្តិប្បាប់ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសេវាកម្មធនាគារចល័ត និងបរិយាបន្នហិរញ្ញវត្ថុ។ ចំពោះការងារអន្តរជាតិ លោកបានទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមឥណទានកសិកម្ម និងជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ពីខែកក្កដា ឆ្នាំ ២០១២ ដល់ខែមិថុនា ឆ្នាំ ២០១៤ និងជាសមាជិកប្រតិបត្តិ នៃសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) ពីខែមករា ឆ្នាំ ២០១៥ ដល់ខែមិថុនា ឆ្នាំ ២០១៧ ផងដែរ។

ជាមួយនឹងប្រវត្តិការងារថ្នាក់អន្តរជាតិ និងបទពិសោធជានាយកប្រតិបត្តិជាន់ខ្ពស់ផ្នែកធនធានមនុស្សយ៉ាងទូលំទូលាយ លោក Willams បានចាប់ផ្តើមអាជីពការងារនៅក្នុងឧស្សាហកម្មសេវាហិរញ្ញវត្ថុ ក្នុងឆ្នាំ ១៩៨៦។ ក្នុងអាជីពការងារមួយដែលមានរយៈពេល ៣៦ឆ្នាំ លោក Williams មានតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ផ្នែកធនធានមនុស្សទាំងក្នុងស្រុក និងក្រៅស្រុក។ លោក Williams មានបទពិសោធយ៉ាងច្រើនក្នុងការបំពេញការងារជាមួយនាយកប្រតិបត្តិជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលដែលប្រកបដោយវិជ្ជាជីវៈ។

ក្រៅពីនៅទីក្រុងឡុងដ៍ លោក Williams បានចំណាយពេលលើអាជីពការងាររបស់លោកនៅទីក្រុងជាច្រើនដូចជា អាំស្តែដាំ តូក្យូ ហុងកុង និងសិង្ហបុរី។ លោកក៏បានបម្រើការនៅក្នុងក្រុមហ៊ុនពហុជាតិធំតូចជាច្រើន ហើយលោកបានរៀនសូត្រ និងសម្របខ្លួនតាមបរិបទការងារនីមួយៗបានយ៉ាងល្អ។



លោក JOHN GERARD WILLIAMS
អភិបាលឯករាជ្យ

លោក Williams មានសមត្ថភាពខ្ពស់ក្នុងការកសាង អភិវឌ្ឍ និងដឹកនាំក្រុមការងារធនធានមនុស្សក្នុងការជ្រើសរើសថ្នាក់ដឹកនាំជាន់ខ្ពស់ និងប្រាកដថាពួកគេអាចសម្របខ្លួន និងបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។ លោកយល់ច្បាស់អំពីភាពខុសគ្នានៃវប្បធម៌ និងភាពចម្រុះនៃជាតិសាសន៍។ លោកធ្លាប់បានដឹកនាំគម្រោងអន្តរជាតិសំខាន់ៗក្នុងផ្នែកជាច្រើនដូចជា សំណង និងអត្ថប្រយោជន៍បុគ្គលិក ការជ្រើសរើសបុគ្គលិក ការផ្លាស់ប្តូរបទនាសម្ព័ន្ធក្រុមហ៊ុន ការគ្រប់គ្រងបុគ្គលិក និងបុគ្គលិកជំនាញៗមកពីបរទេស។ ក្នុងបទពិសោធការងារ លោកបានធ្វើការជាមួយក្រុមហ៊ុន Swiss Re ធនាគារ Kleinwort Benson ធនាគារ ING ក្រុមហ៊ុន Daiwa Capital Markets និង ធនាគារ MUFG ។

នៅចុងឆ្នាំ ២០២២ លោក Williams បានសម្រេចចិត្តលាឈប់ពីការងារសាជីវកម្មរបស់លោក ហើយនៅក្នុងឆ្នាំ ២០២៣ លោកបានបង្កើតអាជីវកម្មផ្ទាល់ខ្លួនដោយផ្តោតសំខាន់ទៅលើ ការបង្ហាត់បង្រៀន ការសម្របសម្រួល និងការងារប្រឹក្សាផ្នែកធនធានមនុស្ស។

លោកគឺជាគ្រូបង្វឹកជំនាញដ៏មានគុណសម្បត្តិមួយរូប នៅសហព័ន្ធគ្រូបង្វឹកអន្តរជាតិ និងមានការផ្តល់កិត្តិយសជាអ្នកសម្របសម្រួលដោយមជ្ឈមណ្ឌលដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព (CEDR)។ ក្នុងឆ្នាំ ២០២៤ លោក Williams បានចូលរួមជាមួយធនាគារ ស្តាបនា គីអិលស៊ី ក្នុងនាមជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មការតែងតាំង និងផ្តល់តម្លៃការ។

គណៈគ្រប់គ្រងប្រតិបត្តិ



លោក ហែន ហ្គ្រី. ម៉ូលដឺ
ប្រធាននាយកប្រតិបត្តិ

លោក ហែន ហ្គ្រី. ម៉ូលដឺ គឺជាប្រធាននាយកប្រតិបត្តិ នៃ ធនាគារ ស្ថាបនា តឺអិលស៊ី។ លោក ហែន គឺជាថ្នាក់ដឹកនាំដែលទទួលបានសមិទ្ធផលជាច្រើនជាមួយនឹងបទពិសោធការងារអស់រយៈពេលជាង ៤០ ឆ្នាំក្នុងសេវាហិរញ្ញវត្ថុបុគ្គល និងធនាគារវិនិយោគ ហើយលោក ហែន មានជំនាញ និងបទពិសោធយ៉ាងទូលំទូលាយលើការគ្រប់គ្រងយុទ្ធសាស្ត្រ និងការផ្លាស់ប្តូរ ហានិភ័យឥណទាន និងរតនាគារ។ លោក ហែន មានកំណត់ត្រា ដែលបានបង្ហាញឱ្យឃើញពីជោគជ័យនៃការផ្លាស់ប្តូរ និងការពង្រីកអាជីវកម្មក្នុងរយៈពេលដ៏ខ្លី ពោលគឺការដឹកនាំអាជីវកម្មដែលមានទ្រព្យសកម្មរាប់ពាន់លានដុល្លារអាមេរិកនៅក្នុងទីផ្សារផ្សេងៗគ្នាជាច្រើនរួមមានក្នុងប្រទេសហូឡង់ ឥណ្ឌា ប្រេស៊ីល ឥណ្ឌូនេស៊ី កូឡុំប៊ី រូម៉ានី អារ៉ាប៊ីសាអូឌីត សាធារណរដ្ឋហ្សាប៊ី និងកម្ពុជា។



លោក ម៉ូរីម៉ូតូ យ៉ូស៊ីហារុ
អនុប្រធាននាយកប្រតិបត្តិ

លោក ម៉ូរីម៉ូតូ យ៉ូស៊ីហារុ មានតួនាទីជាអនុប្រធាននាយកប្រតិបត្តិនៃធនាគារ ស្ថាបនា ដែលមានបទពិសោធជាង ៣០ ឆ្នាំក្នុងវិស័យធនាគារពាណិជ្ជទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក។ នៅធនាគារ ស្ថាបនា លោកដឹកនាំ និងមើលការខុសត្រូវលើផ្នែកហិរញ្ញវត្ថុ និងគ្រប់គ្រងផ្នែកក្នុង។



លោក សៀង សេរី
នាយកប្រតិបត្តិគ្រប់គ្រង ទ្រព្យសកម្ម

លោក សៀង សេរី ធ្លាប់ជានាយកប្រតិបត្តិ រដ្ឋបាល ហើយលោកក៏ត្រូវបានបន្ថែមតួនាទីជានាយកប្រតិបត្តិ គ្រប់គ្រងទ្រព្យសម្បត្តិ ដែលមានបទពិសោធជាង ២៥ ឆ្នាំជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងក្រុមហ៊ុន FMCG អន្តរជាតិ។ នៅធនាគារ ស្ថាបនា លោកដឹកនាំ នាយកដ្ឋានគ្រប់គ្រង និងប្រមូលឥណទាន ឱ្យស្របតាមយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារ។



លោក ហុង ឡុងឌី
នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង

លោក ហុង ឡុងឌី មានតួនាទីជានាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង ដែលមានបទពិសោធធ្វើការជាច្រើនឆ្នាំ នៅក្នុងវិស័យធនាគារ និងនៅក្រុមហ៊ុនគណនេយ្យជំមួយនៅប្រទេសកម្ពុជា។ នៅធនាគារ ស្ថាបនា លោករាយការណ៍ដោយផ្ទាល់ទៅគណៈកម្មការសវនកម្មនៃក្រុមប្រឹក្សាភិបាល លោកទទួលខុសត្រូវគ្រប់គ្រងការងារសវនកម្មផ្ទៃក្នុង ដែលត្រូវត្រួតពិនិត្យលើការអនុវត្តប្រព័ន្ធត្រួតពិនិត្យ លើប្រតិបត្តិការរបស់ធនាគារទាំងមូល។



លោក ណាក់ ពេជ្រកោសា
នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន

លោក ណាក់ ពេជ្រកោសា មានតួនាទីជានាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មានដែលមានបទពិសោធបច្ចេកវិទ្យាជាង ២០ ឆ្នាំជាមួយក្រុមហ៊ុនអន្តរជាតិ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ នៅធនាគារ ស្ថាបនា លោកដឹកនាំនវានុវត្តបច្ចេកវិទ្យានិងការកម្លាយខ្លួនទៅជាធនាគារឌីជីថលដែលស្របទៅតាមយុទ្ធសាស្ត្រឌីជីថលរបស់ធនាគារ។



លោកស្រី ឈឹម សំអុល
នាយិកាប្រតិបត្តិ នីតិកម្ម និងលេខាធិការ

លោកស្រី ឈឹម សំអុល មានតួនាទីជា នាយិកាប្រតិបត្តិ នីតិកម្ម និងលេខាធិការ។ លោកស្រីមានបទពិសោធជាង ១៥ឆ្នាំក្នុងការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ប្រកបដោយគុណភាព ក៏ដូចជាការទទួលបានទំនុកចិត្តខ្ពស់ពីសំណាក់អតិថិជនទាំងក្នុងស្រុក និងក្រៅស្រុក។ នាពេលបច្ចុប្បន្ន លោកស្រីទទួលបន្ទុកគ្រប់គ្រង់លើនាយកដ្ឋាននីតិកម្ម និងលេខាធិការដ្ឋាន រួមបញ្ចូលទាំងការត្រួតពិនិត្យលើការអនុលោមទៅតាមបទបញ្ញត្តិ ព្រមទាំងទំនាក់ទំនងជាមួយភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាល។



លោក ឆេង យ៉ានិត
នាយកប្រតិបត្តិលក់ និងចែកចាយ

លោក ឆេង យ៉ានិត មានតួនាទីជានាយកប្រតិបត្តិលក់ និងចែកចាយនៃធនាគារ ស្តាបនា។ លោកមានបទពិសោធជាង ២០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ទាក់ទងទៅនឹងធនាគារបុគ្គល ការផ្លាស់ប្តូរប្រព័ន្ធឌីជីថល ការគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្រអាជីវកម្មសម្រាប់ទីផ្សារក្នុងប្រទេស និងក្រៅប្រទេស ជាមួយនឹងកំណត់ត្រាការងារឆ្នើមក្នុងការអនុវត្តលើការដឹកនាំចាប់ផ្តើមអាជីវកម្ម និងគ្រប់គ្រងវិបត្តិ។



លោក ថាវ ផាតសុភារីន
នាយកប្រតិបត្តិ សេវាកម្មធនាគារពាណិជ្ជកម្ម

លោក ថាវ ផាតសុភារីន មានតួនាទីជានាយកប្រតិបត្តិសេវាកម្មធនាគារពាណិជ្ជកម្មនៃធនាគារ ស្តាបនា។ លោកមានបទពិសោធជាង ១៥ ឆ្នាំក្នុងវិស័យធនាគារ ជាមួយបទពិសោធដ៏ទូលំទូលាយលើសេវាកម្មធនាគារសម្រាប់អាជីវកម្ម សហគ្រាស ស្ថាប័នហិរញ្ញវត្ថុ និងពាណិជ្ជកម្មអន្តរជាតិ។ បច្ចុប្បន្ននេះ លោកដឹកនាំឥណទានអាជីវកម្ម និងផ្នែកលក់ប្រតិបត្តិការធនាគារ ដើម្បីផ្តល់នូវដំណោះស្រាយសេវាកម្មល្អបំផុតទៅកាន់អតិថិជន។



លោក លី សាលីន
នាយកប្រតិបត្តិធនធានមនុស្ស

លោក លី សាលីន មានតួនាទីជានាយកប្រតិបត្តិធនធានមនុស្សនៃធនាគារ ស្ថាបនា។ លោកមានបទពិសោធជាង ១៥ ឆ្នាំ ក្នុងវិស័យធានារ៉ាប់រង និងធនាគារ។ នៅធនាគារ ស្ថាបនា លោកដឹកនាំយុទ្ធសាស្ត្រធនធានមនុស្ស យុទ្ធសាស្ត្របណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្ស ព្រមទាំងធ្វើការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ដែលស្របតាមយុទ្ធសាស្ត្រធនធានមនុស្ស និងយុទ្ធសាស្ត្រអាជីវកម្មនៃធនាគារ។



លោក ស៊ុយ សុខលាង
នាយកប្រតិបត្តិ ប្រតិបត្តិការ

លោក ស៊ុយ សុខលាង មានតួនាទីជា នាយកប្រតិបត្តិ ប្រតិបត្តិការ នៃធនាគារ ស្ថាបនា។ លោកមានបទពិសោធការងារក្នុងវិស័យធនាគារពាណិជ្ជជាង ២០ឆ្នាំ។ ក្នុងនាមលោកជានាយកប្រតិបត្តិ ប្រតិបត្តិការ លោក សុខលាង គ្រប់គ្រងដឹកនាំការងារប្រតិបត្តិការធនាគារទាំងមូលរួមមាន ប្រតិបត្តិការតាមរយៈសាខា ម៉ាស៊ីនអេធីអឹម ប័ណ្ណឥណទាត់ប្រព័ន្ធឌីជីថល និងសេវាកម្មអតិថិជន ដើម្បីធានាបាននូវគុណភាពសេវាកម្មល្អប្រសើរ និងជំរុញអោយមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។



លោក មិន សុភ័ក្ត្រ
នាយកប្រតិបត្តិ ហិរញ្ញវត្ថុ

លោក មិន សុភ័ក្ត្រ មានតួនាទីជា នាយកប្រតិបត្តិ ហិរញ្ញវត្ថុ នៅធនាគារ ស្ថាបនា។ លោកមានបទពិសោធជាង ១៨ឆ្នាំ នៅក្នុងវិស័យធនាគារទាំងនៅធនាគារពាណិជ្ជនៅប្រទេសកម្ពុជា និងឡាវ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីដឹកនាំ និងជំរុញយុទ្ធសាស្ត្រហិរញ្ញវត្ថុ បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងគាំទ្រគំនិតផ្តួចផ្តើមនៃការវិវឌ្ឍឌីជីថល។



លោកស្រី លឹម ពៅវណ្ណារី
នាយិកាប្រតិបត្តិ ទីផ្សារ

លោកស្រី លឹម ពៅវណ្ណារី មានតួនាទីជានាយិកាប្រតិបត្តិ ទីផ្សារ នៃធនាគារ ស្ថាបនា ដែលមានបទពិសោធជាង ១៧ឆ្នាំ ជាមួយនឹងជំនាញយ៉ាងច្បាស់លាស់លើយុទ្ធសាស្ត្រទីផ្សារក្នុងវិស័យធនាគារ និងវិស័យ FMCG។ លោកស្រីមានតួនាទីដឹកនាំទស្សនវិស័យទីផ្សារ យុទ្ធសាស្ត្រម៉ាកយីហោ និងការទំនាក់ទំនងអតិថិជន ដើម្បីជំរុញឱ្យមានកំណើនប្រកបដោយនិរន្តរភាព និងភាពជាអ្នកដឹកនាំនៅលើទីផ្សារ។



លោក រ៉ូស៊ី អាប្រាមេន
នាយកប្រតិបត្តិ ហានិភ័យ

លោក រ៉ូស៊ី អាប្រាមេន មានតួនាទីជានាយកប្រតិបត្តិ ហានិភ័យ នៃធនាគារ ស្ថាបនា។ លោកមានបទពិសោធជាង ១៤ ឆ្នាំក្នុងវិស័យធនាគារនៅប្រទេសម៉ាឡេស៊ី និងកម្ពុជា។ នៅធនាគារ ស្ថាបនា លោកមានតួនាទីដឹកនាំនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដោយក្នុងនោះលោកជំរុញ និងលើកកម្ពស់ការយល់ដឹងអំពីវប្បធម៌ហានិភ័យ និងការវាយតម្លៃហានិភ័យប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម និងភាពធន់នៃប្រតិបត្តិការ ដើម្បីធានាបាននូវកំណើនប្រកបដោយនិរន្តរភាព។



លោក ថេង វីរៈយុទ្ធ
នាយកប្រតិបត្តិផលិតផល និងយុទ្ធសាស្ត្រ

លោក ថេង វីរៈយុទ្ធ មានតួនាទីជានាយកប្រតិបត្តិផលិតផល និងយុទ្ធសាស្ត្រ នៃធនាគារ ស្ថាបនា។ លោកមានពិសោធជាងមួយទសវត្សរ៍ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅទូទាំងតំបន់អាស៊ាន។ នៅធនាគារ ស្ថាបនា លោកមានតួនាទីដឹកនាំយុទ្ធសាស្ត្រផលិតផល ការផ្លាស់ប្តូរ និងការអភិវឌ្ឍអាជីវកម្ម ដើម្បីជំរុញកំណើនប្រកបដោយចីរភាពសម្រាប់ធនាគារ។

របាយការណ៍
ហិរញ្ញវត្ថុសង្ខេប

ទ្រព្យសកម្មសរុប
គិតជាលានដុល្លារអាមេរិក

២០២៥	២.៧៨០
២០២៤	២.៧៧១
២០២៣	២.៨៤៥
២០២២	២.៧៦១
២០២១	២.៤៤១

មូលធនរបស់ភាគទុនិកសរុប
គិតជាលានដុល្លារអាមេរិក

២០២៥	៤៤៩
២០២៤	៤៣៨
២០២៣	៤១១
២០២២	៣៨៦
២០២១	៣៥៤

ឥណទានសរុប (ដុល)
គិតជាលានដុល្លារអាមេរិក

២០២៥	២.០៦០
២០២៤	២.០២៧
២០២៣	២.១៩៦
២០២២	២.១១១
២០២១	១.៩២៥

ប្រាក់បញ្ញើពីអតិថិជន
គិតជាលានដុល្លារអាមេរិក

២០២៥	១.៩៧៤
២០២៤	១.៩១៦
២០២៣	១.៨៧០
២០២២	១.៧៥៤
២០២១	១.៤៧៨

ប្រាក់ចំណេញសុទ្ធ (ក្រោយបង់ពន្ធ)
គិតជាលានដុល្លារអាមេរិក

២០២៥	៦.២២
២០២៤	១៦.៥១
២០២៣	១៤.៧៤
២០២២	២២.៤៨
២០២១	៥៤.៥៥

អតិថិជនសរុប (ប្រាក់បញ្ញើ និងប្រាក់កម្ចី)
គិតជាពាន់នាក់

២០២៥	៥៨០
២០២៤	៥១៥
២០២៣	៦០៦
២០២២	៥៨០
២០២១	៤៧២

របាយការណ៍
ប្រាក់បញ្ញើអតិថិជន

ក្នុងឆ្នាំ ២០២៥ ធនាគារ ស្ថាបនា នៅតែពង្រឹងជំហររបស់ខ្លួនជាស្ថាប័នហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តដោយប្រាក់បញ្ញើសរុបកើនឡើងដល់ ១.៩៧៤ លានដុល្លារអាមេរិក ពោលគឺកើនឡើង ៥៨ លានដុល្លារអាមេរិក (៣%) ។ ការកើនឡើងនេះបានបង្ហាញយ៉ាងច្បាស់ពីការជឿទុកចិត្តរបស់អតិថិជន និងសាធារណជន និងការផ្តោតសំខាន់ទៅលើដំណោះស្រាយឌីជីថលរបស់ធនាគារ ស្ថាបនា។



កំណើននេះត្រូវបានកើនឡើងដោយមានការចូលរួមពីកត្តាសំខាន់ៗដូចជាសេដ្ឋកិច្ចកម្ពុជា និងការអភិវឌ្ឍឌីជីថលដូចជា៖

ភាពជាអ្នកដឹកនាំឌីជីថល

ការចាប់យក និងវិវឌ្ឍយ៉ាងរហ័សលើកម្មវិធីធនាគារចល័តដើម្បីផ្តល់នូវសេវាធនាគារប្រកបដោយសុវត្ថិភាពខ្ពស់ និងអាចប្រើប្រាស់បានគ្រប់ពេលវេលា ២៤/៧។

ការផ្តោតលើអតិថិជនជាអាទិភាព

រចនាផលិតផល និងសេវាហិរញ្ញវត្ថុទៅតាមតម្រូវការ ងាយស្រួលប្រើប្រាស់ ដែលមានភាពបត់បែន។

បរិយាបន្នហិរញ្ញវត្ថុ

ពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុដល់ សហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយប្រាកដថាប្រជាជនកម្ពុជាទាំងអស់ អាចទទួលបានការប្រើប្រាស់សេវាហិរញ្ញវត្ថុបានយ៉ាងងាយស្រួល។

ការរួមបញ្ចូលប្រព័ន្ធអេកូឡូស៊ី

កិច្ចសហប្រតិបត្តិការ ជាមួយធនាគារជាតិ នៃកម្ពុជា (NBC) លើសេវាផ្ទេរប្រាក់តាមរយៈបាគង និងក្រសួងពាក់ព័ន្ធនានាដូចជាការបង់ពន្ធវិក្កយបត្រផ្សេងៗ ដើម្បីឱ្យកាន់តែមានភាពងាយស្រួលដល់អ្នកប្រើប្រាស់។



ប្រតិបត្តិការផ្នែកឥណទាន

ផលប័ត្រឥណទានសរុបរបស់ធនាគារ មានសមតុល្យ ២.០៦០ លានដុល្លារអាមេរិក។ ស្របពេលដែលឥណទាន នៃសេវាហិរញ្ញវត្ថុបុគ្គលបានកើនឡើង ២,០៤% ដោយមានការរួមចំណែកជាវិជ្ជមានពីសេវាហិរញ្ញវត្ថុបុគ្គល ដែលមានទ្រព្យសម្បត្តិសុទ្ធខ្ពស់ (HNW)។ ស្របពេលដែលផ្នែកស្ថាប័នហិរញ្ញវត្ថុ (FI) មានការថយចុះ ខណៈពេលដែលផ្នែកពាណិជ្ជកម្មបន្តកើនឡើង ។



ផលប័ត្រឥណទាន

២.០៦០ លានដុល្លារអាមេរិក



គំនិតផ្តួចផ្តើម និងដៃគូយុទ្ធសាស្ត្រ

ដើម្បីពង្រឹងជំហរទីផ្សាររបស់ខ្លួនឱ្យកាន់តែរឹងមាំ ធនាគារ ស្ថាបនា បានអនុវត្តនូវគំនិតផ្តួចផ្តើមសំខាន់ៗ ដូចជា៖

- **ការគាំទ្រលើវិស័យកសិកម្ម**

  កិច្ចសហប្រតិបត្តិការសំខាន់ៗរួមមានកម្មវិធី "គម្រោងពង្រឹងសមត្ថភាពប្រកួតប្រជែង និងសុវត្ថិភាពនៃខ្សែសង្វាក់តម្លៃកសិកម្ម (ACSEP)" ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងជាពិសេសដើម្បីគាំទ្រដល់វិស័យកសិកម្មដ៏សំខាន់ តាមរយៈអត្រាការប្រាក់ត្រឹម ៧% ក្នុងមួយឆ្នាំ។

- **សេវាផ្ទេរឥណទាន**

  សេវាផ្ទេរឥណទានត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការបង់រំលស់ទាបជាងមុន និងមានដើមទុនខ្លះសម្រាប់វិនិយោគក្នុងអាជីវកម្មរបស់អតិថិជន។ គិតត្រឹមខែធ្នូ ឆ្នាំ ២០២៥ សមតុល្យឥណទានសរុបចំនួន ១៩៧.៧៣ លានដុល្លារអាមេរិក និងគណនីចំនួន ៤.៤០៣។

ធនាគារ ឌីជីថល

Sathapana Mobile

Sathapana Mobile ទទួលបានការគាំទ្រយ៉ាងច្រើនគួរឱ្យកត់សម្គាល់នៅឆ្នាំ ២០២៥ ដោយមានអ្នកប្រើប្រាស់សរុប ៤៦៣.០០០ នាក់ និងការធ្វើប្រតិបត្តិការចំនួន ១៤ លានប្រតិបត្តិការ ដែលមានតម្លៃស្មើ ៤ ពាន់លានដុល្លារអាមេរិក។ ការធ្វើបច្ចុប្បន្នកម្មដ៏សំខាន់មួយនេះ បាននាំមកនូវចំណុចកែប្រែសំខាន់ៗរួមមាន ការរចនាផ្ទាំងអេក្រង់ថ្មីផ្តល់ភាពបត់បែនតាមតម្រូវការ និងសុវត្ថិភាពខ្ពស់ជាមួយមុខងារ FacePass ដ៏រឹងមាំ ដែលជាកត្តាធ្វើឱ្យ Sathapana Mobile ទទួលបានពានរង្វាន់ឆ្នើមឆ្នាំ២០២៥ លើភាពច្នៃប្រឌិតនៅកម្ពុជា។



សមិទ្ធផលធំៗប្រចាំឆ្នាំ ២០២៥៖

កំណើន

អ្នកប្រើប្រាស់សកម្មកើនឡើង ៣៣% ដែលជាសញ្ញាដ៏ល្អនៃការផ្លាស់ប្តូរទៅប្រើប្រាស់សេវាធនាគារឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាចប្រើប្រាស់ជាសកល

ការដាក់ឱ្យប្រើប្រាស់នូវការទូទាត់តាម QR ឆ្លងប្រទេស រវាងប្រទេសកម្ពុជា (KHQR) និងប្រទេសជប៉ុន(JPQR)។

គ្រប់យ៉ាងនៅក្នុងអេបតែមួយ

ប្រតិបត្តិការធនាគារដ៏សម្បូរបែបរួមមាន ផ្ទេរប្រាក់បានភ្លាមៗ ទូទាត់វិក្កយបត្រ និងអាចស្នើកម្ចីយ៉ាងងាយស្រួល និងសុវត្ថិភាពខ្ពស់ពីទូរស័ព្ទបាន។





កម្មវិធីទូរស័ព្ទសម្រាប់ដៃគូអាជីវកម្ម

កម្មវិធីនេះគឺអាចជួយដល់ប្រតិបត្តិការអាជីវកម្មខ្នាតតូចដោយការផ្តល់នូវសេវាឌីជីថលដោយមិនប្រើប្រាស់សាច់ប្រាក់ដោយទទួលទូទាត់ប្រាក់តាម KHQR និងវិក្កយបត្រអេឡិចត្រូនិក។ គិតមកត្រឹមឆ្នាំ ២០២៥ កម្មវិធីនេះទទួលបាននូវកំណើនដ៏គួរឱ្យកត់សម្គាល់រួមមានចំនួនដៃគូអាជីវកម្មឈានដល់ ១១៥.០០០ (កើនឡើង ៥៥%) អ្នកប្រើប្រាស់សកម្មកើនឡើង ៤៥% និងចំនួនប្រតិបត្តិការទូទាត់តាម QR លើសពី ៤,៨ លានដង ស្មើនឹង ១ ទ្រីលានរៀល (២៩២ លានដុល្លារអាមេរិក)។

ចំនួនដៃគូអាជីវកម្ម

៧៧K
២០២៤

៥៥%
កើនឡើងពីឆ្នាំ ២០២៤

១១៥K
២០២៥



កំណើនសាជីវកម្ម

កម្មវិធីសាជីវកម្ម ស្ថាបនា ផ្តល់ជូនម្ចាស់អាជីវកម្មនូវដំណោះស្រាយឌីជីថល ដែលមានសុវត្ថិភាព និងពេញលេញសម្រាប់ការ ផ្ទេរប្រាក់ ការបើកប្រាក់បៀវត្សរ៍ និងការទូទាត់ផ្សេងៗ។ ជាមួយនឹងកម្រៃសេវាសមរម្យ និងអត្ថប្រយោជន៍ផ្តាច់មុខ វាបង្កើនប្រសិទ្ធភាពតាមរយៈការផ្ទេរប្រាក់បាគងបានភ្លាមៗ ការអនុម័តដែលមានភាពបត់បែន និងការផ្តល់ជូននូវរបាយការណ៍បានទាន់ពេល។



ប័ណ្ណ ស្ថាបនា

គិតមកត្រឹមឆ្នាំ ២០២៥ ធនាគារ ស្ថាបនា បានចេញប័ណ្ណចំនួន ២០១.២៦៧ ដែលត្រូវបានជំរុញដោយការកើនឡើងយ៉ាងខ្លាំងនៃទំហំនៃការទូទាត់ និងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្ររបស់យើងជាមួយក្រុមហ៊ុន Mastercard និង Visa។ តាមរយៈកិច្ចសហប្រតិបត្តិការដ៏រឹងមាំ ជួយបង្កើនបទពិសោធធនាគារដ៏ល្អជូនអតិថិជន ដោយផ្តល់នូវគុណតម្លៃកាន់តែច្រើន និងភាពងាយស្រួលប្រើប្រាស់ជាសកល។

ប័ណ្ណ ស្ថាបនា ត្រូវបានរចនាឡើង ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាព ប័ណ្ណទាំងនេះផ្តល់អតិថិជននូវភាពងាយស្រួលក្នុងការទូទាត់ផ្សេងៗ និងដកប្រាក់យ៉ាងងាយស្រួលពីម៉ាស៊ីនអេធីអឹមជាង ២ លានគ្រឿងនៅទូទាំងពិភពលោក។ ស្របពេលដែលប័ណ្ណឥណពន្ធរបស់យើងផ្តល់នូវភាពងាយស្រួលក្នុងការប្រើប្រាស់ទឹកប្រាក់ប្រកបដោយសុវត្ថិភាពខ្ពស់ជាប្រចាំ ផលិតផលឥណទាន ស្ថាបនា បានជួយអតិថិជនកសាងមូលដ្ឋានហិរញ្ញវត្ថុសម្រាប់អាជីវកម្ម ឬគោលដៅទិញផ្ទះ។ សម្រាប់អតិថិជនព្រីមារណ៍ ប័ណ្ណឥណទានរបស់យើងក៏ផ្តល់នូវអត្ថប្រយោជន៍ផ្តាច់មុខជាច្រើនផងដែរ រួមមាន អាចប្រើប្រាស់សាល រង់ចាំនៅព្រលានយន្តហោះ និងការធានារ៉ាប់រងលើការធ្វើដំណើរហូតដល់ ១ លានដុល្លារ។





MASTERCARD SEND (ការទទួលប្រាក់)

Mastercard Send បន្ថែមលទ្ធភាពឱ្យអតិថិជនរបស់ធនាគារ ស្ថាបនា ទទួលប្រាក់ភ្លាមៗ ប្រកបដោយសុវត្ថិភាពខ្ពស់ និងការផ្ទេរប្រាក់ទៅមក-ក្រៅប្រទេស ដោយផ្ទាល់ទៅក្នុងគណនីធនាគារដែលភ្ជាប់ជាមួយប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទានរបស់អតិថិជន។

ការជូនដំណឹងអំពីប្រតិបត្តិការ

ជាមួយកម្មវិធី Sathapana Mobile លោកអ្នកអាចទទួលបានការជូនដំណឹងភ្លាមៗ សម្រាប់រាល់ប្រតិបត្តិការដែលបានធ្វើ ការធ្វើបច្ចុប្បន្នភាព វិក្កយបត្រផ្សេងៗ ដែលអនុញ្ញាតឱ្យអតិថិជនមើលដែនកំណត់ឥណទាន របាយការណ៍ និងប្រវត្តិប្រតិបត្តិការប្រកបដោយសុវត្ថិភាព។

ចំណុចសំខាន់សម្រាប់ឆ្នាំ ២០២៦

ខណៈពេលដែលយើងកំពុងឈានចូលទៅឆ្នាំ ២០២៦ យើងកំពុងផ្តោតលើការជំរុញនវានុវត្តន៍ តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ និងការពង្រឹងសុវត្ថិភាពប័ណ្ណ។ តាមរយៈការលើកកម្ពស់ផលិតផល និងបទពិសោធអ្នកប្រើប្រាស់ យើងនៅតែប្តេជ្ញាផ្តល់សេវាកម្មធនាគារដែលរលូន និងទំនុកចិត្តខ្ពស់ ស័ក្តិសមនឹងអ្វីដែលអតិថិជនគួរទទួលបាន។

ការអភិវឌ្ឍ
ធនធានមនុស្ស

នៅធនាគារ ស្ថាបនា យើងប្តេជ្ញាជំរុញការរីកចម្រើនផ្នែកវិជ្ជាជីវៈនៃធនធានមនុស្សរបស់យើង ដែលមានបុគ្គលិកសរុបចំនួន ៣.៤៦៤ នាក់។ យើងប្តេជ្ញាបំពាក់បំប៉នដល់បុគ្គលិករបស់យើងនូវជំនាញ ផ្នត់គំនិត និងគុណតម្លៃ ដែលត្រូវមានជាចាំបាច់សម្រាប់ការរីកចម្រើនប្រកបដោយចីរភាព និងលទ្ធផលការងារខ្ពស់។ នៅឆ្នាំ២០២៥ យើងមានយុទ្ធសាស្ត្រផ្តោតលើការបង្កើនការបញ្ចូលបុគ្គលិកថ្មី ការរៀបចំអ្នកដឹកនាំអនាគត និងការពង្រឹងសមត្ថភាពស្ថាប័នតាមរយៈគំនិតផ្តួចផ្តើមផ្ទៃក្នុង និងភាពជាដៃគូយុទ្ធសាស្ត្រ។



ស្ថាបនា អនាគត៖ សាលនវានុវត្តន៍

ជាកន្លែងដែលបុគ្គលិក អ្នកច្នៃប្រឌិតវ័យក្មេង និងអ្នកមានទេពកោសល្យផ្នែកបច្ចេកវិទ្យាទាំងអស់អាចសហការ ប្រមើលមើល និងភ្ជាប់ទំនាក់ទំនងគ្នា ដើម្បីអភិវឌ្ឍគំនិតច្នៃប្រឌិត និងនវានុវត្តន៍។







ភោជនីយដ្ឋាន LUCE

សុខុមាលភាពបុគ្គលិកគឺជាគន្លឹះនាំឱ្យយើងទទួលបានជោគជ័យ។ ហេតុដូច្នេះហើយទើបធនាគារ ស្ថាបនា បានសាងសង់អាហារដ្ឋានខាងក្នុង គឺភោជនីយដ្ឋាន **LUCE** ដើម្បីផ្តល់អាហារដ៏ឈ្ងុយឆ្ងាញ់ និងមានសុខភាពល្អដល់ក្រុមការងាររបស់យើង។

សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៥



- **កម្មវិធីអាហារូបករណ៍**
  ផ្តល់ថវិកាសម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល ៤ឆ្នាំដល់និស្សិតដែលមានជីវភាពខ្វះខាតចំនួន ៥នាក់។
- **ប្រព័ន្ធរៀបចំអ្នកដឹកនាំថ្មី**
  បានចាប់ផ្តើមដំណើរការកម្មវិធី Management Trainee និងក្រុមមានទេពកោសល្យសម្រាប់បន្តវេន
- **ការបញ្ចូលបុគ្គលិកថ្មី**
  បានរៀបចំស្តង់ដារកម្មវិធីបញ្ចូលបុគ្គលិកថ្មីប្រចាំខែដើម្បីឱ្យមានការចូលរួមឱ្យបានជាប់លាប់
- **ការអភិវឌ្ឍជំនាញ**
  បានរៀបចំសិក្ខាសាលាស្តីពីការគ្រប់គ្រងពេលវេលា និងទំនាក់ទំនង។
- **អនុលោមភាព និងវប្បធម៌ដោះស្រាយហានិភ័យ**
  បានរៀបចំវគ្គបណ្តុះបណ្តាលរឿងផ្នែកផ្សេងៗគ្នា។
- **ភាពជាដៃគូយុទ្ធសាស្ត្រ**
  បានសហការជាមួយ IBF អំពីកម្មវិធីបញ្ជាក់វិញ្ញាបនបត្រឆ្នាំ ២០២៦។
- **ការរីកចម្រើនរបស់ថ្នាក់ប្រតិបត្តិ**
  បានរៀបចំទស្សនកិច្ចសិក្សាដកបទពិសោធក្នុងតំបន់សម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់។

ការគ្រប់គ្រង ហានិភ័យ
អភិបាលកិច្ចសាជីវកម្ម និងការប្រតិបត្តិតាម

ភាពជោគជ័យនៃយុទ្ធសាស្ត្ររបស់អាជីវកម្មមួយ ត្រូវការការគាំទ្រលើការគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ទៅលើអភិបាលកិច្ចសាជីវកម្មល្អ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម។ យើងឱ្យតម្លៃលើអភិបាលកិច្ចសាជីវកម្មល្អ ដែលក្នុងនោះរួមមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរឹងមាំដើម្បីធានាឱ្យបាននូវបរិយាកាសគ្រប់គ្រងមួយសម្រាប់ការរីកចម្រើនប្រកបដោយនិរន្តភាព ក៏ដូចជាដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងជីវភាពរស់នៅ របស់ប្រជាជនកម្ពុជាតាមរយៈការផ្តល់នូវសេវាកម្មរបស់ធនាគារដោយផ្ទាល់ និងដោយប្រយោលជូនពួកគេ។ អភិបាលកិច្ចសាជីវកម្មរបស់យើងត្រូវបានបង្កើតឡើងយ៉ាងល្អ និងមានភាពប្រទាក់ក្រឡាគ្នាចាប់តាំងពីកម្រិតក្រុមប្រឹក្សាភិបាល។



ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ មានជំនាញច្បាស់លាស់ និងបទពិសោធយ៉ាងច្រើនក្នុងវិស័យធនាគារ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។ សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ រួមមាន សមាជិកឯករាជ្យ និងសមាជិកមិនឯករាជ្យ។ សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ស្ថាបនា មានគណៈកម្មការបួនដែលក្នុងនោះរួមមានគណៈកម្មការគ្រប់គ្រងហានិភ័យ គណៈកម្មការសវនកម្ម គណៈកម្មការអត្ថប្រយោជន៍ និងការតែងតាំង និងគណៈកម្មការយុទ្ធសាស្ត្រ។ ក្រុមប្រឹក្សាភិបាល និងគណៈកម្មការទាំងបួនមានតួនាទី និង ទំនួលខុសត្រូវច្បាស់លាស់ក្នុងការការពារផលប្រយោជន៍របស់ធនាគារ បង្កើតគុណតម្លៃ និងដឹកនាំយុទ្ធសាស្ត្រអាជីវកម្មដែលរួមមានការយល់ព្រម និងការត្រួតពិនិត្យយកការអនុវត្តគោលដៅយុទ្ធសាស្ត្រ ក្របខ័ណ្ឌអភិបាលកិច្ចល្អ និងវប្បធម៌អាជីវកម្មរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលក៏ត្រួតពិនិត្យមើលផងដែរលើការជ្រើសរើសបុគ្គលិក ការតម្លើងដំណែង និងការចាត់តាំងបុគ្គលសំខាន់ៗនៅក្នុងជួរថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។ ក្រុមប្រឹក្សាភិបាលត្រូវតែធានាឱ្យបានថារាល់សកម្មភាពទាំងឡាយរបស់ថ្នាក់គ្រប់គ្រង ត្រូវតែស្របជាមួយនឹងយុទ្ធសាស្ត្រគោលដៅ គោលនយោបាយ និងកម្រិតហានិភ័យដែលអាចទទួលយកបានដែលកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារផ្ទាល់។

ថ្នាក់គ្រប់គ្រងជាន់ខ្ពស់

បន្ថែមពីលើគណៈកម្មការទាំងបួនខាងលើ ក្រុមប្រឹក្សាភិបាលបានផ្តល់សិទ្ធអំណាចឱ្យទៅប្រធាននាយកប្រតិបត្តិ និងគណៈកម្មការគ្រប់គ្រង ដើម្បីត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ យុទ្ធសាស្ត្រ និងគោលដៅរបស់ធនាគារ ទៅតាមជំនាញរៀងៗខ្លួន សម្រាប់សកម្មភាពគ្រប់គ្រងប្រចាំថ្ងៃ។

ការការពារទាំងបី

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារ ត្រូវបានកំណត់ឡើង និងអនុវត្តស្របទៅតាមបន្ទាត់នៃការការពារទាំងបីថ្នាក់តាមការរៀបចំឡើងដោយគណៈកម្មការគ្រប់គ្រង ធនាគារបាសែលហៅកាត់ថា (BCBS)។ ចំណាត់ថ្នាក់នៃការការពារនីមួយៗមានតួនាទីនិងទំនួលខុសត្រូវទៅតាមជំនាញរៀងៗខ្លួន។

ការការពារថ្នាក់ទីមួយ

សំដៅដល់ផ្នែកប្រតិបត្តិការអាជីវកម្ម និងផ្នែកគាំទ្រប្រតិបត្តិការអាជីវកម្មដែលជាម្ចាស់ហានិភ័យផ្ទាល់ គ្រប់គ្រងរាល់ប្រភេទហានិភ័យទាំងអស់ដែលអាចកើតមានឡើងក្នុងពេលធ្វើប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

ការការពារថ្នាក់ទីពីរ

សំដៅដល់ផ្នែកគ្រប់គ្រងហានិភ័យ និងផ្នែកប្រតិបត្តិតាមដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យក្នុងធនាគារទាំងមូលព្រមទាំង បញ្ហាប្រតិបត្តិតាមនានាដែលរួមមាន ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ផ្នែកទាំងពីរនេះ គឺជាផ្នែកឯករាជ្យត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មការគ្រប់គ្រងហានិភ័យ។

ការការពារថ្នាក់ទីបី

សំដៅដល់ផ្នែកសវនកម្មផ្ទៃក្នុងដែលមានតួនាទី និងទំនួលខុសត្រូវចម្បងៗ រួមមានការចុះធ្វើសវនកម្មទូទៅ និងសវនកម្មដែលផ្អែកលើកត្តាហានិភ័យ ដើម្បីពិនិត្យមើលឡើងវិញ និងផ្តល់ការធានាជូនចំពោះក្រុមប្រឹក្សាភិបាលដោយធ្វើឱ្យប្រាកដថា ក្របខ័ណ្ឌអភិបាលកិច្ចទាំងមូលរួមនឹងក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យ យុទ្ធសាស្ត្រ និងគោលដៅរបស់ធនាគារ គឺត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងសមស្របតាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល។

ក្រមសីលធម៌ និងវិជ្ជាជីវៈអាជីវកម្ម

យើងមានក្រមសីលធម៌យ៉ាងល្អដែលបង្ហាញអំពីវប្បធម៌សាជីវកម្ម ដែលស្របទៅតាមកម្រងច្បាប់ និងបទប្បញ្ញត្តិ។ ពួកយើងផ្តល់តម្លៃយ៉ាងខ្លាំងទៅលើកម្រិតជំនាញនៃគុណភាពការងារ ការធ្វើយ៉ាងណាដែលនាំឱ្យយើងឆ្ពោះទៅរកការរីកចម្រើន និងទទួលបានជំនឿចិត្តពីអតិថិជន និងនិយោជិតទាំងអស់។ ក្រុមការងាររបស់យើងតែងតែផ្តោតសំខាន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មល្អឥតខ្ចោះជូនអតិថិជន។ ក្រមសីលធម៌របស់ធនាគារ ស្ថាបនា គឺត្រូវប្រាកដថាមិនមានការរើសអើងជាតិសាសន៍ ការបៀតបៀនផ្លូវភេទ ឬ និន្នាការនយោបាយនៅក្នុងធនាគារឡើយ។ យើងបានផ្តល់នូវសេវាហិរញ្ញវត្ថុយ៉ាងស្មើភាពជូនសាធារណជនគ្រប់ស្រទាប់វណ្ណៈដោយមិនមានការរើសអើងឡើយ និងរក្សាឱ្យបាននូវសុវត្ថិភាពព័ត៌មានរបស់អតិថិជន។

ទំនាស់ផលប្រយោជន៍

យើងមានគោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ដែលគ្រប់និយោជិតទាំងអស់ រួមទាំងសមាជិកក្រុមប្រឹក្សាភិបាល គឺតម្រូវឱ្យប្រកាសនូវទំនាស់ផលប្រយោជន៍របស់ខ្លួនមកកាន់ធនាគារ។ ពួកយើងគ្រប់គ្រងទំនាស់ផលប្រយោជន៍ ដោយការរៀបចំការវាយតម្លៃយ៉ាងត្រឹមត្រូវទៅលើការប្រតិបត្តិការងាររបស់និយោជិត។ សរុបមកគោលដៅរបស់យើងគឺ ការពារកេរ្តិ៍ឈ្មោះរបស់ធនាគារ និងការរក្សាបាននូវការជឿទុកចិត្តពីបុគ្គលិក និងសាធារណជន។

ការគ្រប់គ្រងហានិភ័យ

ធនាគារ ស្ថាបនា ទទួលស្គាល់ថាការគ្រប់គ្រងហានិភ័យជាធាតុសំខាន់មួយសម្រាប់ការត្រួតពិនិត្យ និងការគាំទ្រទូទៅដើម្បីសម្រេចឱ្យបាននូវយុទ្ធសាស្ត្រ និងគោលដៅរបស់ធនាគារ។ តាមរយៈការការពារថ្នាក់ទីពីរ នាយកដ្ឋានគ្រប់គ្រងហានិភ័យបានផ្តល់នូវទស្សនៈវិស័យវិភាគហានិភ័យ ដើម្បីការពារផលប្រយោជន៍របស់ធនាគារពីសកម្មភាពអាជីវកម្មដែលអាចប៉ះពាល់នៅក្នុងដំណើរការអាជីវកម្ម ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងគំនិតផ្តួចផ្តើមអាជីវកម្ម។

ធនាគារ អនុវត្តក្របខ័ណ្ឌរឹសអាបតៃថាយ (Risk Appetite) ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យ សកម្មភាពហានិភ័យនានាដែល សមស្របទៅនឹងរឹសអាបតៃថាយ (Risk Appetite) និងរឹសថលើរ៉ែន (Risk Tolerance)។ គោលនយោបាយ នីតិវិធី និងការណែនាំនានា ត្រូវបាន បង្កើតយ៉ាងល្អ បានផ្សព្វផ្សាយ និងត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។

បន្ថែមពីលើនេះទៀត នាយកដ្ឋានគ្រប់គ្រងហានិភ័យបានតាមដានយ៉ាងល្អិតល្អន់អំពីការគំរាមកំហែង និងឱកាសផ្សេងៗពីមជ្ឈដ្ឋានខាងក្រៅរួមមានសេដ្ឋកិច្ច វិស័យដែលកំពុងលូតលាស់ ទីផ្សារប្រកួតប្រជែង នយោបាយ សង្គម ការអភិវឌ្ឍនៃបច្ចេកវិទ្យា និងគ្រោះធម្មជាតិ។

ធនាគារ ស្ថាបនា ប្រឈមនឹងហានិភ័យដូចខាងក្រោម៖

ហានិភ័យឥណទាន

ការគ្រប់គ្រងហានិភ័យឥណទានត្រូវបានទទួលបន្ទុកដោយគណៈកម្មការឥណទានរបស់ធនាគារ។ ហានិភ័យឥណទាន គឺជាការខាតបង់ហិរញ្ញវត្ថុរបស់ធនាគារនៅពេលអ្នកខ្ចី ឬ កូនបំណុលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមកិច្ចសន្យា។ ហានិភ័យឥណទាន គឺជាហានិភ័យចម្បងមួយសម្រាប់អាជីវកម្មផ្នែកវិស័យធនាគារ។ ហានិភ័យឥណទានអាចមាននៅក្នុងឧបករណ៍ហិរញ្ញវត្ថុក្នុង និងក្រៅតារាងតុល្យការ។

ធនាគារ ស្ថាបនា បានបង្កើតគោលនយោបាយឥណទាន ដើម្បីគ្រប់គ្រងសកម្មភាពនៃការផ្តល់ឥណទានរបស់ខ្លួន។ ការផ្តល់ឥណទានត្រូវបានអនុវត្តនៅក្រោមគោលនយោបាយឥណទានដែលបានរៀបចំសម្រាប់បណ្តុំផលិតផលឥណទាន រួមមានគោលដៅទីផ្សារ លក្ខខ័ណ្ឌ ឯកសារ និងនីតិវិធីដែលផលិតផលឥណទានត្រូវបានធ្វើការវាស់វែង និងវាយតម្លៃដោយអ្នកទទួលបន្ទុក។ បន្ថែមពីនេះ ធនាគារ ស្ថាបនា ត្រូវធានាធ្វើការបែងចែកភារកិច្ចយ៉ាងច្បាស់លាស់រវាងអ្នកបង្កើតឥណទាន អ្នកវាយតម្លៃឥណទាន និងអ្នកអនុម័តឥណទាន។

ហានិភ័យឥណទាន គឺត្រូវតែតាមដានគ្រប់គ្រងជាប្រចាំ និងវិភាគអំពីសមត្ថភាពនៃការសងបំណុលរបស់អតិថិជនទាំងប្រាក់ដើម និងការប្រាក់ទៅតាមកិច្ចសន្យាដែលបានកំណត់ និងវាយតម្លៃថាអតិថិជនណាមានសក្តានុពល។ ថ្នាក់គ្រប់គ្រងត្រូវធ្វើការពិនិត្យមើលជារៀងរាល់ឆ្នាំ បន្ទាប់ពីបានការផ្តល់ឥណទានជូនអតិថិជនដើម្បីវិភាគស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពពាក់ព័ន្ធនឹងការសងប្រាក់របស់អតិថិជន។ ការអនុវត្តទូទៅដើម្បីគ្រប់គ្រងហានិភ័យឥណទាន គឺត្រូវទាមទារឱ្យមានវត្ថុបញ្ចាំ និងវត្ថុធានាផ្សេងៗរបស់អតិថិជន។ ធនាគារ ស្ថាបនា បានអនុវត្តទៅតាមគោលនយោបាយឥណទាន គឺតម្រូវឱ្យធនាគារទាមទារវត្ថុបញ្ចាំពីអតិថិជន លើសពីនេះទៀត ធនាគារក៏បានអនុវត្តការណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ទ្រព្យបញ្ចាំ ឬដើម្បីកាត់បន្ថយហានិភ័យឥណទាន។

ប្រភេទនៃទ្រព្យបញ្ចាំដែលយកមកជានាលើឥណទានរួមមាន៖

- ហ៊ីប៉ូតែកលើទ្រព្យសម្បត្តិ ឬលំនៅដ្ឋានរួមមាន៖ ដី អគារ និងទ្រព្យសម្បត្តិផ្សេងៗ
- តម្លៃនៃទ្រព្យសកម្មអាជីវកម្មដូចជា៖ ដី អគារ
- វត្ថុធានាមានទម្រង់ជាប្រាក់បញ្ញើមានកាលកំណត់

ក្រៅពីការទទួលយកទ្រព្យបញ្ចាំសម្រាប់កាត់បន្ថយហានិភ័យឥណទាន ធនាគារ បានចូលរួមជាមួយ សាជីវកម្មធានាឥណទានកម្ពុជា តាមរយៈការទទួលយកការធានាឥណទាន ដោយគ្មានទ្រព្យបញ្ចាំ។ ការចូលរួមរបស់ធនាគារនេះ គឺដើម្បីចូលរួមចំណែកក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចតាមរយៈសកម្មភាពផ្តល់កម្ចីរបស់ធនាគារទៅដល់សហគ្រាសធនតូច និងមធ្យម ហើយក៏ជាផ្នែកមួយក្នុងការចូលរួមចំណែកក្នុងការគាំទ្របរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ប្រជាជនកម្ពុជា។

ធនាគារ យល់អំពីដំណាក់កាលងើបឡើងវិញនៃសេដ្ឋកិច្ចបន្ទាប់ពី ផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ១៩ និងភាពយឺតយ៉ាវនៃកំណើនសេដ្ឋកិច្ចពិភពលោក ដែលបង្កឱ្យមានការប៉ះពាល់ដល់ប្រភពចំណូលរបស់អតិថិជនមួយចំនួន។ នេះជាផ្នែកមួយរបស់ធនាគារ ក្នុងការអនុវត្តតាមសេចក្តីណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការធ្វើឥណទានរៀបចំឡើងវិញជូនអតិថិជន។ ទាំងអស់នេះ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការចូលរួមរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ និងជួយបន្ធូរភាពតានតឹងហិរញ្ញវត្ថុរបស់អតិថិជន។ បន្ថែមលើនោះទៅទៀត ធនាគារ នៅតែបន្តធ្វើឥណទានរៀបចំឡើងវិញទៅតាមសំណើរបស់អតិថិជនដោយអនុវត្តតាមសេចក្តីណែនាំរបស់ ធនាគារជាតិ នៃកម្ពុជា និងបរិបទសេដ្ឋកិច្ច។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារគឺជាហានិភ័យនៃការខាតបង់ ឬ ការបាត់បង់ដែលអាចកើតមានឡើងតាមរយៈការកើនឡើងនៃចលនានៃតម្លៃទីផ្សារ ឬ ការប្រែប្រួលតម្លៃទីផ្សារ ដែលធ្វើឱ្យតម្លៃអនាគតនៃលំហូរសាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុនឹងមានការឡើងចុះដោយសារការផ្លាស់ប្តូរនៃតម្លៃទីផ្សារ។ ហានិភ័យទីផ្សារកើតឡើងពីស្ថានភាពបើកចំហរនៃអត្រាការប្រាក់ រូបិយប័ណ្ណ និងមូលធន ដែលកត្តាទាំងអស់នេះទទួលឥទ្ធិពលពីចលនាទីផ្សារទូទៅជាក់លាក់ និងការប្រែប្រួលមិនទៀងនៃអត្រា ឬ តម្លៃទីផ្សារដូចជាអត្រាការប្រាក់ គម្លាតឥណទាន អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃនៃមូលធន។

ធនាគារ ទទួលរងការប៉ះពាល់ចំពោះហានិភ័យទីផ្សារទៅលើសកម្មភាពអាជីវកម្មក្នុងបញ្ជីធនាគារ (Banking Book) តែប៉ុណ្ណោះ និងមិនទទួលរងនូវការប៉ះពាល់ពីហានិភ័យទីផ្សារក្នុងបញ្ជីជួញដូរ (Trading Book) ឡើយ។ ហានិភ័យទីផ្សារដ៏សំខាន់របស់ធនាគារ គឺហានិភ័យដែលមានទំនាក់ទំនងទៅនឹងហានិភ័យអត្រាការប្រាក់ និងហានិភ័យនៃអត្រាប្តូររូបិយប័ណ្ណ បរទេស ដែលជាគន្លឹះដ៏សំខាន់នៃហានិភ័យទីផ្សារនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃនៅក្នុងទីផ្សារធនាគារ នៃព្រះរាជាណាចក្រកម្ពុជា។

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការខាតបង់ ឬ ការបាត់បង់ដោយផ្ទាល់ ឬ ដោយប្រយោលដែលបណ្តាលមកពីកង្វះខាត និងការមិនដំណើរការនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង កត្តាមនុស្ស កត្តាបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ ឬ បណ្តាលមកពីកត្តាខាងក្រៅ ដោយរាប់បញ្ចូលតាំងពីហានិភ័យ ដែលកើតចេញពីលក្ខខណ្ឌផ្លូវច្បាប់ និយ័តកម្ម។

ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការ ធនាគារ បានគ្រប់គ្រងតាមរយៈដំណើរការនៃការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដែលរួមមាន ការត្រួតពិនិត្យ និងការរាយការណ៍នៃសកម្មភាពអាជីវកម្មឱ្យបានត្រឹមត្រូវ និងមានការគាំទ្រពីផ្នែកដែលពាក់ព័ន្ធ ហើយគ្រប់គ្រងដោយថ្នាក់គ្រប់គ្រងជាន់ខ្ពស់។

ក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យប្រតិបត្តិការនៅក្នុងធនាគារ នាំឱ្យមានការបង្កើតយ៉ាងច្បាស់នូវរចនាសម្ព័ន្ធ តួនាទី ក៏ដូចជាគោលនយោបាយនៃការគ្រប់គ្រង។ គោលនយោបាយនៃការគ្រប់គ្រង និងការវាស់វែងផ្ទៃក្នុងផ្សេងទៀតត្រូវបានអនុវត្តដែលរួមមាន ការបង្កើតសិទ្ធិចុះហត្ថលេខា ការកំណត់ប៉ារ៉ាម៉ែត្រនៃការគ្រប់គ្រង ការធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងការអនុវត្តទៅតាមលក្ខខណ្ឌតម្រូវ និយ័តកម្ម និងលក្ខខណ្ឌផ្លូវច្បាប់ផ្សេងទៀត។

គោលដៅនៃការគ្រប់គ្រងហានិភ័យប្រតិបត្តិការមិនមែនលុបបំបាត់រាល់ហានិភ័យទាំងអស់នោះទេ ប៉ុន្តែគឺដើម្បីធានាបានថាការគ្រប់គ្រងដែលដាក់ឱ្យបានអនុវត្ត និងហានិភ័យប្រតិបត្តិការដែលសេសសល់របស់ធនាគារ នៅតែស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន និងគោរពទៅតាមកម្រិតហានិភ័យដែលធនាគារបានកំណត់។

ដើម្បីលើកកម្ពស់ និងធ្វើឱ្យប្រាកដទៅលើការគ្រប់គ្រងហានិភ័យប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាព យើងមានឧបករណ៍វាយតម្លៃហានិភ័យដែលរួមបញ្ចូលនូវការអនុវត្តនិងការប្រតិបត្តិនៃការគ្រប់គ្រង និងការវាយតម្លៃហានិភ័យដោយខ្លួនឯង Risk and Control Self-Assessment (RCSA) នូវរាល់ការធ្វើប្រតិបត្តិការរបស់សាខានិងគ្រប់នាយកដ្ឋានទាំងអស់។ យុទ្ធសាស្ត្រអាជីវកម្មជលិតផល និងសេវាកម្មថ្មីត្រូវបានរួមបញ្ចូលគ្នាទៅលើការវាយតម្លៃហានិភ័យ ដើម្បីកាត់បន្ថយហានិភ័យដែលអាចប៉ះពាល់ដល់ធនាគារមកកម្រិតដែលអាចទទួលយកបាន។

យើងមានគោលការណ៍ធានារ៉ាប់រងដើម្បីផ្ទេរ និងកាត់បន្ថយហានិភ័យប្រតិបត្តិការផ្សេងៗ ដែលគ្របដណ្តប់ទៅលើប្រភេទនៃឧប្បត្តិហេតុផ្សេងៗគ្នា ដូចជាធានារ៉ាប់រងលើប្រតិបត្តិការអាជីវកម្មទាំងមូលរបស់ធនាគារ និងធានារ៉ាប់រងលើឧក្រិដ្ឋកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងកុំព្យូទ័រ (គោលនយោបាយ BBB and ECC) ធានារ៉ាប់រងលើសំណងចំពោះការប្រព្រឹត្តរបស់អ្នកគ្រប់គ្រង និងបុគ្គលិក (គោលនយោបាយ D&O) ធានារ៉ាប់រងសាច់ប្រាក់នៅក្នុងម៉ាស៊ីនអេធីអឹម និងការដឹកជញ្ជូនសាច់ប្រាក់ និងធានារ៉ាប់រងអគ្គីភ័យអគារការិយាល័យ។

ធនាគារ មានគោលនយោបាយគ្រប់គ្រងនិរន្តរភាពអាជីវកម្ម (Business Continuity Management) ដើម្បីធានានិរន្តរភាព ប្រតិបត្តិការចម្បងៗរបស់ធនាគារ ក្នុងព្រឹត្តិការណ៍រំខានណាមួយ។ ក្នុងនោះផងដែរ នីតិវិធីគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ ធ្វើតេស្តសាកល្បង និងអនុវត្តជាប្រចាំ ដើម្បីធ្វើឱ្យប្រាកដថាធនាគារមានការរៀបចំរួចរាល់ និងត្រៀមជាស្រេចក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះព្រឹត្តិការណ៍រំខានណាមួយ។

ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យដែលមិនអាចបំពេញកាតព្វកិច្ចទូទាត់របស់ខ្លួនបានដែលពាក់ព័ន្ធទៅនឹងបំណុលហិរញ្ញវត្ថុនៅពេលបំណុលទាំងនោះដល់ពេលកំណត់ត្រូវសង ឬ ត្រូវដាក់ប្រាក់បំពេញវិញនៅពេលប្រាក់ទាំងនោះត្រូវបានដក។ ផលវិបាកនៃហានិភ័យនេះអាចជាការមិនបានបំពេញកាតព្វកិច្ចក្នុងការសងប្រាក់ត្រលប់ជូនអ្នកតម្កល់ប្រាក់ (Depositors) និងមិនអាចបំពេញតាមការសន្យាក្នុងការផ្តល់កម្ចី។

ធនាគារ មានក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យសន្ទនីយភាព ដែលផ្តល់ជាការណែនាំសម្រាប់ការគ្រប់គ្រងហានិភ័យសន្ទនីយភាពដែលក្នុងនោះរួមមាន ការផ្តល់មូលនិធិឱ្យស្របទៅនឹងសកម្មភាពប្រាក់បញ្ញើ ការផ្តល់ឥណទាន និងសកម្មភាពដើមទុន។ ធនាគារ តាមដានសន្ទនីយភាពក្នុងតារាងតុល្យការ គ្រប់គ្រងបណ្តុំ និងប្រវត្តិនៃលំហូរសាច់ប្រាក់ និងធ្វើឱ្យប្រាកដថាធនាគារ មានសន្ទនីយភាពគ្រប់គ្រាន់ និងអនុវត្តតាមអនុបាទ សន្ទនីយភាពដូចដែលបានកំណត់។ ធនាគារ តែងតែធ្វើការត្រួតពិនិត្យ និងរាយការណ៍ពីស្ថានភាពសាច់ប្រាក់ និងលំហូរសាច់ប្រាក់ទាំងស្ថានភាព រយៈពេលខ្លី និងវែង។ បន្ថែមពីនេះ ធនាគារ បានរៀបចំគម្រោងនៃប្រតិបត្តិការនូវការគ្រប់គ្រងសន្ទនីយភាពយថាភាព (Liquidity Contingency Plan) ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលអាចកើនមានឡើងក្នុងករណីធនាគារ អាចនឹងរងនូវផលប៉ះពាល់ពីស្ថានភាពសេដ្ឋកិច្ច និងព្រឹត្តិការណ៍ខាងក្រៅផ្សេងៗទៀត។

ហានិភ័យព័ត៌មានវិទ្យា

ព័ត៌មានវិទ្យា គឺជាផ្នែកគាំទ្រមួយដ៏សំខាន់របស់ធនាគារ លើការអភិវឌ្ឍដំណើរការផ្ទៃក្នុងកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព អភិបាលកិច្ចល្អ ជលិតភាពប្រកបដោយភាពច្នៃប្រឌិត។ គណៈកម្មាធិការគម្រោងព័ត៌មានវិទ្យាបានរៀបចំឡើង ដើម្បីត្រួតពិនិត្យទៅលើគម្រោងព័ត៌មានវិទ្យា និងអភិបាលកិច្ចព័ត៌មានវិទ្យាក្នុងគោលបំណង ដើម្បីធ្វើឱ្យសមស្របតាមយុទ្ធសាស្ត្រព័ត៌មានវិទ្យាជាមួយនឹងអាជីវកម្ម និងធានាថាមានការវិនិយោគលើព័ត៌មានវិទ្យាគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា និងប្រតិបត្តិតាម។

សុវត្ថិភាពនៃព័ត៌មានវិទ្យាត្រូវការយុទ្ធសាស្ត្ររួមបញ្ចូល ដើម្បីយកមកគ្រប់គ្រងវិន័យដំណើរការ និងបច្ចេកវិទ្យា។ សុវត្ថិភាពនៃព័ត៌មានវិទ្យាមានការពង្រឹង និងធ្វើអោយប្រសើរឡើងលើកម្រិតសុវត្ថិភាពព័ត៌មានវិទ្យានៃធនាគារ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ ដំណើរការ និងស្តង់ដាគ្រប់គ្រងរបស់អន្តរជាតិល្អបំផុត។ ធនាគារបានអនុលោមតាម PCI-DSS PCI-PIN Security SWIFTCSP។ បន្ថែមពីលើ

នេះ ធនាគារ ក៏អនុវត្តប្រព័ន្ធសុវត្ថិភាពតាមរយៈ firewalls, DDoS protection, segmented network, end-point anti-virus និងEDR។

សម្រាប់កម្មវិធី និងសុវត្ថិភាពមូលដ្ឋានទិន្នន័យត្រូវបានការាយតម្លៃជារាល់ខែ និង Patch រៀងរាល់សប្តាហ៍ទៅលើប្រព័ន្ធដែលងាយនឹងទទួលរងការវាយប្រហារ។ និយោជិតចូលរួមជាប្រចាំក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពព័ត៌មាន ដែលផ្តោតទៅលើបញ្ហាឯកជនភាព ហានិភ័យនៃការរំលោភបំពានព័ត៌មាន និងភារកិច្ចផ្នែកសន្តិសុខ តាមរយៈកម្មវិធីសិក្សាតាមអេឡិចត្រូនិក ព្រឹត្តិបត្រព័ត៌មាន និងការក្លែងធ្វើការវាយប្រហារតាមអ៊ីនធឺណិត។

ការប្រតិបត្តិតាម

នាយកដ្ឋានប្រតិបត្តិតាម គឺត្រួតពិនិត្យមើលអនុលោមភាព និងផ្សព្វផ្សាយវប្បធម៌អនុលោមភាព តាមរយៈវគ្គបណ្តុះបណ្តាល សម្របសម្រួល ត្រួតពិនិត្យ និងគាំទ្រដល់បុគ្គលិក ដើម្បីធានាបានថាបុគ្គលិកគ្រប់រូបអនុវត្តតាមច្បាប់ប្រទេសកម្ពុជា បានយ៉ាងត្រឹមត្រូវ។ ដើម្បីចៀសវាងទំនាស់ផលប្រយោជន៍ ផ្នែកប្រតិបត្តិតាមត្រូវរាយការណ៍ទៅក្រុមប្រឹក្សាគណៈកម្មការគ្រប់គ្រងហានិភ័យ ដើម្បីធ្វើឱ្យប្រាកដថាគោលនយោបាយប្រតិបត្តិតាមក្របខ័ណ្ឌនៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម(AML/CFT) ដោយរួមបញ្ចូលទាំងគោលនយោបាយវីស្សេលប្លុីង (Whistle Blowing)។ គោលនយោបាយ និងបទប្បញ្ញត្តិទាំងអស់នេះ ត្រូវបានអនុវត្តទៅតាមបទប្បញ្ញត្តិចេញដោយធនាគារជាតិ នៃកម្ពុជា(NBC) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU)។

សកម្មភាពចម្បងៗប្រចាំឆ្នាំ ២០២៥

វប្បធម៌អនុលោមដ៏រឹងមាំ	វប្បធម៌អនុលោមត្រូវបានណែនាំ ដើម្បីធានាបានថាបុគ្គលិកទាំងអស់នៅតែបន្តធ្វើកិច្ចការរៀងខ្លួនប្រកបដោយសីលធម៌ និងគោរពទៅតាមគោលការណ៍ និងនីតិវិធីរបស់ធនាគារ។ ដាក់បញ្ចូលវគ្គបណ្តុះបណ្តាលអនុលោមភាពទៅក្នុងកម្មវិធីបណ្តុះបណ្តាលបុគ្គលិករបស់ធនាគារ ស្ថាបនា និងត្រូវបានតាមដានជាប្រចាំ។
ផ្នែកស្វែងរកសកម្មភាពឆបោក	ផ្នែកស្វែងរកសកម្មភាពឆបោកបានបង្កើនវិសាលភាពនៃវិធីសាស្ត្រតាមដាន និងស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការសម្គាសអតិថិជនឥណទាន ការស្នងមតិអ្នកផ្តត់ផ្គង់ ការចូលរួមស្តាប់បុគ្គលិក ការស្នងមតិបុគ្គលិក និងការប្រកាសពីការក្លែងបន្លំ និងការបន្តកែលម្អដំណើរការស៊ើបអង្កេតការក្លែងបន្លំ។
ការវាយតម្លៃហានិភ័យនៃគម្រោង	គោលបំណងនៃការវាយតម្លៃហានិភ័យ គឺដើម្បីធានាបានថាហានិភ័យទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណដោយមានការត្រួតពិនិត្យត្រឹមត្រូវច្បាស់លាស់ ដើម្បីអាចធ្វើការដាក់ចេញនូវផលិតផល និងសេវាកម្មថ្មីៗបានដោយជោគជ័យ។
ការគ្រប់គ្រង និងការវាយតម្លៃហានិភ័យដោយខ្លួនឯង	ការគ្រប់គ្រង និងការវាយតម្លៃហានិភ័យដោយខ្លួនឯង (RCSA) ត្រូវបានវាយតម្លៃ ដើម្បីធានាបានថាហានិភ័យគ្រប់ទម្រង់ទាំងអស់ត្រូវបញ្ជាក់បានថាអាចគ្រប់គ្រងបានយ៉ាងសមរម្យ។ ក្របខ័ណ្ឌនេះត្រូវបានដាក់ចេញនៅឆ្នាំ២០២៤ ហើយត្រូវបានកែលម្អបន្ថែមដើម្បីធានាបាននូវភាពជាម្ចាស់ការ។
ទិន្នន័យឥណទាន និងការវិភាគទិន្នន័យ	វិភាគយ៉ាងស៊ីជម្រៅក្នុងការគ្រប់គ្រងហានិភ័យផលប័ត្រឥណទាន និងផ្តល់អនុសាសន៍យ៉ាងសកម្មដល់បុគ្គលិកឥណទានដើម្បីចាត់វិធានការដោះស្រាយដើម្បីកែលម្អការប្រមូលប្រាក់កម្ចី និងធានាគុណភាពឥណទាន។
ព្រឹត្តិបត្រគ្រប់គ្រងហានិភ័យ	ព្រឹត្តិបត្រព័ត៌មានគ្រប់គ្រងហានិភ័យត្រូវបានចេញផ្សាយប្រចាំខែ និងចែករំលែកដល់បុគ្គលិក ដើម្បីផ្តល់មេរៀនដែលបានរៀនកន្លងមក និងកែលម្អការគ្រប់គ្រងហានិភ័យប្រតិបត្តិការ។
ផែនការស្តារឡើងវិញ	ផែនការស្តារឡើងវិញ ត្រូវបានអនុវត្តសម្រាប់ប្រព័ន្ធចម្បងៗ និងសម្រេចបានទៅតាមគោលបំណង និងពេលវេលាកំណត់បានដោយជោគជ័យ។
ការធ្វើស្ត្រេសតេស្តនៃសន្ទនីយភាព	ការធ្វើស្ត្រេសតេស្តនៃសន្ទនីយភាពត្រូវបានធ្វើឡើងរៀងរាល់បីខែ និងមួយឆ្នាំម្តង ដើម្បីធានាបាននូវកម្រិតសន្ទនីយភាពសមស្របស្ថានភាពតានតឹង និងស្របតាមគោលការណ៍ណែនាំរបស់និយ័តករ។
ក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃមូលធន	អនុបាតភាពគ្រប់គ្រាន់នៃដើមទុន ត្រូវបានវាយតម្លៃតាមប្រកាសថ្មីពីធនាគារកណ្តាល នៃកម្ពុជា ដើម្បីធានាថាធនាគារ មានដើមទុនគ្រប់គ្រាន់សម្រាប់ធ្វើប្រតិបត្តិការរបស់ធនាគារ នាពេលអនាគត។
គោលនយោបាយកម្រិតហានិភ័យដែលអាចទទួលយកបាន	គោលនយោបាយកម្រិតហានិភ័យដែលអាចទទួលយកបានដ៏ទូលំទូលាយត្រូវបានបង្កើត និងត្រូវបានត្រួតពិនិត្យនូវកម្រិតហានិភ័យនីមួយៗប្រចាំខែ ដើម្បីរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យរបស់ក្រុមប្រឹក្សាភិបាល។
គណៈកម្មាធិការហានិភ័យធនាគារ	កិច្ចប្រជុំត្រូវបានធ្វើឡើងជាទៀងទាត់លើមូលដ្ឋានប្រចាំត្រីមាស ដើម្បីពិភាក្សាអំពីហានិភ័យសំខាន់ៗ។ អ្នកគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។

ការគ្រប់គ្រង និរន្តរភាពបរិស្ថាន និងសង្គម

ធនាគារ ស្ថាបនា គីអិលស៊ី ប្តេជ្ញាចិត្តក្នុងការបញ្ចូល និងយកចិត្តទុកដាក់លើផ្នែកបរិស្ថាន និងសង្គមទៅក្នុងប្រតិបត្តិការអាជីវកម្ម និងដំណើរការសម្រេចចិត្តរបស់ខ្លួន។ របាយការណ៍នេះគូសបញ្ជាក់អំពីគំនិតផ្តួចផ្តើម និងសមិទ្ធផលសំខាន់ៗក្នុងវិស័យនិរន្តរភាពបរិស្ថាន និងទំនួលខុសត្រូវសង្គមសម្រាប់ឆ្នាំ ២០២៥។



បេសកកម្ម

បេសកកម្មរបស់ធនាគារ នោះគឺការចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការឆ្លើយតបទៅនឹងគំនិតផ្តួចផ្តើមជាតិ និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជាស្តីអំពីបរិស្ថាន និងសង្គមរបស់សមាគមធនាគារនៅកម្ពុជា។ គោលការណ៍ទាំងនេះអាចជួយឱ្យធនាគារ កាត់បន្ថយហានិភ័យនៃការវិនិយោគ និងស្វែងរកឱកាសអាជីវកម្មថ្មីៗ និងអាចថែរក្សាបរិស្ថាន សម្បត្តិបេតិកភណ្ឌ និងការគាំទ្រដល់សហគមន៍ផងដែរ។

សសរស្តម្ភនៃនិរន្តរភាព

បរិស្ថាន
យើងប្តេជ្ញាកាត់បន្ថយផលប៉ះពាល់បរិស្ថានរបស់យើង និងដោះស្រាយការប្រែប្រួលអាកាសធាតុ។ យើងតម្រឹមគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់យើង ជាមួយនឹងគោលដៅអតិថិជនរបស់យើង។

សង្គម
យើងលើកកម្ពស់ភាពចម្រុះ សមធម៌ និងវប្បធម៌បរិយាប័ន្ន ដោយគោរពបុគ្គលម្នាក់ៗនៅក្នុងសហគមន៍ បុគ្គលិក និងអតិថិជនរបស់យើង។

អភិបាលកិច្ច
យើងដើរតួជាដៃគូដែលមានទំនួលខុសត្រូវ ក្នុងការបង្កើតគុណតម្លៃរយៈពេលវែងសម្រាប់ភាគីពាក់ព័ន្ធរបស់យើង ដោយធានាបាននូវការប្រព្រឹត្តដោយយុត្តិធម៌ក្នុងគ្រប់សកម្មភាពអាជីវកម្មទាំងអស់ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សកម្មភាពនិរន្តរភាព

- បានគ្រប់គ្រងផលប៉ះពាល់លើការប្រើប្រាស់ថាមពល និងការប្រើប្រាស់ក្រដាស។
- បានបញ្ចូលកត្តា ESG ទៅក្នុងដំណើរការអាជីវកម្មរបស់យើង។
- បានផ្តល់បរិយាប័ន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សហគមន៍។
- បានគោរពក្រមសីលធម៌ស្តីពីគោលការណ៍ណែនាំនៃការផ្តល់ប្រាក់កម្ចី។
- បានគោរពសិទ្ធិមនុស្ស ភាពចម្រុះ និងសមភាពយេនឌ័រ។
- បានអនុវត្តទៅលើគោលការណ៍មិនអត់ឱនចំពោះការក្លែងបន្លំ និងអំពើពុករលួយ
- បានចៀសវាងសកម្មភាពដែលនាំប៉ះពាល់ដល់សង្គម និងការរំលោភបំពានបទប្បញ្ញត្តិ។
- បានប្រកាន់ខ្ជាប់នូវចនាសម្ព័ន្ធអភិបាលកិច្ចល្អបំផុតនៅក្នុងប្រតិបត្តិការអាជីវកម្ម។
- បានផ្តល់នូវកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងអនាម័យ។



៩ គោលការណ៍ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព

១. ធ្វើការវាយតម្លៃ និងគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុ ការបំពុល សំណល់ និងការការពារ ធនធានធម្មជាតិដែលជួបគ្រោះធ្ងន់ធ្ងរ។

២. យើងនឹងធ្វើការវាយតម្លៃ និងគ្រប់គ្រងហានិភ័យដែលអាចប៉ះពាល់ជាអវិជ្ជមានទៅលើមនុស្ស ជាពិសេសសហគមន៍ក្នុងស្រុក កម្មករ និងប្រជាជនតាគតិច។

៣. យើងនឹងធ្វើការវាយតម្លៃ និងគ្រប់គ្រងហានិភ័យដែលអាចប៉ះពាល់ជាអវិជ្ជមានទៅលើផ្នែកខ្លះនៃបេតិកភណ្ឌវប្បធម៌រួមមាន៖ ភាសា វប្បធម៌ ប្រពៃណី និងបូជនីយដ្ឋានយើង។

៤. យើងនឹងបន្ថែមការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងអក្ខរកម្មរបស់ប្រជាជនកម្ពុជា ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រក្នុងការការពារអតិថិជនយើង។

៥. យើងនឹងពង្រីកដែនវិសាលភាពដល់អ្នកដែលមិនអាច ឬ អាចចូលទៅប្រើវិស័យធនាគារផ្លូវការដោយមានដែនកំណត់ ក៏ដូចជាផ្តល់នូវដំណោះស្រាយប្រសើរជាងមុន ដើម្បីកែសម្រួលដល់ការចូលប្រើសេវាធនាគារ និងកម្រិតសេវាកម្ម។

៦. យើងនឹងផ្តល់ហិរញ្ញប្បទានដល់ការកែប្រែថ្មី ដើម្បីបង្កើតនូវប្រសិទ្ធភាព និងការកែតម្រូវថ្មីទៅលើការរស់នៅ វិស័យបុរាណ និងសកម្មភាពអាជីវកម្ម ព្រមទាំងការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចបៃតងថ្មី។

៧. យើងនឹងស្វះស្វែងកសាងសមត្ថភាពនៅទូទាំងធនាគារ ដើម្បីផ្តល់នូវការប្តេជ្ញាចិត្ត និងលើកកម្ពស់ការយល់ដឹងរបស់អតិថិជន និងសហគមន៍របស់យើងអំពីនិរន្តរភាពហិរញ្ញវត្ថុ។

៨. យើងនឹងគ្រប់គ្រងដានអនុវត្តបរិស្ថាន និងសង្គមយើងដោយផ្ទាល់ និងស្នើសុំនូវស្តង់ដាស្រដៀងគ្នាពីអ្នកផ្គត់ផ្គង់របស់យើង។

៩. ជារៀងរាល់ឆ្នាំ យើងនឹងរាយការណ៍ពីដំណើរការរបស់ធនាគារ និងវិស័យទាំងមូល ដោយផ្សៀងផ្គាត់នឹងការប្តេជ្ញា ដើម្បីទទួលខុសត្រូវ និងចែករំលែកពីលទ្ធផលនៃដំណើរប្រតិបត្តិការ។

គោលការណ៍ក្នុងការអនុវត្ត

ការការពារបរិស្ថាន មនុស្ស និងបេតិកភណ្ឌវប្បធម៌



ធនាគារ មានគោលការណ៍ឥណទាន ដើម្បីគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងការផ្តល់កម្ចី។ គោលការណ៍នេះត្រូវបានបំពេញបន្ថែមដោយគោលការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម ដែលកំណត់នូវដំណើរការប្រព្រឹត្តទៅនៃប្រតិបត្តិការបទដ្ឋាន និងហាមឃាត់ (បញ្ជីដកចេញ) ដើម្បីផ្តល់នូវការលំណែនាំប្រសើរដើម្បីកំណត់ និងប៉ាន់ប្រមាណហានិភ័យបរិស្ថាន និងសង្គមដែលជាផ្នែកមួយនៃដំណើរការវាយតម្លៃឥណទាន។

ការផ្តល់ហិរញ្ញប្បទានសម្រាប់អនាគតនៃប្រទេសកម្ពុជា



យើងបានបង្កើតកម្មវិធីហិរញ្ញវត្ថុដើម្បីបង្កើនការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងពង្រីកវិសាលភាពទៅដល់អ្នកដែលមិនអាច ឬ មានដៃនកំណត់ក្នុងការចូលទៅប្រើវិស័យធនាគារផ្លូវការ។ កម្មវិធីទាំងនេះផ្តល់នូវប្រភពហិរញ្ញប្បទានសម្រាប់ប្រតិបត្តិការអាជីវកម្ម ធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង បង្កើតការងារ និងជំរុញសេដ្ឋកិច្ច។

យើងមានការប្តេជ្ញាចិត្តក្នុងការផ្តល់ប្រាក់កម្ចីដល់ស្ត្រី និងតំបន់ជនបទដែលឆ្ងុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់យើងក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុដល់សហគមន៍ដែលនៅជាប់ស្រយាល។ តាមរយៈការផ្តល់នូវការប្រើប្រាស់សេវាហិរញ្ញវត្ថុ យើងមានគោលបំណងគាំទ្រសហគ្រិនស្ត្រី និងប្រជាជននៅតាមជនបទ ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពរបស់ប្រជាជន។ វិធីសាស្ត្រនេះស្របតាមបេសកកម្មរបស់យើងក្នុងការបង្កើនលទ្ធភាពទទួលបានសេវាធនាគារធ្វើឱ្យប្រសើរឡើង និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

កំណើននៃការផ្តល់ហិរញ្ញប្បទាន			
បរិយាយ	២០២៣	២០២៤	២០២៥
ឥណទានផ្តល់ជូនអតិថិជនជាស្ត្រី %	៤៧%	៤៦%	៤៥%
ឥណទានផ្តល់ជូនប្រជាជននៅទីប្រជុំជន %	៣០%	៣៣%	៣៤%
ឥណទានផ្តល់ជូនប្រជាជននៅតំបន់ជនបទ %	៧០%	៦៧%	៦៦%

កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការលើកកម្ពស់ការសន្សំបានបង្ហាញពីភាពជោគជ័យជាពិសេសការផ្តោតសំខាន់ទៅលើអតិថិជនជាស្ត្រី។ តាមរយៈការបង្កើនការគាំទ្រ និងធនធានដែលផ្តោតលើស្ត្រី យើងបានឃើញនិន្នាការវិជ្ជមាននៅក្នុងចំនួនអ្នកដាក់ប្រាក់សរុប។

ការលើកទឹកចិត្តដល់ការសន្សំ (ចំនួនអតិថិជនប្រាក់បញ្ញើ គិតជាពាន់នាក់)			
បរិយាយ	២០២៣	២០២៤	២០២៥
អតិថិជនប្រាក់បញ្ញើសរុប	៦០៥	៥១៤	៥៨០
អតិថិជនប្រាក់បញ្ញើជាស្ត្រី	២៩៩	២៥៤	២៩៣

ការការពារអតិថិជន

ការការពារអតិថិជនគឺជាគុណតម្លៃស្នូលដ៏សំខាន់ក្នុងការគាំទ្ររាល់ប្រតិបត្តិការរបស់យើង។ យើងប្តេជ្ញាចិត្តដើម្បីជានាបានថាអតិថិជនរបស់យើងត្រូវតែទទួលបាននូវសេវាហិរញ្ញវត្ថុប្រកបដោយយុត្តិធម៌ តម្លាភាព និងទទួលបានផលិតផលហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព។ គោលនយោបាយរបស់យើងត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់ដើម្បីការពារសិទ្ធិ របស់អតិថិជន និងលើកកម្ពស់ទំនាក់ទំនងដ៏រឹងមាំប្រកបដោយទំនុកចិត្ត រវាងធនាគារ និងអតិថិជន។ យើងផ្តោតសំខាន់លើការអនុវត្តការងារ ប្រកបដោយក្រមសីលធម៌ ការការពារឯកជនភាព និងគំនិតផ្តួចផ្តើមចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់អំណាចគាំទ្រអតិថិជនឱ្យទទួលបាន ព័ត៌មានគ្រប់គ្រាន់ដែលពួកគាត់គួរទទួលបាន។ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិករបស់យើងជាបន្តបន្ទាប់ និងការប្រកាន់ខ្ជាប់នូវការអនុវត្តល្អបំផុតក្នុងឧស្សាហកម្ម យើងខិតខំបង្កើតបរិយាកាសសុវត្ថិភាព មានទំនួលខុសត្រូវខ្ពស់ និងពោរពេញដោយការគាំទ្រជូនដល់អតិថិជនទាំងអស់របស់យើង។

យើងមានមោទកភាពដែលបានទទួលវិញ្ញាបនបត្រពី M-Cril នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥។ បន្ទាប់ពីការវាយតម្លៃយ៉ាងតឹងរ៉ឹង ធនាគារ ស្ថាបនាទទួលបានពិន្ទុ ៩៦.៦% លើគ្រប់ផ្នែកទាំងអស់។ M-Cril ជាស្ថាប័នដ៏ល្បីល្បាញដែលត្រូវបានគេស្គាល់ដោយសារស្តង់ដារដ៏តឹងរ៉ឹងក្នុងការផ្តល់ចំណាត់ថ្នាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ វិញ្ញាបនបត្រនេះគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការរក្សាឧត្តមភាពលើការផ្តល់សេវាប្រកបដោយតម្លាភាព ការការពារអតិថិជន និងសមិទ្ធផលហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ។ ជាមួយនឹងការទទួលស្គាល់នេះ អតិថិជនរបស់យើងអាចមានទំនុកចិត្តថាពួកគេកំពុងសហការជាមួយស្ថាប័នដែលអាចទុកចិត្តបានដែលជួយដល់សុខុមាលភាពហិរញ្ញវត្ថុរបស់ពួកគេ។


M-CRIL
inclusive microeconomics

CLIENT PROTECTION CERTIFICATION

issued to

Sathapana Bank Plc

Sathapana Tower, Preah Norodom Blvd., Corner Street N 172 and Street N 174
Phum 14, Sangkat Phsar Thmei Ti Bei, Khan Doun Penh, Phnom Penh, Cambodia

Sathapana Bank Plc has been awarded the Gold Level Certification aligned with the CERISE+SPTF CP Certification Framework

Certified by M-CRIL Limited
Level of compliance: Gold
Issue date: 15 March 2025
Valid till : 12 March 2028

Sudhir Narayan
CEO, M-CRIL

Disclaimer

ការងារ និងការបណ្តុះបណ្តាល

យើងផ្តល់ឱកាសការងារស្មើៗគ្នា ដោយផ្តោតលើភាពយុត្តិធម៌ តម្លាភាព និងការមិនមានជម្លោះផលប្រយោជន៍ក្នុងប្រាក់បំណាច់ និងអត្ថប្រយោជន៍។ យើងលើកទឹកចិត្ត និងជំរុញបុគ្គលិកឱ្យបង្កើនសមត្ថភាពតាមរយៈចំណេះដឹង ជំនាញ និងបទពិសោធ។ យើងក៏ផ្តល់កម្មវិធីហ្វឹកហាត់ការងារសម្រាប់សិស្សានុសិស្ស ដើម្បីឱ្យពួកគេយល់ដឹងអំពីសេវាហិរញ្ញវត្ថុក្នុងវិស័យធនាគារផងដែរ។

ការងារ			
បរិយាយ	២០២៣	២០២៤	២០២៥
បុគ្គលិកស្ត្រី	៣៩%	៣៩%	៣៦%
បុគ្គលិកបុរស	៦១%	៦១%	៦៤%
បុគ្គលិកសរុប	៤.៦០៨	៤.២៣៩	៣.៤៦៤
អ្នកហាត់ការងារ	១,២%	១,១%	១,៧%

ការផ្តល់ហិរញ្ញប្បទាន			
បរិយាយ	២០២៣	២០២៤	២០២៥
វគ្គបណ្តុះបណ្តាល Refresher	៣.៦៩៩	៣.៩០៧	៣.៣៨០
វគ្គបណ្តុះបណ្តាលណែនាំ	១.១៩៥	៥៨៧	៩០២

ការប្រើប្រាស់ថាមពល ទឹក និងក្រដាស

យើងបន្តការអនុវត្តការផ្តួចផ្តើមក្នុងការគ្រប់គ្រងការវាយតម្លៃលើការប្រើប្រាស់ថាមពល និងក្រដាស។ ធនាគារ បានណែនាំផ្លេតហ្វមឌីជីថលដើម្បីជំនួសការប្រើប្រាស់ក្រដាស ហើយកិច្ចប្រជុំ/ការបណ្តុះបណ្តាលភាគច្រើន ត្រូវបានធ្វើឡើងតាមរយៈអនឡាញ។

ការប្រើប្រាស់ថាមពល ទឹក និងក្រដាសអនាម័យ			
បរិយាយ	២០២៣	២០២៤	២០២៥
ថាមពល គីឡូវ៉ាត់ ម៉ោង/FTE	១.៥៤០	១.៤៦៩	២.៩៤២
សាំង លីត្រ/FTE	៥៧	៦២	៧៣
ទឹក ម៉ែត្រគីប/FTE	២៦	២៧	៥៤
ក្រដាស គីឡូ/FTE	៥	៣	៣

ការងារទំនួលខុសត្រូវសង្គម

ឧបត្ថម្ភអំឡុងពេលមានបញ្ហាព្រំដែន

ធនាគារ ស្ថាបនា បាននាំយកអំណោយជាគ្រឿងឧបភោគបរិភោគ ថ្នាំសង្កូវ និងសម្ភារៈប្រើប្រាស់ចាំបាច់ជូនបងប្អូនភៀសសឹកជាច្រើនគ្រួសារ ក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ សៀមរាប និងបាត់ដំបង។









កម្មវិធីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រៈពេល ៤ឆ្នាំ

ធនាគារ ស្ថាបនា បានផ្តល់ជូនអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រៈពេល ៤ឆ្នាំ ពេញ ជូនដល់សិស្សចំនួន ៥រូប ដែលមានទេពកោសល្យ និងកំពុងស្ថិតក្នុងជីវភាពលំបាក ដើម្បីឱ្យពួកគេអាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្រដោយមិនមានការព្រួយបារម្ភពីការចំណាយផ្នែកហិរញ្ញវត្ថុ ព្រោះយើងជឿជាក់យ៉ាងមុតមាំថាយុវជនជាសសរទ្រូង និងរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ។

តន្ត្រីសប្បុរសធម៌ Musica Felice

ធនាគារ ស្ថាបនា បានបរិច្ចាគប្រាក់ចំនួន ៥០០ដុល្លារអាមេរិកជូនតន្ត្រីសប្បុរសធម៌ Musica Felice ដើម្បីចូលរួមជួយគាំទ្រ និងផ្តល់ឱកាសដល់តន្ត្រីករវ័យក្មេងដែលមានទេពកោសល្យឱ្យទទួលបានការបណ្តុះបណ្តាលផ្នែកសិល្បៈ។





បរិច្ចាគថវិកាជូនកាកបាទក្រហមកម្ពុជា

ធនាគារ ស្ថាបនា បានបរិច្ចាគប្រាក់ជូនកាកបាទក្រហមកម្ពុជាចំនួន ២០ លានរៀល ដើម្បីគាំទ្រសកម្មភាពមនុស្សធម៌ក្នុងការគាំទ្រដល់សហគមន៍ និងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

បរិច្ចាគឈាម

ធនាគារ ស្ថាបនា បានសហការជាមួយក្រុមហ៊ុន CBRE Cambodia អគារ ស្ថាបនា និងមជ្ឈមណ្ឌលជាតិផ្គត់ឈាម ក្នុងការរៀបចំកម្មវិធីបរិច្ចាគឈាម ដើម្បីរួមគ្នាសង្គ្រោះជីវិត លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការបរិច្ចាគឈាម និងលើកទឹកចិត្តបុគ្គលិកក្នុងការចូលរួមសកម្មភាពមនុស្សធម៌ក្នុងសង្គម។







បរិច្ចាគកុំព្យូទ័រជូនវិទ្យាល័យអង្គរ

ធនាគារ ស្ថាបនា បានប្រគល់កុំព្យូទ័រចំនួន ៥០គ្រឿង ជាមួយនឹងសម្ភារៈសិក្សាមួយចំនួនជូនដល់វិទ្យាល័យអង្គរ។ គំនិតផ្តួចផ្តើមមួយនេះ ជួយគាំទ្រវិស័យអប់រំនៅក្នុងសហគមន៍ លើកកម្ពស់ចំណេះដឹងផ្នែកឌីជីថល និងផ្តល់ចំណេះដឹងហិរញ្ញវត្ថុដល់សិស្សានុសិស្ស។







ឧបត្ថម្ភកម្មវិធី យុវជនឆ្ពោះទៅរកអាជីវកម្ម

ធនាគារ ស្ថាបនា បានឧបត្ថម្ភកម្មវិធី យុវជនឆ្ពោះទៅរកអាជីវកម្ម ដែលជាកម្មវិធីលើកកម្ពស់សហគ្រិនវ័យក្មេងដែលមានភាពច្នៃប្រឌិត។





ពានរង្វាន់ដ៏មានកិត្យានុភាព

សម្រាប់នវានុវត្តន៍ធនាគារឌីជីថល

SATHAPANA MOBILE

កម្មវិធីធនាគារចល័តដែលមានភាពច្នៃប្រឌិត
នៅកម្ពុជាឆ្នាំ ២០២៥

ពានរង្វាន់ដ៏មានកិត្យានុភាព







ពានរង្វាន់ភាពជាអ្នកដឹកនាំពីក្រុមហ៊ុន Visa



ពានរង្វាន់ស្ថាប័នហិរញ្ញវត្ថុចូលរួមល្អឥតខ្ចោះ
ពីសាជីវកម្មជានាឥណទានកម្ពុជា



វិញ្ញាបនបត្រស្តង់ដា
សុវត្ថិភាពទិន្នន័យ
ឧស្សាហកម្មប័ណ្ណទូទាត់

អំណរគុណ៖ ឧបត្ថម្ភសមាគម
ធនាគារនៅកម្ពុជា លើកម្មវិធី
«ទិវាសុវត្ថិភាពឌីជីថល»

របាយការណ៍
ហិរញ្ញវត្ថុសវនកម្ម

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស្ថាបនា តីអិលស៊ី (ហៅកាត់ថា "ធនាគារ") សូមបង្ហាញនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។

អំពីធនាគារ

ស្ថាបនា លីមីតធីត ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ("MFI") ត្រូវបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងពាណិជ្ជកម្ម ("MoC") នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៣ តាមអនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ រវាងស្ថាបនាសហគមន៍កម្ពុជា (CCB) ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលបានបង្កើតឡើងនៅក្នុង ឆ្នាំ១៩៩៦ និងបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាបណ្ណដើម្បីធ្វើប្រតិបត្តិការជា មីក្រូហិរញ្ញវត្ថុពី ធនាគារជាតិ នៃកម្ពុជា ("NBC") នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ហើយចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ទទួលបានអាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍។ ដោយស្ថិតនៅក្រោមអាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានត្រូវបានអនុញ្ញាតឱ្យផ្តល់ឥណទាន និងសេវាផ្តល់ប្រាក់សន្សំដល់ក្រុមគ្រួសារក្រីក្រ និងមានចំណូលទាប និងអង្គភាពធុនតូច ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃកម្ពុជា ដើម្បីផ្តល់សេវាកម្មទទួលប្រាក់បញ្ញើ។ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាបណ្ណរយៈពេល ៣ឆ្នាំបន្តទៀត ដើម្បីផ្តល់សេវាកម្មប្តូរប្រាក់។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ធនាគារ ម៉ារ៉ូហាន់ ជប៉ុន តីអិលស៊ី ("MJB") បានចុះកិច្ចសន្យាទិញលក់ជាមួយ Stichting Triodos-Doen Nederlandse Financierings-Maatschapij Voor Ontwikellingslanden N.V. DWM Funds S.C.A – SICAV SIF CCB និង Sathapana Employee Investment Limited ដើម្បីទិញភាគហ៊ុនចំនួន ៩៥,១% ពីស្ថាបនា លីមីតធីត។ ការទិញហ៊ុននេះត្រូវបានអនុម័តដោយធនាគារជាតិ នៃកម្ពុជា នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ ហើយក្រសួងពាណិជ្ជកម្ម បានអនុម័តទៅលើការប្តូរកម្មសិទ្ធិ នៃដើមទុននាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន អនុលោមតាមកិច្ចព្រមព្រៀងជាមួយ CCB បានអនុម័តសេចក្តីសម្រេចមួយ ដើម្បីអនុម័តលើការលក់ភាគហ៊ុន ដែលនៅសល់ចំនួន ៤,៩% របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទៅឱ្យ MJB ដែលតំណាងឱ្យភាគកម្មមិនគ្រប់គ្រងទាំងអស់របស់គ្រឹះស្ថាន ក្នុងតម្លៃសរុប ៦,០២ លានដុល្លារអាមេរិក។ ប្រតិបត្តិការនេះ ត្រូវបានបញ្ចប់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

នៅដើមឆ្នាំ២០១៥ ធនាគារ ម៉ារ៉ូហាន់ ជប៉ុន តីអិលស៊ី និងស្ថាបនា លីមីតធីត បានយល់ព្រមធ្វើការរួមបញ្ចូលគ្នានូវគ្រឹះស្ថានទាំងពីរ ទៅជាគ្រឹះស្ថានតែមួយ ដោយមានឈ្មោះថ្មីជាធនាគារ ស្ថាបនា តីអិលស៊ី ហើយទទួលបានការអនុម័តជាផ្លូវការពី NBC នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ធនាគារជាតិ នៃ កម្ពុជា បានផ្តល់អាជ្ញាបណ្ណធនាគារអចិន្ត្រៃយ៍ ដល់ធនាគារ ស្ថាបនា តីអិលស៊ី។ រាល់ទ្រព្យសកម្ម និងបំណុលទាំងអស់របស់ MJB បានផ្ទេរទៅឱ្យធនាគារ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

ធនាគារធ្វើប្រតិបត្តិការរបស់ខ្លួនតាមបណ្តាខេត្តទាំង ២៥ ដែលមានបណ្តាញសាខាចំនួន ១៧៥ សាខា។

សកម្មភាពអាជីវកម្មចម្រុង

ធនាគារ មានសកម្មភាពអាជីវកម្មចម្រុង ក្នុងការធ្វើប្រតិបត្តិលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីតាំង

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារ ស្ថាបនា លេខ ៦៣ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧២ និងផ្លូវលេខ១៧៤ ភូមិ១៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារធ្វើប្រតិបត្តិការរបស់ខ្លួនតាមបណ្តាខេត្តទាំង ២៥ ដែលមានបណ្តាញសាខាចំនួន ១៧៥ សាខា។

និយោជិត

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ធនាគារមាននិយោជិតចំនួន ៣.៤៦៤ នាក់ (ឆ្នាំ២០២៤៖ ៤.២៣៩ នាក់)។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

ដើមទុនដែលបានបង់

ដើមទុនដែលបានបង់របស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានចំនួន ២៩៥.០០០.០០០ ដុល្លារអាមេរិក (ឆ្នាំ២០២៤៖ ២៩០.០០០.០០០ ដុល្លារអាមេរិក)។

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធនជាសារវន្តក្នុងអំឡុងការិយបរិច្ឆេទ ក្រៅពីអ្វីដែលបានទទួលស្គាល់ និងលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

ការខាតបង់ឥណទានរំពឹងទុកលើឥណទានទៅអតិថិជន និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ដែលបានវាស់វែងតាមថ្លៃដើមរំលស់

មុនពេលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការសមស្របដើម្បីធានាថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចេញពីបញ្ជី ឬការទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកនោះ ហើយក្រុមប្រឹក្សាភិបាល ជឿជាក់ថា រាល់ឥណទានអាក្រក់ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ដែលបានវាស់វែងតាមថ្លៃដើមរំលស់ ត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ការខាតបង់ឥណទានរំពឹងទុក ឬការអនុញ្ញាតសម្រាប់ការបាត់បង់ឥណទានដែលរំពឹងទុក។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួនទឹកប្រាក់នៃការលុបចេញពីបញ្ជី ឬ សំវិធានធនលើការខាតបង់ឥណទានរំពឹងទុកនៃឥណទានទៅអតិថិជន និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ដែលបានវាស់វែងតាមថ្លៃដើមរំលស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីធានាថា រាល់ទ្រព្យសកម្មទាំងឡាយណា ដែលទំនងជាមិនអាចទទួលស្គាល់នៅក្នុងដំណើរការអាជីវកម្មធម្មតាតាមតម្លៃរបស់ទ្រព្យសកម្មទាំងនោះ ដូចដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងថានឹងអាចប្រមូលបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចនឹងបណ្តាលឱ្យមានផលប៉ះពាល់ ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលនាំឱ្យមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

វិធីសាស្ត្រនៃការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងបណ្តាលឱ្យប៉ះពាល់ដល់ការអនុវត្តនៃវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមាន ភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

បំណុលយថាភាព និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖
(ក) ពុំមានបន្ទុកលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ក្នុងការធានាលើបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(ខ) ពុំមានបំណុលយថាភាពណាមួយរបស់ធនាគារ ដែលកើតមានចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញ ក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងមាន ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាព របស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅពេលដល់កាលកំណត់សងនោះទេ។

ព្រឹត្តិការណ៍បន្តបន្ទាប់

ពុំមានព្រឹត្តិការណ៍សំខាន់ៗណាបានកើតឡើងបន្ទាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៥ ដែលតម្រូវឱ្យមានការធ្វើ និយ័តកម្ម ឬការលាតត្រដាង ក្រៅពីអ្វីដែលបានទទួលស្គាល់ និងលាតត្រដាងក្នុងកំណត់សម្គាល់ នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយនេះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានឈ្មោះដូចខាងក្រោម៖

បណ្ឌិត Han Chang-Woo	ប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ)
លោក Han Ken	អនុប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ)
ឯកឧត្តម Shinohara Katsuhiro	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
ឯកឧត្តម គឹម វ៉ាដា	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Williams John Gerard	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Hosoi Takehito	អភិបាលមិនប្រតិបត្តិ (លាលែងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥)
លោក Hiramatsu Naoya	អភិបាលមិនប្រតិបត្តិ
លោក Kawahara Yoshiki	អភិបាលមិនប្រតិបត្តិ (លាលែងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥)
លោក Matsuyama Hirohisa	អភិបាលមិនប្រតិបត្តិ (តែងតាំងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥)

សវនកម្ម

ក្រុមហ៊ុន អឺនស្ត៍ អែន យ៉ុង (ខេមបូឌា) គឺជាសវនករបស់ក្រុមហ៊ុន។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់អភិបាលឱ្យទទួលបាននូវអត្ថប្រយោជន៍តាមរយៈការទិញយកភាគហ៊ុន ឬទិញសញ្ញាប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃទេ។

ក្រុមប្រឹក្សាភិបាលមិនបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងអភិបាល ឬក៏ជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិក ឬជាមួយក្រុមហ៊ុនដែលអភិបាល មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុនោះទេ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវពី ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយគណៈគ្រប់គ្រងដែលត្រូវបានតម្រូវឱ្យ៖

១) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដែលត្រូវបានគាំទ្រដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព
២) អនុលោមតាម CIFRSs ឬប្រសិនបើមានការប្រាសចាកណាមួយសម្រាប់គោលបំណងនៃការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ការប្រាសចាកនេះ ត្រូវបានលាតត្រដាង បកស្រាយ និងកំណត់ចំនួន ទឹកប្រាក់ឱ្យបានសមរម្យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ
៣) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព
៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ធនាគារនឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង
៥) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព នូវរាល់សេចក្តីសម្រេចជាសារវន្តទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថារាល់ការសម្រេចទាំងនេះ ត្រូវបានឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ក្នុងការធានាថា បញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារឱ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានអនុវត្ត។ គណៈគ្រប់គ្រងក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ និងស្វែងរកការបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាល សូមបញ្ជាក់ថា ធនាគារបានអនុលោមតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ តំណាងឱ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលមានភ្ជាប់ជាមួយនេះថា បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាម CIFRSs។

តំណាងឱ្យក្រុមប្រឹក្សាភិបាល៖

ធនាគារ ស្ថាបនា ភីអិលស៊ី
SATHAPANA BANK PLC.

លោក Yoshiharu Morimoto
អនុប្រធាននាយកប្រតិបត្តិ

លោក មិន សុភ័ក្ត្រ
ប្រធាននាយកប្រតិបត្តិ ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះ៖ ក្រុមប្រឹក្សាភិបាល និងភាគទុនិករបស់ ធនាគារ ស្ថាបនា ភីអិលស៊ី

មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ស្ថាបនា ភីអិលស៊ី (“ធនាគារ”) ដែលមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយនិងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ លើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (“CIFRSs”)។

មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា (”CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំយោងតាមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងតាមប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលសមស្របចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាសដែលទទួលខុសត្រូវជាសាធារណៈ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា ជាមួយតម្រូវការផ្នែកសីលធម៌ដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាសដែលទទួលខុសត្រូវជាសាធារណៈ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌របស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

ព័ត៌មានផ្សេងទៀតក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងទៀត រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងថានឹងមានសម្រាប់យើងខ្ញុំ បន្ទាប់ពីកាលបរិច្ឆេទនេះ។
គណៈគ្រប់គ្រងមានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងទៀតនេះ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងទៀតនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានបែបធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងទៀតនេះដែរ។ ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងទៀតនេះ ហើយពិចារណាថា តើព័ត៌មានផ្សេងទៀតនេះ មានភាពខុសគ្នាជាសារវន្ត ឬទេជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាន ពីការងារសវនកម្ម ឬ ថាតើព័ត៌មានផ្សេងទៀតនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំ សន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងទៀតនេះ ដោយផ្អែកលើការងារ ដែលបានអនុវត្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងទៀតនេះទេ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRSs ហើយនិងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រង គិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ធនាគារ និងធ្វើការលាតត្រដាង ប្រសិនបើមាន នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យរបស់ធនាគារ លើកលែងតែក្នុងករណីគណៈ គ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការធនាគារ ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ចមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោម តាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្ត ដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចត្រូវបានរំពឹងទុកដោយសមហេតុផលថា មានឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្ម ដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សារនូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានកម្រិតខ្ពស់ជាងហានិភ័យ ដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការយុបយិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាល:ទេស: ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណ:គ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យ ដោយគណ:គ្រប់គ្រង និងតាមរយ:ភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានថាតើមានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្ត ទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌទាំងឡាយណាដែលនាំឱ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឱ្យទាញចំណាប់អារម្មណ៍ ក្នុងរបាយការណ៍សវនការលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណ:គ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត ក៏អាចបង្កឱ្យធនាគារមិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរ នូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

Emmanuel A. Guelas
Partner

អឺនស្ទ៍ អើន យ៉ាង (ខេមបូឌា)
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនការប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៣	៨៧.៤៦៦.៤៧១	៣៥១.០០២.៩៤៨	១៨៧.៦៨០.៨៨៦	៥៩៤.៤១៥.៥៦៦
សមតុល្យនៅធនាគារជាតិ នៃកម្ពុជា	៤	៤៨៦.៣០៦.៧៥០	១.៩៥១.៥៤៨.៩៨៩	៤១៧.២២០.៧៧៨	១.៦៧៩.៣១៣.៦៣២
សមតុល្យនៅធនាគារផ្សេងៗ	៥	៨៤.១៣៧.១៤១	១៧៧.១២២.៣៤៧	៨១.៩០២.៦៨៦	៣២៩.៦៥៨.៣១១
ឥណទានទៅអតិថិជន	៦	២.០៤៣.០០៨.២៥៤	៨.១៩៨.៥៩២.១២៣	២.០០៩.៤៥៨.៣៥៤	៨.០៨៨.០៦៩.៨៧៥
ការវិនិយោគផ្សេងៗ	៧	១០.០៧៧.៩៦៨	៤០.៤៤២.៨៨៧	១០.០៤៨.២០១	៤០.៤៤៤.០១០
ទ្រព្យសកម្មផ្សេងៗ	៨	២១.៣៨០.៥៤៣	៨៥.៨០០.១១៨	២២.៩៨៤.៨៧១	៩២.៥១៤.១០៥
ទ្រព្យសម្រាប់លក់	៩	១៦.៣០៨.១១៩	៦៥.៤៤៤.៤៨២	-	-
ទ្រព្យ និងបរិក្ខារ	១០	១៥.៥១៥.៩៧១	៦២.២៦៥.៥៩២	២១.២១២.៩២៦	៨៥.៣៨២.០២៧
សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម	១១	២៨.១៥៥.៤១៦	១១២.៩៨៧.៦៨៤	៣២.៧៨៤.៦៤៥	១៣១.៩៥៨.១៩៦
ថ្លៃដើមកម្មវិធីកុំព្យូទ័រ	១២	៩.៧៧២.២៧៦	៣៩.២១៦.១៤៤	១០.៦៣៤.១២៤	៤២.៨០២.៣៤៩
មូលនិធិពាណិជ្ជកម្ម	១៣	១៧.៣៨០.០៣០	៦៩.៧៤៦.០៦០	១៧.៣៨០.០៣០	៦៩.៩៥៤.៦២១
ទ្រព្យសកម្មសរុប		២.៧៧៩.៥០៨.៩៣៩	១១.១៥៤.១៦៩.៣៧៤	២.៧៧១.៣០៧.៥០១	១១.១៥៤.៥១២.៦៩២
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១៤	១.៩៧៣.៦១២.៤៤៣	៧.៩២០.១០៦.៧៣៤	១.៩១៦.០៤២.៦៤០	៧.៧១២.០៧១.៦២៦
ប្រាក់កម្ចី	១៥	១៨៤.៨៤៤.៤៣១	៧៤១.៧៨០.៧០២	១៨៣.៦៩៩.៤៤៣	៧៣៩.៣៩០.២៥៨
អនុបំណុល	១៦	៩៤.៧៨៣.៨០៣	៣៨០.៣៦៧.៤០១	១០៥.៥៥០.០០០	៤២៤.៨៣៨.៧៥០
បំណុលផ្សេងៗ	១៧	៤១.៦២៨.៤០១	១៦៧.០៥៤.៧៧៤	៦០.១២៨.៩២៨	២៤២.០១៨.៩៣៥
អត្ថប្រយោជន៍និយោជិត	១៨	១.១៣៥.១៧៦	៤.៥៥៥.៤៦១	៣០.៦៦៩.២០៨	១២៣.៤៤៣.៥៦២
ពន្ធពន្យារជាបំណុល	១៩(ខ)	១.០៥៥.២១៨	៤.២៣៤.៥៩០	៦៧០.៧៥១	២.៦៩៩.៧៧៣
បំណុលភតិសន្យា	២០	៣៣.៦១៤.៦៦៧	១៣៤.៨៩៥.៦៥៩	៣៦.៩៣៦.១២៤	១៤៨.៦៦៧.៨៩៩
បំណុលសរុប		២.៣៣០.៦៧៤.១៣៩	៩.៣៥២.៩៩៥.៣២១	២.៣៣៣.៦៩៧.០៩៤	៩.៣៩៣.១៣០.៨០៣
មូលធន					
ដើមទុន	២១(ក)	២៩៥.០០០.០០០	១.១៨០.០០០.០០០	២៩០.០០០.០០០	១.១៦០.០០០.០០០
ប្រាក់ចំណេញរក្សាទុក		៥.៨៦៧.៥១៦	២៩.៦៧៧.៨៦៣	២១.៨៦៤.៩៨៥	៩២.២៣៨.៩១១
ប្រាក់បម្រុងកាតព្វកិច្ច	២១(ខ)	១៨៧.៩៦៧.២៨៤	៦០២.០៤៣.៥៣៦	១២៦.១៤៥.៤២២	៥១៤.៥១៦.០៤៨
ទុនបម្រុងលើការបកប្រែរូបិយប័ណ្ណ		-	(១០.៥៤៦.៩៤៦)	-	(៥.៣៧៣.០៧០)
មូលធនសរុប		៤៤៨.៨៣៤.៨០០	១.៨០១.១៧៤.០៥៣	៤៣៧.៦១០.៤០៧	១.៧៦១.៣៨១.៨៨៩
បំណុល និងមូលធនសរុប		២.៧៧៩.៥០៨.៩៣៩	១១.១៥៤.១៦៩.៣៧៤	២.៧៧១.៣០៧.៥០១	១១.១៥៤.៥១២.៦៩២

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយចាប់ពីទំព័រលេខ ១៥ ដល់ ១១៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់លេខ ២.៤)
ចំណូលប្រតិបត្តិការ					
ចំណូលការប្រាក់	២២	២២៤.៥០៦.៦៦៦	៩០០.៤៩៦.២៣៧	២៣៦.៤០៧.៦៨៧	៩៦២.៤១៥.៦៩៤
ចំណាយការប្រាក់	២៣	(១១៧.៧៥០.៥៥៨)	(៤៧២.២៩៧.៤៨៨)	(១៤២.៩២៧.៤៣៥)	(៥៨១.៨៥៧.៥៨៨)
ចំណូលការប្រាក់សុទ្ធ		១០៦.៧៥៦.១០៨	៤២៨.១៩៨.៧៤៩	៩៣.៤៨០.២៥២	៣៨០.៥៥៨.១០៦
ចំណូលផ្សេងៗ	២៤	៨.១៥៩.១៧១	៣២.៧២៦.៤៣៥	៩.៦២២.៩២៦	៣៩.១៧៤.៩៣២
កម្រៃសេវា និងកម្រៃជើងសាសុទ្ធ	២៥	១០.៦៨៨.៤២៥	៤២.៨៧១.២៧៣	១១.០០២.៣៤៨	៤៤.៧៩០.៥៥៩
ចំណូលប្រតិបត្តិការ		១២៥.៦០៣.៧០៤	៥០៣.៧៩៦.៤៥៧	១១៤.១០៥.៥២៦	៤៦៤.៥២៣.៥៩៧
ចំណាយទូទៅ និងចំណាយរដ្ឋបាល	២៦	(៧៩.៥៧១.៥៩៤)	(៣១៩.១៦១.៦៦៤)	(៨៧.៥៩៥.៥៩២)	(៣៥៦.៦០១.៦៥៥)
សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក	២៧	(៣៩.២០១.០០៥)	(១៥៧.២៣៥.២៣១)	(៨.០២១.២៣២)	(៣២.៦៥៤.៤៣៥)
ចំណូលមុនបង់ពន្ធលើប្រាក់ចំណូល		៦.៨៣១.១០៥	២៧.៣៩៩.៥៦២	១៨.៤៨៨.៧០២	៧៥.២៦៧.៥០៧
ចំណាយពន្ធលើប្រាក់ចំណូល	១៩	(៦០៦.៧១២)	(២.៤៣៣.៥២២)	(១.៩៧៤.១៤៩)	(៨.០៣៦.៧៦១)
ចំណូលសុទ្ធសម្រាប់ការិយបរិច្ឆេទ		៦.២២៤.៣៩៣	២៤.៩៦៦.០៤០	១៦.៥១៤.៥៥៣	៦៧.២៣០.៧៤៦
លទ្ធផលពេញលេញផ្សេងៗ៖					
លម្ឿងពីការបកប្រែរូបិយប័ណ្ណ		-	(៥.១៧៣.៨៧៦)	-	(២៥.១៧៥.៤២១)
លទ្ធផលពេញលេញសរុប		៦.២២៤.៣៩៣	១៩.៧៩២.១៦៤	១៦.៥១៤.៥៥៣	៤២.០៥៥.៣២៥

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយចាប់ពីទំព័រលេខ ១៥ ដល់ ១១៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ចំណេញរក្សាទុក		ប្រាក់បម្រុងកាតព្វកិច្ច		ទុនបម្រុងលើការបកប្រែរូបិយប័ណ្ណ	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២១)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤ និង២១)	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សមតុល្យ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	២៩០.០០០.០០០	១.១៦០.០០០.០០០	២១.៤៦៤.៩៨៥	៩២.២៣៨.៩១១	១២៦.១៤៥.៤២២	៥១៤.៥១៦.០៤៨	(៥.៣៧៣.០៧០)	៤៣៧.៦១០.៤០៧	១.៧៦១.៣៨១.៨៨៩
លទ្ធផលពេញលេញសរុប សម្រាប់ការិយបរិច្ឆេទ	-	-	៦.២២៤.៣៩៣	២៤.៩៦៦.០៤០	-	-	(៥.១៧៣.៨៧៦)	៦.២២៤.៣៩៣	១៩.៧៩២.១៦៤
ការបន្ថែមដើមទុន	៥.០០០.០០០	២០.០០០.០០០	-	-	-	-	-	៥.០០០.០០០	២០.០០០.០០០
ការផ្ទេរទៅប្រាក់បម្រុងកាតព្វកិច្ច	-	-	(២១.៨២១.៨៦២)	(៨៧.៥២៧.៤៨៨)	២១.៨២១.៨៦២	៨៧.៥២៧.៤៨៨	-	-	-
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**២៩៥.០០០.០០០**	**១.១៨០.០០០.០០០**	**៥.៨៦៧.៥១៦**	**២៩.៦៧៧.៤៦៣**	**១៤៧.៩៦៧.២៨៤**	**៦០២.០៤៣.៥៣៦**	**(១០.៥៤៦.៩៤៦)**	**៤៤៨.៨៣៤.៨០០**	**១.៨០១.១៧៤.០៥៣**
សមតុល្យ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	២៨០.០០០.០០០	១.១២០.០០០.០០០	៦៦.៨៣៣.៤១៧	២៧៦.៩៣៣.៧៩៧	៦៤.២៦២.៤៣៧	២៦២.៥៩០.៤១៦	១៩.៨០២.៣៥១	៤១១.០៩៥.៨៥៤	១.៦៧៩.៣២៦.៥៦៤
លទ្ធផលពេញលេញសរុប សម្រាប់ការិយបរិច្ឆេទ	-	-	១៦.៥១៤.៥៥៣	៦៧.២៣០.៧៤៦	-	-	(២៥.១៧៥.៤២១)	១៦.៥១៤.៥៥៣	៤២.០៥៥.៣២៥
ការបន្ថែមដើមទុន	១០.០០០.០០០	៤០.០០០.០០០	-	-	-	-	-	១០.០០០.០០០	៤០.០០០.០០០
ផ្ទេរទៅប្រាក់បម្រុងកាតព្វកិច្ច	-	-	(៦១.៨៨២.៩៨៥)	(២៥១.៩២៥.៦៣២)	៦១.៨៨២.៩៨៥	២៥១.៩២៥.៦៣២	-	-	-
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**២៩០.០០០.០០០**	**១.១៦០.០០០.០០០**	**២១.៤៦៤.៩៨៥**	**៩២.២៣៨.៩១១**	**១២៦.១៤៥.៤២២**	**៥១៤.៥១៦.០៤៨**	**(៥.៣៧៣.០៧០)**	**៤៣៧.៦១០.៤០៧**	**១.៧៦១.៣៨១.៨៨៩**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយចាប់ពីទំព័រលេខ ១៥ ដល់ ១១៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សាច់ប្រាក់សុទ្ធ (ប្រើក្នុង) ផ្តល់ពីសកម្មភាពប្រតិបត្តិការ	២៨	(៧៦.១៥១.៨២៤)	(៣០១.៩០៨.៧៨៤)	២២៣.៦២០.៦១១	៩១០.៣៥៩.៥០៩
សកម្មភាពវិនិយោគ					
ការទិញនៃ៖					
ទ្រព្យ និងបរិក្ខារ	១០	(១.៦៦៣.១១៤)	(៦.៦៧០.៧៥០)	(២.៩១៣.៦៨១)	(១១.៨៦១.៥៩៥)
ថ្លៃដើមកម្មវិធីកុំព្យូទ័រ	១២	(៥៧៨.៦៦៣)	(២.៣២១.០១៧)	(១.៦៩២.០៤៦)	(៦.៨៨៨.៣១៩)
សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម		(២៩៦.៥៧៩)	(១.១៨៩.៥៧៨)	(២៧.៣១៣)	(១១១.១៩១)
ការវិនិយោគផ្សេងៗ		-	-	(៩.៩៣៧.៨៨៨)	(៤០.៤៥៧.១៤២)
ការលក់នៃទ្រព្យ និងបរិក្ខារ		២១.៤៦៤	៨៦.០៩២	២៣.៧៤០	៩៦.៦៤៦
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ		(២.៥១៦.៨៩២)	(១០.០៩៥.២៥៣)	(១៤.៥៤៧.១៨៨)	(៥៩.២២១.៦០១)
សកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពី៖					
ប្រាក់កម្ចី	១៥	៧២.០៤៣.៣៣០	២៨៨.៩៦៥.៧៩៧	១.០១៧.៦៨០	៤.១៤២.៩៧៥
អនុបំណុល	១៦	១៩.១៩១.២៦៥	៧៦.៩៧៦.១៦៤	៣.៣០០.០០០	១៣.៤៣៤.៣០០
ការបន្ថែមដើមទុន	២១(ក)	៥.០០០.០០០	២០.០០០.០០០	១០.០០០.០០០	៤០.០០០.០០០
ការទូទាត់សងលើ៖					
ប្រាក់កម្ចី	១៥	(៧០.៨៩៨.៣៤២)	(២៨៤.៣៧៣.២៥០)	(១១៧.៧១៨.៥១៣)	(៤៧៩.២៣២.០៦៦)
អនុបំណុល	១៦	(២៩.៩៥៧.៨៦២)	(១២០.១៥៩.៣៨០)	(២២.៩៥០.០០០)	(៩៣.៤២៩.៤៥០)
បំណុលភតិសន្យា	២០	(៥.៨៨៦.០៣៩)	(២៣.៦០៨.៩០២)	(៦.០៦០.៩២១)	(២៤.៦៧៤.០០៩)
សាច់ប្រាក់សុទ្ធបានប្រើក្នុង សកម្មភាពហិរញ្ញប្បទាន		(១០.៥០៧.២៤៨)	(៤២.១៩៩.៥៧១)	(១៣២.៤១១.៧៥៤)	(៥៣៩.៧៥៨.២៥០)
(ថយចុះ) ការកើនឡើងសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		(៨៩.១៧៥.៩៦៤)	(៣៥៤.២០៣.៦០៨)	៧៦.៦៦១.៦៦៩	៣១១.៣៧៩.៦៥៨
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ		៤៥២.៤០៥.១៨៨	១.៨២០.៩៣០.៨៨៣	៣៧៥.៧៤៣.៥១៩	១.៥៣៤.៩១២.២៧៥
លម្អៀងពីការបកប្រែរូបិយប័ណ្ណ		-	(៩.០៨៨.៤០០)	-	(២៥.៣៦១.០៥០)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	៣	៣៦៣.២២៩.២២៤	១.៤៥៧.៦៣៨.៨៧៥	៤៥២.៤០៥.១៨៨	១.៨២០.៩៣០.៨៨៣

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយចាប់ពីទំព័រលេខ ១៥ ដល់ ១១៩ ជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១. ព័ត៌មានទូទៅ

ធនាគារ ស្ថាបនា តីអិលស៊ី ហៅកាត់ថា (“ធនាគារ”) ត្រូវបានបង្កើតឡើង និងបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការបង្កើត និងប្រតិបត្តិការ

ស្ថាបនា លីមីតធីត ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (“MFI”) ត្រូវបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងពាណិជ្ជកម្ម (“MoC”) នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៣ តាមអនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ រវាងស្ថាបនាសហគមន៍កម្ពុជា (CCB) ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦ និងបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាបណ្ណដើម្បីធ្វើប្រតិបត្តិការជាមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិ នៃ កម្ពុជា (“NBC”) នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៣ ហើយចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ ស្ថិតនៅក្រោមឈ្មោះជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍។ ដោយស្ថិតនៅក្រោមអាជ្ញាបណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានត្រូវបានអនុញ្ញាតឱ្យផ្តល់តណទាន និងសេវាផ្តល់ប្រាក់សន្សំដល់ក្រុមគ្រួសារក្រីក្រ និងមានចំណូលទាប និងអង្គភាពធុនតូច ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាបណ្ណពីធនាគារជាតិ នៃ កម្ពុជា ដើម្បីផ្តល់សេវាកម្មទទួលប្រាក់បញ្ញើ។ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានទទួលអាជ្ញាបណ្ណរយៈពេល ៣ ឆ្នាំ បន្តទៀតដើម្បីផ្តល់ សេវាកម្មប្តូរប្រាក់។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ធនាគារ ម៉ារ៉ូហាន់ ជប៉ុន តីអិលស៊ី (“MJB”) បានចុះកិច្ចសន្យាទិញលក់ជាមួយ Stichting Triodos-Doen Nederlandse Financierings-Maatschapij Voor Ontwikellingslanden N.V. DWM Funds S.C.A – SICAV SIF CCB និង Sathapana Employee Investment Limited ដើម្បីទិញភាគហ៊ុនចំនួន ៩៥,១% ពីស្ថាបនា លីមីតធីត។ ការទិញហ៊ុននេះត្រូវបានអនុម័ត ដោយធនាគារជាតិ នៃ កម្ពុជា នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ ហើយក្រសួងពាណិជ្ជកម្ម បានអនុម័ត ទៅលើការប្តូរកម្មសិទ្ធិនៃដើមទុននាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានសម្រេចតាមការអនុលោមនៃកិច្ចព្រមព្រៀងជាមួយ CCB ថាភាគហ៊ុនមិនមានអភិបាលភាពរបស់គ្រឹះស្ថាន ត្រូវបានលក់ទៅឱ្យ MJB ហើយភាគហ៊ុនដែលនៅសល់ចំនួន ៤,៩% ជារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយភាគហ៊ុនមិនមានអភិបាលភាពនេះតំណាងឱ្យភាគហ៊ុនរបស់គ្រឹះស្ថានមានសមតុល្យសរុប ៦,០២ លានដុល្លារអាមេរិក។ ប្រតិបត្តិការនេះ ត្រូវបានបញ្ចប់នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

នៅដើមឆ្នាំ២០១៥ ធនាគារ ម៉ារ៉ូហាន់ ជប៉ុន តីអិលស៊ី និងស្ថាបនា លីមីតធីត បានយល់ព្រមរួមបញ្ចូលគ្រឹះស្ថានទាំងពីរជា ធនាគារតែមួយ ដោយមានឈ្មោះថ្មីជាធនាគារ ស្ថាបនា តីអិលស៊ី ហើយទទួលបានការអនុម័តជាផ្លូវការពីធនាគារជាតិ នៃ កម្ពុជា នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦។ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ធនាគារជាតិ នៃ កម្ពុជា បានផ្តល់អាជ្ញាបណ្ណជាធនាគារ អចិន្ត្រៃយ៍ដល់ធនាគារ ស្ថាបនា តីអិលស៊ី។ រាល់ទ្រព្យសកម្ម និងបំណុលទាំងអស់របស់ MJB បានផ្ទេរទៅឱ្យធនាគារ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារស្ថាបនាលេខ ៦៣ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧២ និង ផ្លូវលេខ១៧៤ ភូមិ១៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារធ្វើប្រតិបត្តិការរបស់ខ្លួនតាមបណ្តាខេត្តទាំង ២៥ ដែលមានបណ្តាញសាខាចំនួន ១៧៥ សាខា។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ធនាគារមាននិយោជិតចំនួន ៣.៤៦៤ នាក់ (ឆ្នាំ២០២៤៖ ៤.២៣៩ នាក់)។

សកម្មភាពអាជីវកម្មចម្បង

ធនាគារ មានសកម្មភាពអាជីវកម្មចម្បងក្នុងទិដ្ឋភាពជាធនាគារ និងការផ្តល់សេវាកម្មដែលពាក់ព័ន្ធនឹងសេវាកម្មហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។

ដើមទុនដែលបានបង់

ដើមទុនដែលបានបង់របស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានចំនួន ២៩៥.០០០.០០០ ដុល្លារ អាមេរិក (ឆ្នាំ២០២៤៖ ២៩០.០០០.០០០ ដុល្លារអាមេរិក)។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចខាងក្រោម៖

បណ្ឌិត Han Chang-Woo	ប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ)
លោក Han Ken	អនុប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ)
ឯកឧត្តម Shinohara Katsuhiro	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
ឯកឧត្តម គឹម វ៉ាដា	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Williams John Gerard	អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
លោក Hosoi Takehito	អភិបាលមិនប្រតិបត្តិ (លាលែងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥)
លោក Hiramatsu Naoya	អភិបាលមិនប្រតិបត្តិ
លោក Kawahara Yoshiki	អភិបាលមិនប្រតិបត្តិ (លាលែងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥)
លោក Matsuyama Hirohisa	អភិបាលមិនប្រតិបត្តិ (តែងតាំងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥)

២. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត ដែលបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ បានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងជាប់លាប់នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។

២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាមមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែសមាសធាតុទាំងឡាយណាដែលមិនត្រូវបាន រៀបចំឡើងក្រោមមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ ដូចបានបង្ហាញខាងក្រោមនេះ៖

- ឧបករណ៍ហិរញ្ញវត្ថុតាមថ្លៃដើមរំលស់
- ឧបករណ៍ហិរញ្ញវត្ថុបានកំណត់តម្លៃតាមតម្លៃសមស្រប
- កំណត់អត្ថប្រយោជន៍កាតព្វកិច្ច និង
- សំវិធានធន ដែលបានវាស់វែងតាមការចំណាយដែលបានប៉ាន់ស្មានយ៉ាងត្រឹមត្រូវបំផុតដែលតម្រូវឱ្យទូទាត់កាតព្វកិច្ចបច្ចុប្បន្ន ជាមួយការធ្វើអប្បហារ ប្រសិនបើមានផលប៉ះពាល់ទៅលើតម្លៃពេលវេលានៃសាច់ប្រាក់មានភាពជាសារវន្ត។

ការិយបរិច្ឆេទសារពើពន្ធ

ការិយបរិច្ឆេទសារពើពន្ធរបស់ធនាគារចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

២.២ របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

និយ័តករគណនេយ្យ និងសវនកម្ម បានចេញប្រកាស (សារាចរ) លេខ ០៦៨-សហវ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា បានអនុម័តទៅលើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិ (“IFRSs”) ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (“IASB”) លុះត្រាតែមានការពន្យារផ្សេងពីនេះ។ ស្តង់ដាទាំងនេះ ដូចគ្នាទៅនឹង CIFRSs ដែរ។

២.៣ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

ធនាគារបង្ហាញពីរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន តាមលំដាប់លំដោយនៃសន្ទនីយភាព ដោយផ្អែកលើគោលបំណងរបស់ធនាគារ និងសមត្ថភាពក្នុងការប្រមូលមកវិញ/ការទូទាត់នូវទ្រព្យសកម្ម/បំណុលចម្បងភាគច្រើន នៃសមាសធាតុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការវិភាគទៅលើលទ្ធភាពក្នុងការប្រមូលមកវិញ ឬការទូទាត់ក្នុងរយៈពេល ១២ខែ បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍ (“ចរន្ត”) និងច្រើនជាង ១២ ខែ បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍ (“អចរន្ត”) ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣២។

២.៤ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណមុខងាររបស់ធនាគារ គឺដុល្លារអាមេរិក (“US$”)។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ហើយគ្រប់តម្លៃទាំងអស់ត្រូវបានបង្គត់ទៅជាខ្ទង់ដុល្លារអាមេរិកដែលនៅជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។ ការបកប្រែរូបិយប័ណ្ណពី ដុល្លារអាមេរិកទៅជាខ្មែររៀល (“KHR”) ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដោយផ្អែកលើអត្រាប្តូរប្រាក់ ដែលអាចអនុវត្តបានក្នុង ១ ដុល្លារអាមេរិក ដូចដែលបានប្រកាសដោយធនាគារជាតិ នៃ កម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ដោយផ្អែកលើអត្រាប្តូរប្រាក់ដែលអាចអនុវត្តបានក្នុង ១ដុល្លារអាមេរិកដូចខាងក្រោម៖

	ឆ្នាំ២០២៥	ឆ្នាំ២០២៤
អត្រាចុងគ្រា	៤.០១៣	៤.០២៥
អត្រាមធ្យម*	៤.០១១	៤.០៧១

* អត្រាមធ្យមត្រូវបានកំណត់ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិ នៃ កម្ពុជា។

២.៥ សេចក្តីសង្ខេបនៃព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

គោលនយោបាយគណនេយ្យដែលមានចែងនៅខាងក្រោមនេះ ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនគ្រប់ពេលវេលា ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

២.៥.១ ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

(ក) ការទទួលស្គាល់ និងការវាស់វែងដំបូង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលធនាគារក្លាយជាភាគីនៃសំវិធានធនតាមកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ទៅលើការទិញ ឬលក់។

(ខ) ចំណាត់ថ្នាក់

ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅពេលទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ និងវាស់វែងតាម៖ ថ្លៃដើមរំលស់ តម្លៃសមស្របតាមរយៈលទ្ធផលពេញលេញផ្សេងៗ (“FVOCI”) ឬតម្លៃសមស្របតាមរយៈចំណេញ ឬខាត (“FVTPL”)។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់តាមថ្លៃដើមរំលស់ ប្រសិនបើវាបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់តាម FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់នៅក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីកាន់កាប់ទ្រព្យសកម្មដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឱ្យមានការកើនឡើងតាមកាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់ដែលជា ‘ការទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”)។

ឧបករណ៍បំណុលត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់នៅក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីសម្រេចបានទាំង ការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្ម និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឱ្យមានការកើនឡើងតាមកាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់ដែលជា SPPI។

ការទទួលស្គាល់ដំបូងនៃការវិនិយោគមូលធន ដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ធនាគារអាចធ្វើការជ្រើសរើស ដោយពុំមានការកែប្រែក្នុងការបង្ហាញពីការផ្លាស់ប្តូរជាបន្តបន្ទាប់នូវតម្លៃសមស្របនៅក្នុងលទ្ធផលពេញលេញផ្សេងៗ ("OCI")។ ការជ្រើសរើសនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការវិនិយោគនីមួយៗដាច់ដោយឡែក។

ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទាំងអស់ ត្រូវបានចាត់ថ្នាក់ និងវាស់វែងតាម FVTPL។

លើសពីនេះទៀត ការទទួលស្គាល់ដំបូង ធនាគារអាចកំណត់នូវទ្រព្យសកម្មហិរញ្ញវត្ថុដែលអាចត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ឬតាម FVOCI ទៅវាស់វែងតាម FVTPL ប្រសិនបើការអនុវត្តដូច្នេះ លុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតមានឡើង។

ការវាយតម្លៃគំរូអាជីវកម្ម

ធនាគារធ្វើការវាយតម្លៃពីគោលបំណងនៃគំរូអាជីវកម្ម ដែលទ្រព្យសកម្មត្រូវបានកាន់កាប់នៅកម្រិតផលបត្រ ព្រោះវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុត ពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មានដែលបានផ្តល់ជូនគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់កម្រិតផលបត្រ និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយ ទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ភាពស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលបំណុល ដែលជាមូលនិធិរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- របៀបនៃប្រតិបត្តិការនៃផលបត្រ ត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលជះឥទ្ធិពលដល់ប្រតិបត្តិការគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលប្រធានគ្រប់គ្រងអាជីវកម្មទទួលបានសំណង (ឧទាហរណ៍ថា តើសំណងគឺផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្ម ដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងការិយបរិច្ឆេទមុន មូលហេតុនៃការលក់ទាំងនេះ និងការរំពឹងទុក ពីសកម្មភាពលក់នាពេលអនាគត។ ទោះយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានពិចារណាតែមួយផ្នែកទេ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃរួម ដែលធនាគារបានបញ្ជាក់អំពីគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះអាចសម្រេចបាន និងរបៀបដែលលំហូរសាច់ប្រាក់ត្រូវាបានប្រមូលមកវិញ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកាន់កាប់សម្រាប់ការធ្វើពាណិជ្ជកម្ម ឬគ្រប់គ្រង និងការអនុវត្តដែលត្រូវបានវាយតម្លៃ ដោយផ្អែកលើ មូលដ្ឋានតម្លៃសមស្រប ដែលត្រូវបានវាស់វែងនៅ FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនកាន់កាប់សម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនកាន់កាប់សម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺជាការទូទាត់តែប្រាក់ដើមនិងការប្រាក់

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ 'ប្រាក់ដើម' ត្រូវបានកំណត់ជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ដំបូង។ 'ការប្រាក់' ត្រូវបានកំណត់ជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ ក្នុងរយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងសមតុល្យប្រាក់ដើម ដែលនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ធនីយភាព និងចំណាយរដ្ឋបាល) រួមទាំងកម្រិតប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជា SPPI ធនាគារពិចារណាលើលក្ខខណ្ឌកិច្ចសន្យា នៃឧបករណ៍នោះ។ វារួមបញ្ចូល ទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានរយៈពេលកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬសមតុល្យលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញតាមលក្ខខណ្ឌនេះទេ។

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍យថាភាព ដែលអាចផ្លាស់ប្តូរសមតុល្យ និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌចំណាយបង់មុន និងការពន្យារពេល
- លក្ខខណ្ឌ ដែលកំណត់ការទាមទាររបស់ធនាគារចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មដែលបានបញ្ជាក់ (ឧទាហរណ៍ ឥណទានមិនមែនជាសំណង) និង
- លក្ខណៈពិសេស ដែលកែប្រែអំពីតម្លៃពេលវេលានៃសាច់ប្រាក់ ឧទាហរណ៍ ការកំណត់អត្រាការប្រាក់តាមកាលកំណត់)។

ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់

ក្នុងករណីខ្លះ ឥណទានត្រូវបានធ្វើឡើងដោយធនាគារ ដែលធានាដោយទ្រព្យបញ្ចាំរបស់អ្នកខ្ចីទៅលើការទាមទាររបស់ធនាគារចំពោះ លំហូរសាច់ប្រាក់នៃវត្ថុបញ្ចាំមូលដ្ឋាន (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ធនាគារអនុវត្តការវិនិច្ឆ័យក្នុងការវាយតម្លៃថា តើឥណទាន ទាំងនោះ បានបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ SPPI ដែរឬទេ។ ជាធម្មតា ធនាគារពិចារណាលើព័ត៌មានមួយចំនួននៅពេល ធ្វើការវិនិច្ឆ័យដូចខាងក្រោមនេះ៖

- ក្នុងលក្ខខណ្ឌការរៀបចំកិច្ចសន្យាមានកំណត់ចំនួន និងកាលបរិច្ឆេទជាក់លាក់នៃការទូទាត់ជាសាច់ប្រាក់ឥណទាន
- តម្លៃសមស្របនៃវត្ថុបញ្ចាំទាក់ទងនឹងសមតុល្យទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធានា
- សមត្ថភាព និងឆន្ទៈរបស់អ្នកខ្ចីក្នុងការទូទាត់តាមកិច្ចសន្យាទោះបីមានឱនភាពតម្លៃលើទ្រព្យបញ្ចាំ
- ក្នុងលក្ខខណ្ឌអ្នកខ្ចី គឺជាបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារ ក្នុងការខាតបង់លើទ្រព្យសកម្ម ទាក់ទងនឹងឥណទានមានសំណងពេញលេញ
- ទំហំដែលវត្ថុបញ្ចាំតំណាងឱ្យទាំងអស់ ឬ ផ្នែកសំខាន់នៃទ្រព្យរបស់អ្នកខ្ចី និង

- ធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការគិតគូរលើមូលដ្ឋានទ្រព្យសកម្ម។

ចំណាត់ថ្នាក់ឡើងវិញ
ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញឡើយ បន្ទាប់ពីមានការទទួលស្គាល់ដំបូង លើកលែងតែក្នុងការិយបរិច្ឆេទ បន្ទាប់ពីធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

(គ) ការឈប់ទទួលស្គាល់
ទ្រព្យសកម្មហិរញ្ញវត្ថុ
ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុតាមកិច្ចសន្យាត្រូវបានផុតសុពលភាព ឬ ផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យនិងផលចំណេញទាំងអស់នៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬធនាគារមិនរក្សាទុកនូវរាល់ហានិភ័យនិងផលចំណេញ ហើយក៏មិនរក្សាបានការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុនេះឡើយ។

ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬ តម្លៃយោងដែលត្រូវបានបែងចែកទៅចំណែកនៃទ្រព្យដែលបានឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបានមិនគិតពីបំណុលថ្មីដែលត្រូវបានរាប់បញ្ចូល) និង (ii) ចំណេញ ឬខាតបង្គរនៅក្នុង OCI ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុ
ធនាគារឈប់ទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្នុងកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

(ឃ)ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ
ទ្រព្យសកម្មហិរញ្ញវត្ថុ
ប្រសិនបើលក្ខខណ្ឌ នៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ ធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្ម ដែលបានកែប្រែមានភាពខុសគ្នាច្រើនឬទេ។ ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំងនោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ ដើមត្រូវបានចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានគេឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់ តាមតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការដែលមានលក្ខណៈគ្រប់គ្រាន់។ កម្រៃសេវានានា ដែលទទួលបានជាផ្នែកនៃការកែប្រែត្រូវបានកត់ត្រាដូចខាងក្រោម៖

- កម្រៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងកម្រៃសេវាដែលតំណាងឱ្យការទូទាត់តាម ថ្លៃដើមប្រតិបត្តិការដែលមានសិទ្ធិ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- កម្រៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាត ដែលជាផ្នែកមួយនៃប្រាក់ចំណេញ ឬខាតពីការឈប់ទទួលស្គាល់។

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែ នៅពេលដែលអ្នកខ្ចីជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដូច្នេះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញនូវលក្ខខណ្ឌកិច្ចសន្យាដើមជាអតិបរមា ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាច្រើន។ ប្រសិនបើធនាគារមានផែនការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ បន្ទាប់មកវាត្រូវពិចារណាជាមុនថា តើផ្នែកណាមួយ នៃទ្រព្យសកម្មគួរតែត្រូវបានលុបចោលមុនពេលមានការផ្លាស់ប្តូរនឹងកើតមានឡើង (សូមមើលគោលនយោបាយ នៃការលុបចោលទ្រព្យសកម្មនៅកំណត់សម្គាល់លេខ ២.៥.១(ឆ))។ វិធីសាស្ត្រនេះបានប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ មិនបានបំពេញតាមករណីបែបនេះទេ។

ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ឬFVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុនោះទេ ធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពដំបូងរបស់ទ្រព្យសកម្ម ហើយទទួលស្គាល់លទ្ធផលកែតម្រូវចំណេញ ឬខាត។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់អណ្តែត អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលត្រូវបានប្រើដើម្បីគណនាការកើនឡើង ឬការខាតបង់ត្រូវបានកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលធ្វើការកែប្រែ។ ថ្លៃដើមឬកម្រៃសេវាចំណាយ និងកម្រៃសេវា ដែលទទួលបានជាផ្នែក នៃការកែតម្រូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ហើយត្រូវបានគេធ្វើរំលស់លើរយៈពេលនៅសល់ នៃទ្រព្យសកម្មដែលបានកែប្រែទាំងនោះ។

ប្រសិនបើមានការកែប្រែបែបនេះ ត្រូវបានអនុវត្តដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី បន្ទាប់មកភាពចំណេញ ឬខាត ត្រូវបានបង្ហាញរួមគ្នាជាមួយនឹងឱនភាពតម្លៃ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលបានគណនា ដោយប្រើ
វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

បំណុលហិរញ្ញវត្ថុ
ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែហើយលំហូរសាច់ប្រាក់នៃបំណុល ដែលបានកែប្រែមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីមួយ ដែលផ្អែកលើលក្ខខណ្ឌដែលបានកែប្រែត្រូវបានទទួលស្គាល់ តាមតម្លៃសមស្រប។ ភាពខុសគ្នារវាងសមតុល្យយោងនៃបំណុលហិរញ្ញវត្ថុដែលឈប់បានទទួលស្គាល់ និងតម្លៃបស្នងដែលបានបង់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។ តម្លៃបស្នងដែលបានបង់ រួមបញ្ចូលទាំងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលត្រូវបានផ្ទេរប្រសិនបើមាន និងការទទួលយកបំណុលថ្មី រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះថ្លៃដើមបានរំលស់នៃបំណុល ត្រូវបានគណនាឡើងវិញ ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអណ្តែត អត្រាការប្រាក់ប្រសិទ្ធភាពដំបូង ដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេល ដែលធ្វើការកែប្រែ។ រាល់ចំណាយ និងកម្រៃសេវាដែលកើតឡើង ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃ

យោងនៃបំណុល និងត្រូវបានរំលស់ផ្អែកលើរយៈពេល ដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែនោះ ដោយធ្វើការគណនាអត្រាការប្រាក់ប្រសិទ្ធភាព ឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

(ង) ការកាត់កង
ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កង និងសមតុល្យសុទ្ធត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានសិទ្ធិស្របច្បាប់ក្នុងការកំណត់នូវសមតុល្យ ហើយមានបំណងទូទាត់ដោយផ្អែកលើមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(ច) ការវាស់វែងតម្លៃសមស្រប
'តម្លៃសមស្រប' គឺជាតម្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬទូទាត់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការដែលមានអ្នកចូលរួមទីផ្សារ នៅកាលបរិច្ឆេទនៃការវាស់វែង ឬក្នុងករណីដែលមិនមានទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលធនាគារមានសិទ្ធិប្រើប្រាស់នាកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលត្រូវឆ្លុះបញ្ចាំងពីភាពមិនមានដំណើរការហានិភ័យ។

នៅពេលមានឧបករណ៍នេះ ធនាគារវាស់តម្លៃសមស្របនៃឧបករណ៍ដោយប្រើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ឧបករណ៍នោះ។ ទីផ្សារត្រូវបានចាត់ទុកថា 'សកម្ម' ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលកើតឡើងជាមួយនឹងប្រេកង់ និងបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃតាមមូលដ្ឋានជាប្រចាំ។

ប្រសិនបើមិនមានការដកស្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះ ធនាគារប្រើបច្ចេកទេសវាយតម្លៃដែលបង្កើនការប្រើប្រាស់ធនធាន ដែលអាចសង្កេតបាន និងបង្រួមអប្បបរមានៃការប្រើប្រាស់ជាតុចូលដែលមិនអាចសង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង គឺតម្លៃប្រតិបត្តិការជាធម្មតា តម្លៃសមស្របរបស់តម្លៃតបស្នងដែលបានផ្តល់ឱ្យឬទទួលបាន។ ប្រសិនបើធនាគារកំណត់ថាតម្លៃសមស្របលើការទទួលស្គាល់ដំបូងខុសគ្នាពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របមិនត្រូវបានបង្ហាញដោយតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម សម្រាប់កំណត់អត្តសញ្ញាណទ្រព្យសកម្ម ឬបំណុលដែលដូចគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃទៅលើជាតុចូលមិនអាចអង្កេតបាន គឺត្រូវបានវិនិច្ឆ័យថា មិនមានការជាប់ទាក់ទងសំខាន់ៗនឹងការវាស់វែងនោះទេ បន្ទាប់មកឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងដោយ តម្លៃសមស្របកែតម្រូវដើម្បីពន្យារភាពខុសគ្នារវាងតម្លៃ សមស្របលើការទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះត្រូវបានគេទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋានសមស្របនៃអាយុកាលរបស់ឧបករណ៍ ប៉ុន្តែមិនលើសពីពេលដែលការវាយតម្លៃ ត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចសង្កេតបាន ឬប្រតិបត្តិការត្រូវបានបិទ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុល ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃស្នើទិញ និងតម្លៃដាក់លក់ បន្ទាប់មកធនាគារវាស់វែង ទ្រព្យសកម្មក្នុងតម្លៃស្នើទិញ និងបំណុលតាមតម្លៃដាក់លក់។

ផលបត្រនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានប្រឈមនឹងហានិភ័យទីផ្សារ និងហានិភ័យឥណទានដែលត្រូវបាន គ្រប់គ្រងដោយធនាគារដោយផ្អែកលើផលប៉ះពាល់សុទ្ធចំពោះហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងដោយផ្អែកលើតម្លៃ ដែលនឹងត្រូវបានទទួលដើម្បីលក់ (ឬបង់ប្រាក់ដើម្បីផ្ទេរ ឬរយៈពេលខ្លីសុទ្ធ) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវកម្រិតផលបត្រ ឧទាហរណ៍ ការដេញថ្លៃ -ស្នើសុំការកែតម្រូវ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងដោយឈរលើមូលដ្ឋានពី ការប៉ះពាល់សុទ្ធ -ត្រូវបានបែងចែកជាទ្រព្យសកម្ម និងបំណុលដាច់ដោយឡែក ដោយផ្អែកលើមូលដ្ឋាននៃការកែតម្រូវហានិភ័យដែល ទាក់ទងនឹងឧបករណ៍ នីមួយៗនៅក្នុងផលបត្រ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលមានលក្ខណៈទាមទារ (ឧទាហរណ៍ គណនីតាមតម្រូវការ) មិនតិចជាងសមតុល្យដែលត្រូវបង់ តាមតម្រូវការដែលត្រូវបានធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលសមតុល្យអាចតម្រូវឱ្យបង់។

ធនាគារ ទទួលស្គាល់ការផ្ទេរប្រាក់រវាងកម្រិត នៃឋានានុក្រមតម្លៃសមស្របនៅ ចុងការិយបរិច្ឆេទនៃរបាយការណ៍ ក្នុងអំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

(ឆ) អ៊ីមភែរមិន
ធនាគារទទួលស្គាល់នូវសំវិធានពីការខាតបង់ឥណទានរំពឹងទុក ("ECL") លើឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោមដែលមិនត្រូវបានវាស់វែងតាម FVTPL៖
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានអនុម័ត។

ពុំមានការខាតអ៊ីមភែរមិន ត្រូវបានទទួលស្គាល់លើការវិនិយោគមូលធននោះទេ។

ធនាគារវាស់វែងសំវិធានធនខាតបង់តាមសមតុល្យស្មើនឹង ECL មួយអាយុកាលលើកលែងតែចំណុចដូចខាងក្រោម ដែលត្រូវបានវាស់វែងជា ECL រយៈពេល ១២ ខែ៖
- មូលបត្រវិនិយោគបំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនៅការិយបរិច្ឆេទនៃការរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលហានិភ័យឥណទានមិនបានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីមានការទទួលស្គាល់ដំបូង។

ECL ១២ខែ គឺជាផ្នែកមួយនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍មិនប្រក្រតីលើឧបករណ៍ហិរញ្ញវត្ថុដែលអាចធ្វើទៅបានក្នុងរយៈពេល ១២ខែ បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ ECL មានរយៈពេល ១២ខែ ត្រូវបានគេទទួលស្គាល់ថាជា 'ឧបករណ៍ហិរញ្ញវត្ថុដំណាក់កាលទី ១'។

ECL មួយអាយុកាល គឺជា ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលអាចកើតមានទាំងអស់លើអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែល ECL មួយអាយុកាល ត្រូវបានគេទទួលស្គាល់ ប៉ុន្តែមិនមានអ៊ីមភែរមិនលើឥណទាន ត្រូវបានគេហៅថា 'ឧបករណ៍ ហិរញ្ញវត្ថុដំណាក់កាលទី ២'។

នាកាលបរិច្ឆេទ នៃការរាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើហានិភ័យ

ឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីមានការទទួលស្គាល់ដំបូង។ នៅពេលហានិភ័យឥណទានបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូង សំវិធានធនលើការខាតបង់ត្រូវបានវាស់វែងតាមសមតុល្យស្មើនឹង ECL មួយអាយុកាល។ នៅពេលកំណត់ថាតើហានិភ័យឥណទាន នៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូង និងនៅពេលប៉ាន់ស្មាន ECL ធនាគារពិចារណាលើព័ត៌មានសមហេតុផល និងអាចទុកចិត្តបានដែលពាក់ព័ន្ធ និងអាចរកបានដោយ មិនចាំបាច់ចំណាយឬការប្រឹងប្រែងដែលមិនសមហេតុផល។ ទាំងនេះរួមមានទាំងបរិមាណ និងព័ត៌មានប្រកបដោយគុណភាព និងការវិភាគ ផ្អែកលើបទពិសោធន៍ និងប្រវត្តិសាស្ត្ររបស់ធនាគារ និងការវាយតម្លៃឥណទានដែលមានស្រាប់ និងរួមបញ្ចូលទាំងព័ត៌មានព្យាករណ៍ទៅ អនាគត។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់ដំបូង ឬប្រសិនបើគុណភាពឥណទាននៃ ឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើងនោះ ឬលែងមានការកើនឡើងគួរឱ្យ កត់សម្គាល់លើហានិភ័យឥណទានចាប់តាំងពីមានការទទួលស្គាល់ដំបូង ហើយសំវិធានធនខាតបង់ត្រូវបានវាស់វែងក្នុងសមតុល្យស្មើនឹង ECL រយៈពេល ១២ខែ។

រយៈពេលអតិបរមាដែលត្រូវបានពិចារណានៅពេលប៉ាន់ស្មាន ECL គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារត្រូវប្រឈមនឹង ហានិភ័យឥណទាន។

កំណត់ថាតើហានិភ័យឥណទានបានកើនឡើងជាសារវន្ត
ធនាគារវាយតម្លៃថាតើហានិភ័យឥណទានបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង នៅការិយបរិច្ឆេទរបាយការណ៍នីមួយៗ។ ការកំណត់ថាតើការកើនឡើងហានិភ័យឥណទានមានសារៈសំខាន់ឬអត់ អាស្រ័យលើលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអ្នកខ្ចី និងតំបន់ភូមិសាស្ត្រ។

ធនាគារចាត់ទុកថាការកើនឡើងនូវហានិភ័យឥណទានកើតឡើងមិនលើសពីពេលដែលទ្រព្យសកម្មហួសកាលកំណត់ ៣០ថ្ងៃ (“DPD”)។ ថ្ងៃដែលហួសកំណត់ត្រូវបានកំណត់ដោយរាប់ចំនួនថ្ងៃចាប់តាំងពីថ្ងៃផុតកំណត់ ដំបូងបំផុតដែលទាក់ទងនឹងការទូទាត់ប្រាក់ពេញលេញ មិនត្រូវបានទទួល។ កាលបរិច្ឆេទកំណត់ត្រូវបានកំណត់ដោយមិនគិតពីរយៈពេលអនុគ្រោះ ណាមួយដែលអាចមានសម្រាប់អ្នកខ្ចីឡើយ។

ប្រសិនបើមានភស្តុតាងបង្ហាញថាមិនមានការកើនឡើងគួរឱ្យ កត់សម្គាល់លើហានិភ័យឥណទានទាក់ទងនឹងការទទួលស្គាល់ដំបូងទេនោះ សំវិធានធនខាតបង់លើឧបករណ៍មួយនឹងវិលត្រឡប់ជាការវាស់វែង ECL រយៈពេល ១២ខែ។

និយមន័យនៃឥណទានខូច
ធនាគារពិចារណាលើព្រឹត្តិការណ៍ដែលបង្កើតអោយមានឥណទានខូចដូចខាងក្រោម
- អ្នកខ្ចីទំនងជាមិនបង់កាតព្វកិច្ចឥណទានរបស់ខ្លួនដល់ធនាគារ ដោយគ្មានការប្រមូលមកវិញពីធនាគារ ដោយការរឹបអូស ទ្រព្យបញ្ចាំ (ប្រសិនបើមាន) ឬ
- ធនាគារពិចារណាថា អ៊ីមែរមិនឥណទាន កើតឡើងនៅពេល ទ្រព្យសកម្ម ហួសកាលកំណត់បង់រយៈពេល ៩០ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬហួសកាលកំណត់បង់ច្រើនជាង ៣០ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី។
- នៅពេលគណនីនេះត្រូវបានរៀបចំឡើងវិញ ឬ មានការផ្លាស់ប្តូរ
- នៅពេលគណនីត្រូវបានចាត់ថ្នាក់ទៅតាមចំណាត់ថ្នាក់នៃហ្វាស៊ីលីធីដែលខូច នៃអ្នកខ្ចីតែម្នាក់ នៅក្នុងប្រភពបញ្ជីឥណទានដូចគ្នា។

ការវាស់វែងនៃ ECL
ECL គឺជាការប៉ាន់ស្មាន ដោយផ្អែកលើការថ្លឹងថ្លែងប្រូបាប៊ីលីតេនៃការខាតបង់ឥណទាន ហើយត្រូវបានវាស់វែងដូចខាងក្រោម៖
- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានអ៊ីមែរមិនលើឥណទាន នាការិយបរិច្ឆេទនៃរបាយការណ៍៖ ជាតម្លៃបច្ចុប្បន្នដែលមានកង្វះខាតសាច់ប្រាក់ (មានន័យថាភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអ៊ីមែរមិនលើឥណទាន នាការិយបរិច្ឆេទនៃរបាយការណ៍៖ ដូចជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគត និង
- កិច្ចសន្យាឥណទាន ដែលមិនបានដក៖ ជាតម្លៃបច្ចុប្បន្នដែលមានភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលត្រូវសងទៅធនាគារ ប្រសិនបើកិច្ចសន្យានេះ មិនបានប្រើប្រាស់ និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបាន។

ធាតុចូល ការសន្មត និងបច្ចេកទេសដែលត្រូវបានប្រើសម្រាប់ការប៉ាន់ស្មាន ECL
ធាតុចូលសំខាន់ៗ ក្នុងការវាស់វែងរបស់ ECL គឺជារចនាសម្ព័ន្ធអថេរដូចខាងក្រោម៖
- ប្រូបាប៊ីលីតេនៃឥណទានខូច (“PD”)
- ការខាតបង់ដែលបានកើតមាន (“LGD”)
- ចំនួនដែលត្រូវខាតបង់នៅពេលឥណទានខូច (“EAD”)
- ការកែតម្រូវកត្តាសេដ្ឋកិច្ច (“EFA”) និង
- កត្តាអប្បហារ (“DF”)។

ECL សម្រាប់ការបង្ហាញនៅដំណាក់កាលទី ១ ត្រូវបានគណនាដោយគុណ PD ១២ខែ ដោយ EAD ១២ ខែ និង EFA ១២ ខែ ដោយ LGD និងដោយកត្តាអប្បហារ។ ECL មួយអាយុកាល ត្រូវបានគណនាដោយគុណ PD មួយអាយុកាល និង EAD មួយអាយុកាល និង EFA មួយអាយុកាល និង LGD និងកត្តាអប្បហារ។

ធនាគារទទួលយកនូវតារាងបម្រែបម្រួល ដែលមានមូលដ្ឋានលើភាពមិនត្រឹមត្រូវគំរូអត្រាការខាតបង់ជាប្រវត្តិសាស្ត្រ និងគំរូប្រូកស៊ីដើម្បី ប៉ាន់ស្មាន PD របស់ខ្លួន។

LGD គឺជាទំហំនៃការបាត់បង់ដែលអាចកើតមានប្រសិនបើមានលំនាំដើម ធនាគារប៉ាន់ស្មានប៉ារ៉ាម៉ែត្ររបស់ LGD ផ្អែកលើប្រវត្តិនៃអត្រា ពីការសើរើឡើងវិញដែលមានការទាមទារការទូទាត់ពីសមភាគី។ គំរូ LGD ពិចារណាលើរចនាសម្ព័ន្ធ វត្ថុបញ្ចាំ អតីតភាពនៃការទូទាត់ ឧស្សាហកម្មសមភាគី និងថ្លៃដើមនៃការស្តារឡើងវិញនៃទ្រព្យបញ្ចាំណាមួយដែលជាផ្នែករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ LGD ត្រូវបានគណនា ផ្អែកលើវិធីសាស្ត្រសាកល្បង។ វិធីសាស្ត្រសាកល្បង គឺផ្អែកទៅលើសំណុំលំហូរសាច់ប្រាក់ដែលបាន

ប៉ាន់ស្មាន (ឧទាហរណ៍ ការប្រមូល ឬលក់វត្ថុបញ្ចាំ) ក្នុងអំឡុងពេលនៃការសាកល្បង និងអប្បហារលើអត្រាការប្រាក់ប្រសិទ្ធភាពរហូតដល់កាលវិសាន្ត។

EAD តំណាងឱ្យការប៉ះពាល់ដែលរំពឹងទុកក្នុងករណីមានបញ្ហា។ ធនាគារទាញយក EAD ពីការប៉ះពាល់នាពេលបច្ចុប្បន្នទៅនឹងសមភាគី និងការផ្លាស់ប្តូរសក្តានុពលនៃសមតុល្យបច្ចុប្បន្នដែលបានអនុញ្ញាតក្រោម កិច្ចសន្យានិងកើតឡើងពីការរំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុគឺជាតម្លៃយោងដុលតាមលំនាំដើម ដែលដល់កាលកំណត់សង។ ចំពោះការសន្យាផ្តល់ឥណទាន EADs គឺជាចំនួនសក្តានុពល នាពេលអនាគត ដែលអាចត្រូវបានបង្ហាញក្រោមកិច្ចសន្យាដែលត្រូវបានប៉ាន់ស្មានផ្អែកលើការសង្កេតប្រវត្តិសាស្ត្រ និងការព្យាករណ៍ នាពេលខាងមុខ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ EAD ត្រូវបានកំណត់ដោយយកគំរូតាមលទ្ធផលដែលអាចមាននៅចំណុចផ្សេងៗ ក្នុងពេលវេលាដោយប្រើសេណារីយ៉ូ និងបច្ចេកទេសស្ថិតិ។

ដូចដែលបានរៀបរាប់ខាងលើ ការប្រើប្រាស់អតិបរមាចំនួន ១២ ខែ PD សម្រាប់ទ្រព្យសកម្មដំណាក់កាលទី ១ ធនាគារវាស់វែង ECL ពិចារណាលើហានិភ័យនៃការខកខានក្នុងរយៈពេលកិច្ចសន្យាអតិបរមា (រាប់បញ្ចូលទាំងជម្រើសពន្យាររបស់អ្នកខ្ចី) ប្រឈមនឹងហានិភ័យឥណទាន ទោះបីក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទាន ធនាគារពិចារណារយៈពេលយូរជាងនេះ។ រយៈពេលកិច្ចសន្យាអតិបរមា មានរហូតដល់កាលបរិច្ឆេទដែលធនាគារមានសិទ្ធិទាមទារសងប្រាក់ជាមុន ឬបញ្ចប់កិច្ចសន្យា ឬការធានាឥណទាន។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ
ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានពិភាក្សាឡើងវិញ ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយ ទ្រព្យថ្មី ដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី បន្ទាប់មកការវាយតម្លៃត្រូវបានធ្វើឡើងថាតើទ្រព្យសកម្មហិរញ្ញវត្ថុ គួរត្រូវបានគេទទួលស្គាល់ហើយ ECL ត្រូវបានវាស់ដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ ដែលរំពឹងទុកនឹងមិនបណ្តាលឱ្យមានការទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកដែលបានមកពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកែប្រែត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះសាច់ប្រាក់ពី ទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ ដែលរំពឹងទុកនឹងមានលទ្ធផលនៃការមិនទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃដែលរំពឹងទុកនៃទ្រព្យសកម្មថ្មី ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយពីទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់នៅ ពេលឈប់ទទួលស្គាល់។ សមតុល្យនេះត្រូវបានរាប់បញ្ចូលក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ដែលត្រូវបានធ្វើអប្បហារតម្លៃតាមកាលបរិច្ឆេទ ដែលបានរំពឹងទុកនៃការឈប់ទទួលស្គាល់រហូតដល់កាលបរិច្ឆេទនៃការរាយការណ៍ ដោយប្រើអត្រាការប្រាក់ដើមដែលមានប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអ៊ីមែរមិនឥណទាន
នាការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចំណាយតាមថ្លៃដើមបានរំលស់ និងបំណុល ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅ FVOCI មានឥណទានអ៊ីមែរមិន (សំដៅដល់ “ដំណាក់កាលទី៣ ទ្រព្យសកម្មហិរញ្ញវត្ថុ”)។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឥណទានអ៊ីមែរមិន នៅពេលព្រឹត្តិការណ៍មួយឬច្រើន មានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរសាច់ប្រាក់ហិរញ្ញវត្ថុនាពេលអនាគតរបស់ទ្រព្យសកម្ម ហិរញ្ញវត្ថុបានកើតឡើង។

ភស្តុតាងដែលទ្រព្យសកម្មហិរញ្ញវត្ថុ មានអ៊ីមែរមិនឥណទាន រួមមានទិន្នន័យដែលអាចសង្កេតបានដូចខាងក្រោម៖

- បញ្ហាផ្នែកហិរញ្ញវត្ថុសំខាន់ៗ របស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ការរំលោភកិច្ចសន្យាដូចជាករណីហួសកាលកំណត់ ឬហួសកាលបរិច្ឆេទកំណត់
- ការរៀបចំឡើងវិញនូវឥណទានដោយធនាគារ តាមលក្ខខណ្ឌដែលធនាគារមិនដែលបានពិចារណាពីមុនមក
- វាអាចនឹងកើតឡើងដែលថាអ្នកខ្ចីនឹងចូលក្សីយធន ឬការរៀបចំហិរញ្ញវត្ថុឡើងវិញ ឬ
- អវត្តមាននៃទីផ្សារសកម្មមួយសម្រាប់ការជានាដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានគេពិចារណាឡើងវិញ ដោយសារតែការចាត់បង់គុណភាពនៅក្នុងស្ថានភាពរបស់អ្នកខ្ចីត្រូវបានគេចាត់ទុកថាជា អ៊ីមែរមិនឥណទាន លុះត្រាតែមានភស្តុតាងដែលបង្ហាញថាហានិភ័យ នៃការមិនទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះ គួរឱ្យកត់សម្គាល់ហើយមិនមានសូចនាករផ្សេងទៀតនៃអ៊ីមែរមិនឥណទាននោះទេ។

លើសពីនេះទៅទៀតឥណទានដែលហួសកាលកំណត់ រយៈពេល ៩០ ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬស្មើ ៣០ ថ្ងៃសម្រាប់ឥណទានរយៈពេលខ្លី ត្រូវបានគេចាត់ទុកថាមានអ៊ីមែរមិនឥណទាន។

ការបង្ហាញនូវសំវិធានធន ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
សំវិធានធនសម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់៖ ជាគណនី បញ្ច្រាសពីសមតុល្យយោងដុលរបស់ទ្រព្យសកម្ម។

ការលុបចេញ
ឥណទាន និងបុរេប្រទានត្រូវបានលុបចោល (ទាំងផ្នែកខ្លះ ឬពេញលេញ) នៅពេលគ្មានការរំពឹងទុកសមហេតុផលក្នុងការប្រមូលមកវិញនូវ ទ្រព្យសកម្មហិរញ្ញវត្ថុទាំងមូល ឬផ្នែកណាមួយឡើយ។ ជាទូទៅករណីនេះនៅពេលដែលធនាគារកំណត់ថា អ្នកខ្ចីមិនមានទ្រព្យសម្បត្តិ ឬប្រភពចំណូលដែលអាចបង្កើតលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីសងចំនួនដែលត្រូវបានលុបចោល។ ការវាយតម្លៃនេះត្រូវបានអនុវត្តតាម កម្រិតទ្រព្យសកម្មដាច់ដោយឡែក។

លទ្ធភាពក្នុងការប្រមូលមកវិញនូវសមតុល្យដែលបានលុបចោលពីមុន ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានលុបចោលអាចជាកម្មវត្ថុ នៃការអនុវត្តសកម្មភាព ដើម្បីឱ្យអនុលោមតាមនីតិវិធីរបស់ធនាគារ ក្នុងការប្រមូលត្រឡប់មកវិញនូវចំនួនដែលពុំទាន់បានសង។

២.៥.២ សាច់ប្រាក់ និងសាច់ប្រាក់សមមូល
សម្រាប់គោលបំណងក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារ

ផ្សេងៗ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសានុបីខែ ឬតិចជាងនេះ ដែលងាយស្រួលក្នុងការបំប្លែងជា សាច់ប្រាក់ជាក់លាក់ ហើយប្រឈមនឹងហានិភ័យបម្រែបម្រួលតម្លៃតិចតួច។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានយោងតាមតម្លៃដើមរំលស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

២.៥.៣ មូលធន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។ ការកើនឡើងនៃចំណាយដែលទាក់ទងដោយផ្ទាល់ក្នុងការចេញផ្សាយភាគហ៊ុនធម្មតាត្រូវបាន ទទួលស្គាល់ជាការកាត់ចេញពីមូលធន ផលប៉ះពាល់សារពើពន្ធសុទ្ធ។ ភាគហ៊ុនផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុលដោយផ្អែក ទៅលើស្ថានភាពសេដ្ឋកិច្ច នៃឧបករណ៍ហិរញ្ញវត្ថុជាក់លាក់ណាមួយ។ ការចែកចាយដល់អ្នកកាន់ឧបករណ៍ហិរញ្ញវត្ថុដែល ត្រូវបានចាត់ថ្នាក់ ជាឧបករណ៍មូលធនត្រូវបានកត់ត្រាដោយផ្ទាល់ក្នុងគណនីមូលធន។

ប្រាក់ចំណេញរក្សាទុក រួមបញ្ចូលប្រាក់ចំណេញរក្សាទុកក្នុង ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទមុនមកទាំងអស់។

២.៥.៤ ប្រាក់បម្រុងទូទៅ និងប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងទូទៅត្រូវបានបង្កើតឡើងជាចាំបាច់សម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅ។ ក្រុមប្រឹក្សាភិបាលអនុវត្តការសម្រេចចិត្តសម្រាប់ការប្រើប្រាស់ និងថែរក្សាប្រាក់បម្រុងទូទៅ។ ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅប្រាក់បម្រុងទូទៅ គឺត្រូវមានការអនុម័តពីក្រុមប្រឹក្សាភិបាល។

ប្រាក់បម្រុងកាតព្វកិច្ចត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃ សំវិធានធនរវាងការកំណត់ ECL អនុលោមតាម CIFRS ៩ ឧបករណ៍ហិរញ្ញវត្ថុ និងសំវិធានធនតាមបទប្បញ្ញត្តិ ដែលបានចែងដោយអនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា ប្រកាសលេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរលេខ ធ៧-០១៨-០០១ ស រ ណ ចុះថ្ងៃទី១៦ ខែកុម្ភ: ឆ្នាំ២០១៨ ស្តីពីការបែងចែកហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិនសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

សំវិធានធនតាមបទប្បញ្ញត្តិតម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុចែងចំណាត់ថ្នាក់ផលបត្រកម្ចីជាប្រាំថ្នាក់ និងសំវិធានធនទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃលើសកាលកំណត់	អត្រាទាយផ្ទទាន
ស្តង់ដា	០ ថ្ងៃដល់ ១៤ ថ្ងៃ (រយៈពេលខ្លី) ០ ថ្ងៃដល់ ២៩ ថ្ងៃ (រយៈពេលវែង)	១%
ឃ្លាំមើល	១៥ ថ្ងៃដល់ ៣០ ថ្ងៃ (រយៈពេលខ្លី) ៣០ ថ្ងៃដល់ ៨៩ ថ្ងៃ (រយៈពេលវែង)	៣%
ក្រោមស្តង់ដា	៣១ ថ្ងៃដល់ ៦០ ថ្ងៃ (រយៈពេលខ្លី) ៩០ ថ្ងៃដល់ ១៧៩ ថ្ងៃ (រយៈពេលវែង)	២០%
សង្ស័យ	៦១ ថ្ងៃដល់ ៩០ ថ្ងៃ (រយៈពេលខ្លី) ១៨០ ថ្ងៃដល់ ៣៥៩ ថ្ងៃ (រយៈពេលវែង)	៥០%
បាត់បង់	ចាប់ពី ៩១ ថ្ងៃ (រយៈពេលខ្លី) ៣៦០ ថ្ងៃឬ ច្រើនជាង (រយៈពេលវែង)	១០០%

ធនាគារត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាម CIFRS ៩ និងសំវិធានធនតាមបទប្បញ្ញត្តិ និង៖

- ក្នុងករណីសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិ ទាបជាងសំវិធានធនដែលបានគណនាស្របតាម CIFRS ៩ ធនាគារ ត្រូវកត់ត្រាសំវិធានធនតាម CIFRS ៩ និង
- ក្នុងករណីសំវិធានធនគណនាតាមបទប្បញ្ញត្តិ ខ្ពស់ជាងសំវិធានធនដែលបានគណនាស្របតាម CIFRS ៩ ធនាគារត្រូវកត់ត្រាសំវិធានធនតាម CIFRS ៩ និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅក្នុងគណនីប្រាក់បម្រុងកាតព្វកិច្ច។

នៅថ្ងៃទី៥ ខែកុម្ភ: ឆ្នាំ២០២៥ ធនាគារជាតិ នៃ កម្ពុជា (“NBC”) បានចេញសារាចរលេខ ធ៣០-០២៥-១៧០ ស.ជ.ណ លើការគណនាលើសំវិធានធនតាមបទប្បញ្ញត្តិ។ ធនាគារជាតិ នៃ កម្ពុជា (“NBC”) តម្រូវឱ្យគ្រប់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ (“BFIs”) គណនាសំវិធានធនតាមបទប្បញ្ញត្តិ ដោយប្រើនូវតម្លៃយោងដុលរបស់ឥណទាន ដែលរួមបញ្ចូលនូវការប្រាក់បង្គរត្រូវទទួល ដោយពឹងផ្អែកលើស្តង់ដាគណនេយ្យ គុណនឹងអត្រាដែលចែងដោយបទប្បញ្ញត្តិ (ស្តង់ដា ១% ឃ្លាំមើល ៣% ក្រោមស្តង់ដា ២០% សង្ស័យ ៥០% បាត់បង់ ១០០%)។ ការអនុវត្តថ្មីនេះត្រូវចាប់ផ្តើមពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មក្នុងឆ្នាំ២០២៤ និងរបាយការណ៍បទប្បញ្ញត្តិ ប្រចាំត្រីមាសចាប់ពីខែមករា ឆ្នាំ២០២៥ តទៅ។

២.៥.៥ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ ត្រូវបានកំណត់តាមថ្លៃដើមដក ECL។

២.៥.៦ ឥណទានទៅអតិថិជន

ឥណទានទៅអតិថិជន ត្រូវបានវាស់វែងជំបូងតាមតម្លៃសមស្របបូកការកែតម្រូវទៅលើថ្លៃដើមផ្ទាល់ក្នុងប្រតិបត្តិការ និងត្រូវបានវាស់វែង ជាបន្តបន្ទាប់តាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

២.៥.៧ ការវិនិយោគផ្សេងៗ

ការវិនិយោគផ្សេងៗ លើមូលធន រួមមានការវិនិយោគលើមូលធន និងការវិនិយោគលើប័ណ្ណបំណុល។

ការវិនិយោគលើមូលធន តំណាងឱ្យការវិនិយោគរបស់ធនាគារលើមូលបត្រដែលមិនបានចុះបញ្ជីដែលត្រូវបានកំណត់ថាជា FVTPL ហើយត្រូវបានវាយតម្លៃតាមថ្លៃដើមដកអ៊ីមភែរមិន។

ការវិនិយោគប័ណ្ណបំណុលតំណាងឱ្យការវិនិយោគរបស់ធនាគារលើប័ណ្ណរតនាគារ ដែលធានាដោយរដ្ឋាភិបាលកម្ពុជា។ ការវិនិយោគ ប័ណ្ណបំណុលទាំងនេះត្រូវបានគេវាយតម្លៃតាមថ្លៃដើមរំលស់ ហើយត្រូវបានរក្សាទុកក្នុងគោលបំណងដើម្បីទទួលបានការប្រាក់ ហើយមានលំហូរសាច់ប្រាក់ដែលត្រូវបានគេរំពឹងថានឹងប្រមូលបាននៅអំឡុងពេលអនាគតជាក់លាក់ណាមួយ។

២.៥.៨ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមថ្លៃដើម ដកអ៊ីមភែរមិន ប្រសិនបើមាន។

២.៥.៩ ទ្រព្យសម្រាប់លក់

ធនាគារចាត់ថ្នាក់ទ្រព្យថា ទ្រព្យសម្រាប់លក់ ប្រសិនបើតម្លៃយោងរបស់វា

នឹងត្រូវបានប្រមូលបានមកវិញ តាមរយៈប្រតិបត្តិការលក់ មិនមែនតាមរយៈការប្រើប្រាស់បន្ត។ ទ្រព្យអសកម្ម ដែលបានចាត់ថ្នាក់ថាជាទ្រព្យសម្រាប់លក់ ត្រូវបានវាស់វែងតាមតម្លៃទាបជាងគេ រវាងតម្លៃយោង និងតម្លៃសមស្រប ដកចំណាយលើការលក់។ ចំណាយលើការលក់ គឺជាថ្លៃដើមបន្ថែមដែលទាក់ទងដោយផ្ទាល់នឹងការលក់ទ្រព្យ (ឬការលក់ទ្រព្យជាក្រុម) ដែលមិនរួមបញ្ចូលថ្លៃដើមហិរញ្ញវត្ថុ និងចំណាយពន្ធលើប្រាក់ចំណូល។

លក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់ថ្នាក់ថាជា ទ្រព្យសម្រាប់លក់ គឺត្រូវបានចាត់ទុកថាបានបំពេញតែនៅពេលដែលការលក់គឺទំនងជាខ្ពស់, ហើយទ្រព្យឬការលក់ទ្រព្យជាក្រុម អាចរកបានសម្រាប់ការលក់ភ្លាមៗនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់វា។ សកម្មភាពដែលចាំបាច់សម្រាប់បំពេញការលក់ គួរតែកំណត់ថាវាទំនងជាមិនមានការប្រែប្រួលខ្លាំងទៅនឹងការលក់ដែល នឹងត្រូវធ្វើឡើង ឬការសម្រេចចិត្តលក់នឹងត្រូវបានដកចេញ។ គណៈគ្រប់គ្រងត្រូវតែមានការប្តេជ្ញា

បាន ត្រូវបានធ្វើមូលធនកម្មផ្អែកលើមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទាញយកកម្មវិធីកុំព្យូទ័រជាក់លាក់សម្រាប់នាំយកទៅប្រើប្រាស់។

ថ្លៃដើមកម្មវិធីកុំព្យូទ័រ ត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុករយៈពេល ១០ ឆ្នាំ។

ថ្លៃដើមដែលទាក់ទងជាមួយការអភិវឌ្ឍ ឬថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលថ្លៃដើមទាំងនោះកើតឡើង។

២.៥.១២ ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យាមាន ឬមិនមានភតិសន្យា ប្រសិនបើកិច្ចសន្យាមានសិទ្ធិគ្រប់គ្រងការប្រើប្រាស់ ទ្រព្យសកម្មដែលបានកំណត់ក្នុងរយៈពេលកំណត់ជាថ្នូរនឹងតម្លៃតបស្នង។

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាមានសិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ ធនាគារវាយតម្លៃថាតើ៖

- កិច្ចសន្យាពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ - នេះអាចត្រូវបានបញ្ជាក់ច្បាស់ ឬមិនច្បាស់លាស់ហើយ គួរតែមានភាពខុសគ្នាលើរូបរាង ឬតំណាងឱ្យសមាសភាពរបស់ទ្រព្យសកម្មទាំងអស់ដែលមានលក្ខណៈរូបរាងខុសគ្នា។ ប្រសិនបើអ្នកផ្គត់ផ្គង់ មានសិទ្ធិយកទ្រព្យសកម្មផ្សេងមកជំនួសក្នុងរយៈពេលនៃការប្រើប្រាស់ នោះទ្រព្យសកម្មនេះ មិនត្រូវបានកំណត់ជាក់លាក់ទេ
- ធនាគារមានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន ពីការប្រើប្រាស់ទ្រព្យសកម្មក្នុងអំឡុងពេលប្រើប្រាស់ និង
- ធនាគារមានសិទ្ធិក្នុងការប្រើទ្រព្យសកម្មដោយផ្ទាល់។ ធនាគារមានសិទ្ធិនេះនៅពេលដែលខ្លួនមានសិទ្ធិធ្វើការសម្រេចចិត្តដែល ពាក់ព័ន្ធបំផុតក្នុងការផ្លាស់ប្តូរបៀប និងគោលបំណងសម្រាប់ទ្រព្យសកម្មដែលត្រូវបានប្រើប្រាស់។ ក្នុងករណីដែលការសម្រេចចិត្ត ទាំងអស់អំពីរបៀបនិងសម្រាប់គោលបំណងអ្វី ដែលទ្រព្យត្រូវបានប្រើប្រាស់ត្រូវបានកំណត់ទុកជាមុន ធនាគារមានសិទ្ធិដឹកនាំ ការប្រើប្រាស់ទ្រព្យ ប្រសិនបើ៖
  i) ធនាគារមានសិទ្ធិធ្វើប្រតិបត្តិការទ្រព្យសកម្ម ឬ
  ii) ធនាគារបានរចនាទ្រព្យសកម្មតាមរបៀប ដែលកំណត់ទុកជាមុននូវរបៀបនិងគោលបំណងអ្វីដែលនឹងត្រូវប្រើប្រាស់។

នៅពេលចាប់ផ្តើម ឬវាយតម្លៃឡើងវិញនូវកិច្ចសន្យា ដែលមានសមាសធាតុភតិសន្យា និងសមាសធាតុមិនមែនភតិសន្យា ធនាគារបែងចែកតាមតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យានីមួយៗ និងសមាសធាតុផ្សំដែលមិនមែនជាភតិសន្យា ដោយផ្អែកលើថ្លៃឈ្នួលដាច់ដោយឡែក។ ទោះយ៉ាងណាក៏ដោយ ភតិសន្យាដី និងអគារដែលធនាគារក្នុងនាមជាភតិបតី ធនាគារបានជ្រើសរើស ការគណនាមិនបំបែកសមាសធាតុមិនមែនភតិសន្យា ហើយត្រូវរាប់បញ្ចូលសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាទៅជាសមាសធាតុនៃភតិសន្យាតែមួយ។

ភតិសន្យាដែលធនាគារជាភតិក:

ការរៀបចំមួយបានបង្ហាញពីសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ប្រសិនបើលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- អ្នកទិញមានសមត្ថភាព ឬសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ខណៈពេលដែលទទួលបាន ឬគ្រប់គ្រងលើសពីចំនួនតិចតួច នៃលទ្ធផលទាំងនោះ ឬ
- អ្នកទិញមានសមត្ថភាព ឬសិទ្ធិក្នុងការគ្រប់គ្រងសិទ្ធិប្រើប្រាស់រូបវន្តក្នុងអំឡុងពេលទទួលបានឬគ្រប់គ្រងលើសពីចំនួនតិចតួច នៃលទ្ធផលទាំងនោះ។

កត្តា និងកាលៈទេសៈបានបង្ហាញថាមានដាច់ឆ្ងាយដែលថាភាគីផ្សេងទៀតនឹងទទួលបានច្រើនជាងចំនួនតិចតួច ហើយតម្លៃក្នុងមួយឯកតា មិនត្រូវបានកំណត់ក្នុងមួយឯកតានៃទិន្នផលទេហើយស្មើនឹងតម្លៃទីផ្សារបច្ចុប្បន្នក្នុងមួយឯកតានៃលទ្ធផលទាំងនេះ។

ធនាគារទទួលស្គាល់នូវសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យានៅការិយបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់លើ ទ្រព្យសកម្មវាស់វែងដំបូងតាមថ្លៃដើម ដែលរួមមានតម្លៃដំបូងនៃបំណុលភតិសន្យាដែលបានកែតម្រូវសម្រាប់ការទូទាត់ភតិសន្យា ដែលបានធ្វើឡើង នៅ ឬមុនការិយបរិច្ឆេទចាប់ផ្តើមបូករួមនឹងថ្លៃដើមដំបូងដែលបានកើតឡើងដោយផ្ទាល់ និងការប៉ាន់ស្មាននៃចំណាយដើម្បីរុះរើ និងដកចេញទ្រព្យសកម្មមូលដ្ឋាន ឬទ្រព្យសម្បត្តិមូលដ្ឋានដែលបានស្ថារឡើងវិញ ឬទីតាំងដែលទ្រព្យទាំងនោះស្ថិតនៅតិចជាងភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ដែលត្រូវប្រើត្រូវបានរំលស់ជាបន្តបន្ទាប់ដោយប្រើវិធីសាស្ត្ររំលស់ថេរ ចាប់ពីការិយបរិច្ឆេទចាប់ផ្តើមរហូតដល់ ចុងបញ្ចប់នៃរយៈពេលភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មដែលបានប៉ាន់ស្មានត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចគ្នាទៅនឹង ទ្រព្យ និងបរិក្ខារ។ លើសពីនេះទៀតសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាទៀងទាត់ដោយការខាតអ៊ីមតែរមិនប្រសិនបើមាន ហើយត្រូវបានកែតម្រូវសម្រាប់ការវាស់វែងឡើងវិញយ៉ាងជាក់លាក់នៃបំណុលភតិសន្យា។

អាយុកាលប្រើប្រាស់ ដែលបានប៉ាន់ស្មាននៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម រួមមានការភតិសន្យាការិយាល័យកណ្តាល ការិយាល័យសាខា និងទីតាំង ATM មានអាយុកាលចាប់ពីចន្លោះ ១៤ខែ ទៅ ១៥ឆ្នាំ។

បំណុលភតិសន្យាត្រូវបានវាស់ដំបូងតាមតម្លៃបច្ចុប្បន្ន នៃការទូទាត់ភតិសន្យាដែលមិនត្រូវបានបង់នៅកាលបរិច្ឆេទចាប់ផ្តើមនៃអប្បហារ ដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬប្រសិនបើអត្រានេះមិនអាចត្រូវបានកំណត់យ៉ាងងាយទៅនឹងប្រាក់កម្ចីបន្ថែមរបស់ធនាគារ។ ជាទូទៅធនាគារប្រើអត្រាកម្ចីបន្ថែមរបស់ខ្លួនជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យាដែលមាននៅក្នុងការវាស់វែងនៃបំណុលភតិសន្យារួមមាន៖

- ការទូទាត់ថេររួមទាំងការទូទាត់ជារូបធាតុនៃការទូទាត់ថេរ
- ការទូទាត់ភតិសន្យាអថេរដែលពឹងផ្អែកលើសន្ទស្សន៍ ឬអត្រាមួយដែលវាស់វែងដំបូងដោយប្រើសន្ទស្សន៍ឬអត្រានៅ ការិយបរិច្ឆេទចាប់ផ្តើម
- សមតុល្យដែលរំពឹងថានឹងត្រូវបង់ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃដែលស្ថិតនៅក្រោមជម្រើសនៃការទិញដែលធនាគារមានភាពប្រាកដប្រជា ដើម្បីអនុវត្តភតិសន្យានេះ ក្នុងរយៈពេលជម្រើសបន្ត និងប្រសិនបើធនាគារមានភាពប្រាកដប្រជាក្នុងការប្រើប្រាស់ជម្រើសបន្ថែម និងការផាកពិន័យសម្រាប់ការបញ្ចប់ភតិសន្យា មុនកាលកំណត់ លុះត្រាតែធនាគារមានភាពជាក់លាក់ដោយសមហេតុផល ប៉ុន្តែមិនត្រូវបញ្ចប់មុនកំណត់ឡើយ។

បំណុលភតិសន្យាត្រូវបានវាស់វែងតាមថ្លៃដើមបាន រំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានវាស់វែងឡើងវិញនៅពេល មានការផ្លាស់ប្តូរយ:ពេលភតិសន្យា ការផ្លាស់ប្តូរពីការវាយតម្លៃនៃជម្រើសក្នុងការទិញទ្រព្យសកម្មមូលដ្ឋាន ការផ្លាស់ប្តូរការទូទាត់ភតិសន្យានៅពេលអនាគតដែលកើតឡើងពីការផ្លាស់ប្តូរសន្ទស្សន៍ ឬអត្រា ឬប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានរបស់ធនាគារលើសមតុល្យ ដែលរំពឹងថានឹងត្រូវបង់ក្រោមការធានាតម្លៃសំណល់។

នៅពេលដែលបំណុលភតិសន្យាត្រូវបានអនុវត្តតាមវិធីសាស្ត្រវាស់វែងឡើងវិញ ការកែតម្រូវដែលត្រូវគ្នាត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬត្រូវបានកត់ក្នុងប្រាក់ចំណេញឬ ខាត ប្រសិនបើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបាន កាត់បន្ថយឱ្យស្មើសូន្យ។

ធនាគារបង្ហាញសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យាដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ភតិសន្យារយៈពេលខ្លី និងភតិសន្យាទ្រព្យសកម្មដែលមានតម្លៃទាប
ធនាគារបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ភតិសន្យារយៈពេលខ្លី (ពោលគឺ ភតិសន្យាមានកាលកំណត់ ១២ខែ ឬ តិចជាងនេះ) ហើយភតិសន្យានៃទ្រព្យសកម្មតម្លៃទាប។ ធនាគារទទួលស្គាល់ការទូទាត់ភតិសន្យា ដែលទាក់ទងនឹងភតិសន្យាទាំងនេះ ជាការចំណាយផ្អែកលើមូលដ្ឋានរំលស់ថេរលើភតិសន្យាមានកាលកំណត់។

២.៥.១៣ អត្ថប្រយោជន៍របស់និយោជិត
(ក) អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី
ធនាគារទទួលស្គាល់បំណុល និងសំវិធានធនអត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី ដែលវាមានកាតព្វកិច្ចតាមកិច្ចសន្យា ឬតាមការអនុវត្តកន្លងមក ដែលបានបង្កើតតាមកាតព្វកិច្ចតាមបទប្បញ្ញត្តិ។

ប្រាក់ឈ្នួល ប្រាក់បៀវត្ស បុព្វលាភ និងអត្ថប្រយោជន៍រយៈពេលខ្លីផ្សេងទៀត ត្រូវបានទទួលស្គាល់ជាការចំណាយក្នុងឆ្នាំ ដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ ដោយនិយោជិតរបស់ធនាគារ។

(ខ) អត្ថប្រយោជន៍ក្រោយបំពេញការងារ
អត្ថប្រយោជន៍ក្រោយបំពេញការងារ រួមមានបំណុលរបស់ធនាគារទៅនិយោជិតលើ ទូទាត់ប្រាក់បំណាច់ អតីតភាពការងារ និងការឈប់សម្រាកប្រចាំឆ្នាំ។

ការទូទាត់សំណងប្រាក់បំណាច់អតីតភាពការងារ
នៅឆ្នាំ២០១៨ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (“MoLVT”) បានចេញប្រកាសលេខ ៤៤៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការអនុវត្តការ ទូទាត់ប្រាក់អតីតភាពការងារសម្រាប់និយោជិតដែលបានចុះកិច្ចសន្យាក្នុងចិរវេលាមិនជាក់លាក់ ដែលបានអនុវត្ត តាមការអនុម័តប្រកាសចុះនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។ ប្រកាសនេះតម្រូវឱ្យមានការផ្តល់ប្រាក់អតីតភាពការងារម្តងទៀតស្មើនឹង ដប់ប្រាំថ្ងៃក្នុងមួយឆ្នាំរបស់និយោជិត ដែលនឹងត្រូវផ្តល់ឱ្យពួកគេក្នុងអតិបរមាមិនលើសពីចំនួន ៦ខែ ដែលគណនាទៅតាមប្រាក់បៀវត្ស មធ្យមសុទ្ធសម្រាប់ឆ្នាំនីមួយៗ។

ការទូទាត់ត្រូវបានធ្វើឡើងនៅរៀងរាល់ខែមិថុនា និងខែធ្នូសម្រាប់ឆ្នាំនីមួយៗ ដូចខាងក្រោម៖
- ស្មើនឹង ៣ ថ្ងៃ នឹងធ្វើឡើងជារៀងរាល់ខែមិថុនា
- ស្មើនឹង ៣ ថ្ងៃ នឹងធ្វើឡើងជារៀងរាល់ខែធ្នូ។

ការឈប់សម្រាកប្រចាំឆ្នាំ
ធនាគារផ្តល់ជូននិយោជិតដែលកំពុងបំពេញការងារ នូវអត្ថប្រយោជន៍ក្រោមគម្រោងអត្ថប្រយោជន៍ នៃការឈប់សម្រាកប្រចាំឆ្នាំ។ និយោជិតអាចយោងការឈប់សម្រាកប្រចាំឆ្នាំដែលមិនបានប្រើបានទៅដល់ ៦ថ្ងៃ និងត្រូវប្រើប្រាស់ថ្ងៃឈប់សម្រាកដែលយោងពីឆ្នាំមុនក្នុងរយៈពេល ៦ ខែនៃឆ្នាំបន្ទាប់ បើមិនដូច្នោះទេ សមតុល្យនឹងត្រូវបានបាត់បង់។

ចំនួនឆ្នាំដែលបានបំពេញ សេវាកម្ម	ថ្ងៃឈប់សម្រាកប្រចាំឆ្នាំ
ចាប់ពី ១ ទៅ ៣ឆ្នាំ	១៨ថ្ងៃ ក្នុងមួយឆ្នាំ
ចាប់ពី ៤ ទៅ ៦ឆ្នាំ	១៩ថ្ងៃ ក្នុងមួយឆ្នាំ
ចាប់ពី ៧ ទៅ ៩ឆ្នាំ	២០ថ្ងៃ ក្នុងមួយឆ្នាំ
ចាប់ពី ១០ ឡើងទៅ	២១ថ្ងៃ ក្នុងមួយឆ្នាំ

២.៥.១៤ ប្រាក់បញ្ញើជាបំណុល
ប្រាក់បញ្ញើជាបំណុល ត្រូវបានកំណត់តាមសមតុល្យដែលគេត្រូវបានទូទាត់។ ការប្រាក់បានបង្គរជារៀងរាល់កាលបរិច្ឆេទ និងត្រូវបានទទួលស្គាល់ជាគណនីបំណុលដាច់ដោយឡែក មុននឹងទទួលស្គាល់ជាផ្នែកមួយរបស់គណនីបញ្ញើបំណុល។

២.៥.១៥ សំវិធានធន
សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេល ដែលធនាគារ មានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលថាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវបានទាមទារដើម្បីដោះស្រាយ កាតព្វកិច្ច។ ប្រសិនបើផលប៉ះពាល់មានភាពជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយតម្លៃអប្បហារ ការថយចុះនៃលំហូរសាច់ប្រាក់ នាពេលអនាគតដែលរំពឹងទុក ក្នុងអត្រាពន្ធមុនដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងនៅពេលដែលមាន ភាពសមស្របហានិភ័យជាក់លាក់របស់បំណុល។ មិនមានតម្លៃអប្បហារ ត្រូវបានទទួលស្គាល់ថាជាចំណាយហិរញ្ញវត្ថុ។

២.៥.១៦ ការប្រាក់
អត្រាការប្រាក់ប្រសិទ្ធភាព
ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាអប្បហារតម្លៃយ៉ាងជាក់លាក់ដែលប៉ាន់ស្មានការទូទាត់សាច់ប្រាក់នាពេលអនាគត ឬវិក្កយបត្រតាមរយៈ អាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុទៅ៖
- តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង
- ថ្លៃដើមបានរំលស់លើបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលមានអ៊ីមុតែរមិនលើឥណទាន ដែលបានទិញ ឬទទួលបាន ធនាគារប៉ាន់ស្មាន លំហូរសាច់ប្រាក់នាពេលអនាគត ដោយពិចារណា

លើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែន ECL នោះទេ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអ៊ីមែរមិនលើឥណទាន នៅពេលទិញ ឬ នៅពេលបង្កើតអត្រាការប្រាក់ប្រសិទ្ធភាពកែតម្រូវឥណទាន ត្រូវបានគណនាដោយប្រើលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានរួមទាំង ECL ផងដែរ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមមានថ្លៃប្រតិបត្តិការ និងកម្រៃសេវា ដែលជាផ្នែកសំខាន់នៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមានប្រាក់កម្ចីបន្ថែម ដែលត្រូវបានបែងចែកដោយផ្ទាល់ទៅនឹងការទទួលបាន ឬចេញផ្សាយ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

ថ្លៃដើមរំលស់ និងតម្លៃយោងដុល

'ថ្លៃដើមរំលស់' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាតម្លៃដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបាន វាស់វែងនៅពេលទទួលស្គាល់ដំបូងដកការទូទាត់ប្រាក់ដើម ការបូកឬដករំលស់បង្គរ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព មាន ភាពខុសគ្នានៃតម្លៃដំបូង និងតម្លៃនៅកាលវសាន្ត ហើយសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ បានធ្វើការកែតម្រូវលើ សំវិធានធនខាតបង់នៃឥណទានរំពឹងទុក។

'តម្លៃយោងដុល' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ជាថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុមុនពេលធ្វើការកែតម្រូវលើសំវិធានធនខាតបង់ឥណទានរំពឹងទុក។

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូល និងចំណាយការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តទៅលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យនោះមិនមានអ៊ីមែរមិនលើឥណទាន) ឬថ្លៃដើមបានរំលស់លើបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានកែប្រែ ដែលជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញ តាមកាលកំណត់នៃលំហូរសាច់ប្រាក់ នៃអត្រាការប្រាក់អណ្តែតដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលទីផ្សារអត្រាការប្រាក់។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវបានកែប្រែ សម្រាប់ការកែតម្រូវការបង្ការហានិភ័យ លើតម្លៃសមស្រប នាការិយបរិច្ឆេទនៃការធ្វើរំលស់លើការបង្ការហានិភ័យដែលកែតម្រូវនេះបានចាប់ផ្តើម។

ទោះយ៉ាងណាក៏ដោយ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានអ៊ីមែរមិនលើឥណទានជាបន្តបន្ទាប់ទៅនឹងការទទួលស្គាល់ដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពតាមថ្លៃដើមបានរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មទាំងនោះ លែងមានអ៊ីមែរមិនលើឥណទាន បន្ទាប់មកការគណនាចំណូលការប្រាក់នឹងត្រលប់ទៅមូលដ្ឋានសរុបវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានការទទួលស្គាល់អ៊ីមែរមិនលើឥណទាន ពេលទទួលស្គាល់ដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តតាម អត្រាការប្រាក់មានប្រសិទ្ធភាពនៃការកែតម្រូវឥណទានទៅលើថ្លៃដើមបានរំលស់របស់ទ្រព្យសកម្ម។ ការគណនាចំណូលការប្រាក់មិនត្រឡប់ទៅមូលដ្ឋានសរុបទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មមានភាពប្រសើរឡើងក៏ដោយ។

ការបង្ហាញ

ចំណូលការប្រាក់ និងចំណាយការប្រាក់ដែលបានកំណត់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ត្រូវបានធ្វើការបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

២.៥.១៧ កម្រៃសេវា និងកម្រៃជើងសា

ចំណូល និងចំណាយលើកម្រៃសេវា និងកម្រៃជើងសាដែលជាផ្នែកមួយនៃអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្ម ឬ បំណុលហិរញ្ញវត្ថុ ដែលត្រូវបានរាប់បញ្ចូលក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ប្រាក់ចំណូលកម្រៃសេវា និងកម្រៃជើងសាផ្សេងទៀត រួមទាំងកម្រៃសេវាគណនីត្រូវបានទទួលស្គាល់ថាសេវាកម្មពាក់ព័ន្ធត្រូវបានបំពេញ។

កិច្ចសន្យាជាមួយអតិថិជន ដែលទទួលបានលទ្ធផលជាឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារអាចជាផ្នែកខ្លះនៃវិសាលភាពរបស់ CIFRS ៩ និងផ្នែកខ្លះនៃវិសាលភាពរបស់ CIFRS ១៥ ប្រាក់ចំណូលកិច្ចសន្យាជាមួយ អតិថិជន។ ប្រសិនបើក្នុងករណីនេះ ធនាគារអនុវត្ត CIFRS ៩ ដំបូងដើម្បីបំបែកនិងវាស់ផ្នែកនៃកិច្ចសន្យាដែលស្ថិតក្នុងវិសាលភាពរបស់ CIFRS ៩ និងបន្ទាប់មកបានអនុវត្តតាម CIFRS ១៥ លើចំនួនដែលនៅសល់។

២.៥.១៨ ចំណូលភាគលាភ

ចំណូលភាគលាភត្រូវបានទទួលស្គាល់នៅពេលសិទ្ធិរបស់ធនាគារ ពីការទទួលបានការទូទាត់នោះត្រូវបានកើតឡើង។

២.៥.១៩ អ៊ីមែរមិននៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ធនាគារ ក្រៅពីសន្និធិ ទ្រព្យសកម្មក្នុងកិច្ចសន្យា ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនាការិយបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានសូចនាករណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានអ៊ីមែរមិន។ ប្រសិនបើមានសូចនាករនោះកើតឡើង តម្លៃនៃទ្រព្យសកម្ម ដែលអាចប្រមូលបានមកវិញត្រូវបានប៉ាន់ស្មាន។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់គ្មានកំណត់ ឬ ដែលមិនទាន់រួចរាល់សម្រាប់ប្រើប្រាស់ តម្លៃដែលអាចប្រមូលបានត្រូវបានប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ។

ការខាតអ៊ីមែរមិនត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មឬឯកតាបង្កើតសាច់ប្រាក់ ("CGU") លើសពីតម្លៃដែលអាចប្រមូលបានមកវិញ។

តម្លៃដែលអាចប្រមូលបានមកវិញនៃទ្រព្យសកម្មឬ CGU គឺជាតម្លៃធំជាងរវាង តម្លៃនៃការប្រើប្រាស់ និងតម្លៃសមស្របដកចំណាយក្នុងការលក់។ ក្នុងការវាយតម្លៃទៅលើតម្លៃប្រើប្រាស់ លំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មាន ត្រូវបានធ្វើអប្បហារតម្លៃ ទៅជាតម្លៃបច្ចុប្បន្នដោយប្រើអត្រាអប្បហារពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្នអំពីតម្លៃពេលវេលា និងហានិភ័យជាក់លាក់លើ ទ្រព្យសកម្មឬ CGU។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើអ៊ីមែរមិន ទ្រព្យសកម្មដែលមិនអាចធ្វើតេស្តដាច់ដោយឡែក ត្រូវបានដាក់ជាក្រុមរួមគ្នាទៅជា ក្រុមតូចបំផុតនៃទ្រព្យសកម្ម ដែលបង្កើតលំហូរសាច់ប្រាក់ពីការប្រើប្រាស់បន្តហើយ

ភាគច្រើនស្ថិតនៅក្រៅលំហូរសាច់ប្រាក់ នៃទ្រព្យសកម្ម ផ្សេងទៀត ឬ CGUs។

ការខាតអ៊ីមភែរមិន ត្រូវបានទទួលស្គាល់លើរបាយការណ៍ចំណេញ ឬខាត។ ការខាតអ៊ីមភែរមិនបានទទួលស្គាល់លើ CGUs ត្រូវបានបែងចែកដំបូង ដើម្បីកាត់បន្ថយ តម្លៃយោងដែលបានបែងចែកទៅ CGU និងបន្ទាប់មក កាត់បន្ថយតម្លៃយោងរបស់ទ្រព្យសកម្មផ្សេងៗទៀត នៅក្នុង CGUs លើមូលដ្ឋាន Pro Rata។

លើកលែងតែមូលនិធិពាណិជ្ជកម្ម ការខាតអ៊ីមភែរមិនដែលបានទទួលស្គាល់ក្នុងអំឡុងពេលមុនៗ ត្រូវបានវាយតម្លៃនៅការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ សូចនាករណាមួយដែលបង្ហាញថាការខាតត្រូវបានថយចុះ ឬលែងមានទៀតហើយ។ ការខាតអ៊ីមភែរមិន ត្រូវបានកត់ត្រាបញ្រ្ចាស ប្រសិនបើមានការផ្លាស់ប្តូរការប៉ាន់ស្មានដើម្បីកំណត់តម្លៃដែលអាចប្រមូលបានមកវិញ។ ការខាតអ៊ីមភែរមិន ត្រូវបានកត់ត្រាបញ្រ្ចាស ទៅនឹងទំហំដែលតម្លៃយោងរបស់ទ្រព្យសកម្ម ដោយមិនលើសពីតម្លៃយោងដែលបានកំណត់ការដករំលស់សុទ្ធ ឬរំលស់ទ្រព្យសកម្មអរូបី ប្រសិនបើមិនមានការទទួលស្គាល់លើការខាតអ៊ីមភែរមិន។

២.៥.២០ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលរួមមានពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែសមាសធាតុ ដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬនៅក្នុងលទ្ធផលពេញលេញផ្សេងទៀត។

ធនាគារបានកំណត់ថាការប្រាក់ និងការពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណូល រួមទាំងការកំណត់ពន្ធមិនប្រាកដប្រជា ភាពខុសពីនិយមន័យ នៃពន្ធលើប្រាក់ចំណូល ហើយដូច្នេះបានរាប់បញ្ចូលគណនីទាំងនេះក្រោម CIAS ៣៧ សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព និងបានទទួលស្គាល់ការចំណាយដែលពាក់ព័ន្ធទាំងនេះនៅក្នុង 'ការចំណាយផ្សេងៗ'។

បន្ទាប់ពីការអនុម័ត CIFRSs អគ្គនាយកដ្ឋានពន្ធដារ (“GDT”) មិនបានបង្ហាញពីការផ្លាស់ប្តូរមូលដ្ឋានពន្ធក្នុងការគណនាពន្ធពីផលប៉ះពាល់ ពន្ធនៃការផ្លាស់ប្តូរទៅ CIFRSs ទេ។ ធនាគារបានអនុវត្តការវិនិច្ឆ័យលើសំវិធានធនពន្ធដែលត្រូវបង់ និងពន្ធពន្យារ។ ការប្រើប្រាស់ការសន្មតខុសៗគ្នាអាចនាំឱ្យមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ បំណុលពន្ធបច្ចុប្បន្ន និងពន្ធពន្យាររបស់ធនាគារ ត្រូវស្ថិតក្រោមការកំណត់ជាមួយអគ្គនាយកដ្ឋានពន្ធដារ។

(i) ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួលបានលើប្រាក់ចំណូលជាប់ពន្ធសម្រាប់រយៈពេលដែលប្រើប្រាស់អត្រាពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តជាធរមាននាការិយបរិច្ឆេទនៃរបាយការណ៍ និងការកែតម្រូវពន្ធដែលត្រូវបង់គិតក្នុងការិយបរិច្ឆេទមុនៗ។

(ii) ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ចំពោះ ភាពខុសគ្នាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល សម្រាប់គោលបំណង របាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងដែលត្រូវប្រើសម្រាប់គោលបំណងពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ចំពោះការខាតពន្ធដែលមិនបានប្រើប្រាស់ និង ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន ហើយទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើបាន បើប្រៀបធៀបនឹងប្រាក់ចំណេញ ដែលអាចប្រើប្រាស់បាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានពិនិត្យក្នុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ និងបានកាត់បន្ថយក្នុងកម្រិតដែលវាអាចនឹងមិនអាចទទួលបាននូវអត្ថប្រយោជន៍ពន្ធ ដែលពាក់ព័ន្ធ។ ការកាត់បន្ថយបែបនេះ ត្រូវបានកត់ត្រាបញ្រ្ចាសនៅពេលដែលលទ្ធភាពនៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានភាពប្រសើរឡើង។ ពន្ធពន្យារត្រូវបានកំណត់តាមអត្រាពន្ធដែលរំពឹងថានឹងត្រូវបានអនុវត្ត ចំពោះភាពខុសគ្នាបណ្តោះអាសន្ន នៅពេលដែលពួកគេផ្លាស់ប្តូរដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬត្រូវបានអនុម័តជាធរមាននាការិយបរិច្ឆេទនៃរបាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងពីផលវិបាកពន្ធដែល នឹងអនុវត្តតាមលក្ខណៈដែលធនាគាររំពឹងថានាការិយបរិច្ឆេទនៃរបាយការណ៍ ដើម្បីប្រមូលមកវិញ ឬទូទាត់លើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវបានទូទាត់សងក្នុងករណីតម្រូវការជាក់លាក់មួយ។

២.៥.២១ មូលនិធិពាណិជ្ជកម្ម

មូលនិធិពាណិជ្ជកម្ម ត្រូវបានវាស់វែងដំបូងតាមតម្លៃដើម (ជាចំនួនលើសនៃតម្លៃតបស្នងដែលបានផ្ទេរ និងតម្លៃដែលបាន ទទួលស្គាល់របស់ភាគហ៊ុនមិនមានអភិបាលភាព និងអត្ថប្រយោជន៍ដែលមានពីមុន ដែលកាន់កាប់លើទ្រព្យសកម្មដែលអាចកំណត់ អត្តសញ្ញាណសុទ្ធដែលនឹងទទួលបាន និងបំណុលដែលបានសន្មត)។ ប្រសិនបើតម្លៃសមស្របរបស់តម្លៃសុទ្ធនៃទ្រព្យសកម្មមាន ចំនួនច្រើនជាតម្លៃទទួលបានពីការទិញលក់ ធនាគារត្រូវធ្វើការវាយតម្លៃសារឡើងវិញថាតើទ្រព្យសកម្ម និងបំណុលទាំងអស់ត្រូវបានគណនាដោយភាពត្រឹមត្រូវ និងការទទួលស្គាល់នាការិយបរិច្ឆេទនៃការទិញដែរ ឬទេ។ ប្រសិនបើការវាស់វែងឡើងវិញនៅតែផ្តល់ លទ្ធផលថា តម្លៃសមស្របនៃតម្លៃសុទ្ធរបស់ទ្រព្យសកម្មធំជាងតម្លៃទទួលបានពីការផ្ទេរ ផលចំណេញទាំងនោះត្រូវបានទទួលស្គាល់ក្នុង របាយការណ៍ចំណេញ ឬខាត។

បន្ទាប់ពីការទទួលស្គាល់ដំបូង មូលនិធិពាណិជ្ជកម្មត្រូវបាន វាស់វែងតាមថ្លៃដើមដកខាតអ៊ីមភែរមិនបង្គរ។ មូលនិធិពាណិជ្ជកម្មត្រូវធ្វើតេស្តអ៊ីមភែរមិន យ៉ាងតិចណាស់មួយឆ្នាំម្តង។ សម្រាប់គោលបំណងក្នុងការធ្វើតេស្តអ៊ីមភែរមិនមូលធនពាណិជ្ជកម្មដែលកើតឡើង នៅពេលរួមបញ្ចូលគ្នា ឬចាប់ពីការិយបរិច្ឆេទនៃការទិញ ត្រូវបានបែងចែកតាមឯកតាបង្កើតសាច់ប្រាក់នីមួយៗរបស់ធនាគារ ដែលនឹងរំពឹងថាមានអត្ថប្រយោជន៍កើតឡើងពីការរួមបញ្ចូលគ្នា ដោយមិនគិតពីទ្រព្យសកម្ម ឬបំណុលរបស់ភាគី ដែលត្រូវបានទិញ។

នៅពេលមូលនិធិពាណិជ្ជកម្ម ត្រូវបានបែងចែកទៅឯកតាបង្កើតសាច់ប្រាក់ហើយផ្នែកមួយ នៃអង្គភាពនេះត្រូវបានលក់ មូលធនពាណិជ្ជកម្ម ដែលទាក់ទងនឹងប្រតិបត្តិការដែលបានលក់ ត្រូវបានដាក់បញ្ចូលទៅក្នុងសមតុល្យយោងនៃប្រតិបត្តិការ នៅពេលគណនាទៅលើផល ចំណេញ ឬខាត

ក្នុងពេលលក់។ ក្នុងករណីនេះ មូលធនពាណិជ្ជកម្មដែលបានលក់ត្រូវបានគណនាតាមតម្លៃប្រតិបត្តិការដែលបាន លក់ និងបានដកចេញនូវចំណែកនៃឯកតាបង្កើតសាច់ប្រាក់ដែលបានរក្សាទុកទាំងនោះ។

២.៥.២២ បំណុលយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាព ដែលថាលំហូរចេញនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនឹងត្រូវបានទាមទារ ឬចំនួនមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ និងត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែ ប្រូបាប៊ីលីតេនៃលំហូរចេញនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចគឺស្ទើតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬ ការមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាបំណុលជាប់លាប់ផងដែរដរាបណាប្រូបាប៊ីលីតេ នៃលំហូរចេញនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៅស្ទើតែគ្មាន។

២.៥.២៣ ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពលំហូរចូលនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ឬសមតុល្យមិនអាចត្រូវបានប៉ាន់ស្មានបានទេ ហើយទ្រព្យសកម្ម មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងត្រូវបានបង្ហាញជាទ្រព្យសកម្មបន្តលើកលែងតែប្រូបាប៊ីលីតេនៃ លំហូរចូលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចគឺស្ទើរតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមានអាចត្រូវបានបញ្ជាក់ពីការកើតឡើង ឬមិនកើតឡើងនូវព្រឹត្តិការណ៍មួយឬច្រើនត្រូវបានបង្ហាញផងដែរក្នុងនាមជាទ្រព្យសកម្មយថាភាព លើកលែងតែលំហូរចូលពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច គឺស្ទើរតែគ្មាន។

២.៥.២៤ ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយធនាគារ។ ប្រតិបត្តិការភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងធនាគារ និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃឬមិនបានគិតថ្លៃ។

១. បុគ្គល ឬមនុស្សដែលជិតស្និទ្ធជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយធនាគារ ប្រសិនបើបុគ្គលនោះ
   - ក មានសិទ្ធិគ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើធនាគារ
   - ខ មានឥទ្ធិពលខ្លាំងលើធនាគារ ឬ
   - គ គឺជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ធនាគារ។

២. អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធរបស់ធនាគារ ប្រសិនបើស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖
   - ក អង្គភាព និងធនាគារ គឺជាសមាជិកនៃសម្ព័ន្ធតែមួយ
   - ខ អង្គភាពមួយដែលជាការចូលរួម ឬការបណ្តាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
   - គ អង្គភាពទាំងពីរធ្វើការបណ្តាក់ទុនរួមលើភាគីទីបីដូចគ្នា
   - យ អង្គភាពមួយ គឺជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបី និងអង្គភាពផ្សេងទៀតគឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
   - ង អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយបំពេញការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិតទាំងក្នុងធនាគារ ឬអង្គភាពដែលទាក់ទងនឹងធនាគារ
   - ច អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុងចំណុច ១ ខាងលើ
   - ឆ បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុងចំណុច ១.ក ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃគណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន ឬ អង្គភាពមេចុងក្រោយ
   - ជ អង្គភាព ឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្តល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗដល់ធនាគារ ឬជូនចំពោះធនាគារមេ។

២.៥.២៥ ការបង្គត់តួលេខ

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ឱ្យក្លាយជាតួលេខគត់ដែលមានតម្លៃដែលនៅគៀកបំផុតទៅ នឹងតួលេខទឹកប្រាក់ដុល្លារជាដុល្លារអាមេរិក និងពាន់រៀលសម្រាប់ទឹកប្រាក់ជាខ្មែររៀល។

២.៥.២៦ ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍

ធនាគារ កំណត់យកព្រឹត្តិការណ៍បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដែលព្រឹត្តិការណ៍ទាំងនោះ រួមទាំងអំណោយផល និងមិនអំណោយផល ហើយបានកើតឡើងរវាងចុងការិយបរិច្ឆេទនៃរបាយការណ៍ និងការិយបរិច្ឆេទដែលរបាយការណ៍ត្រូវបានអនុម័តឱ្យចេញផ្សាយ។ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ទាំងនោះដែលផ្តល់នូវភស្តុតាងក្នុង ការបញ្ជាក់ថាបានកើតឡើងនាចុងការិយបរិច្ឆេទ នៃរបាយការណ៍។ ព្រឹត្តិការណ៍មិនមានការកែតម្រូវបន្ទាប់ពីចុងការិយបរិច្ឆេទ នៃរបាយការណ៍ ដែលត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលវាមានភាពជាសារវន្ត។

២.៦ ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាម CIFRSs តម្រូវឱ្យធនាគារធ្វើការប៉ាន់ស្មាន និងការសន្មតដែលប៉ះពាល់ដល់សមតុល្យនៃធនធាន បំណុល ចំណូល និងចំណាយ ដែលបានរាយការណ៍ និងការលាតត្រដាងធនធានចំណូលយថាភាព និងបំណុលយថាភាព។ ព្រឹត្តិការណ៍នាពេលអនាគតអាចនឹងកើតឡើង ដែលអាចបណ្តាលឱ្យការសន្មតត្រូវបានប្រើក្នុងការប៉ាន់ស្មាន ដែលមានការផ្លាស់ប្តូរ។ ផលប៉ះពាល់នៃការផ្លាស់ប្តូរណាមួយនៅក្នុងការប៉ាន់ស្មានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុតែនៅពេល ដែលពួកគេអាចកំណត់បានតាមការសមស្រប។

២.៦.១ ការវិនិច្ឆ័យ

ខាងក្រោមនេះគឺជាការវិនិច្ឆ័យសំខាន់ៗ និងការសន្មតសំខាន់ៗដែលមានហានិភ័យយ៉ាងសំខាន់នៃការធ្វើនិយ័តកម្មជាសារវន្តទៅ នឹងតម្លៃរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់៖

បំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ របស់ខ្លួនអាស្រ័យលើគំរូអាជីវកម្មសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ និងថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុគឺ SPPI លើសមតុល្យដើមដែលនៅសល់។ ធនាគារធ្វើការវាយតម្លៃគំរូអាជីវកម្មដោយផ្អែកលើកត្តា ដែលអាចសង្កេតបានដូចជា៖

- ការអនុវត្តគំរូអាជីវកម្ម និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងគំរូអាជីវកម្មនោះត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ

- ហានិភ័យដែលជះឥទ្ធិពលដល់ដំណើរការអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងជាពិសេសវិធីដែលហានិភ័យត្រូវបានគ្រប់គ្រង
- សំណងដល់អង្គភាពអាជីវកម្មមិនថាផ្អែកលើតម្លៃសមស្រប នៃទ្រព្យដែលបានគ្រប់គ្រង ឬ លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល និង
- ភាពញឹកញាប់នៃការរំពឹងទុក តម្លៃ និងពេលវេលានៃការលក់។

ក្នុងការអនុវត្តតេស្ត SPPI ធនាគារអនុវត្តការវិនិច្ឆ័យ និងពិចារណាលើកត្តាពាក់ព័ន្ធដូចជារូបិយប័ណ្ណដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបាន កំណត់រយៈពេលដែលអត្រាការប្រាក់ត្រូវបានកំណត់ព្រឹត្តិការណ៍បន្តដែលអាចផ្លាស់ប្តូរចំនួន និងពេលវេលា នៃលំហូរសាច់ប្រាក់អានុភាព លក្ខណៈពិសេសលក្ខខណ្ឌនៃចំណាយបង់មុន និងការពន្យារពេល និងលក្ខណៈពិសេសផ្សេងទៀតដែលអាចកែប្រែការពិចារណាទៅលើតម្លៃនៃពេលវេលា។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ
នៅពេលដែលតម្លៃសមស្របរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬបានបង្ហាញ នៅក្នុងកំណត់ត្រាទៅរបាយការណ៍ហិរញ្ញវត្ថុមិនអាចទទួលបានពីទីផ្សារសកម្មទេ ហើយត្រូវបានកំណត់ដោយប្រើបច្ចេកទេសវាយតម្លៃផ្ទៃក្នុង ដោយប្រើគំរូវាយតម្លៃទីផ្សារដែលត្រូវបានទទួលយកជាទូទៅ។ ជាតុចូលនៃគំរូទាំងនេះត្រូវបានយកចេញពីទីផ្សារដែលអាចអង្កេតបាន នៅពេលដែលអាចធ្វើទៅបានប៉ុន្តែនៅពេលដែលមិនអាចធ្វើទៅបានកម្រិតនៃការវិនិច្ឆ័យត្រូវបានទាមទារក្នុងការបង្កើតតម្លៃសមស្រប។

ភតិសន្យា
ការវាយតម្លៃថាតើកិច្ចព្រមព្រៀងរួមមានភតិសន្យាគឺផ្អែកលើសមាសធាតុរបស់វា។ កិច្ចព្រមព្រៀងរួមមានភតិសន្យានៅពេលបំពេញ តាមកិច្ចព្រមព្រៀងផ្អែកលើទ្រព្យសកម្មជាក់លាក់ ឬទ្រព្យសកម្ម និងកិច្ចព្រមព្រៀងដែលបង្ហាញពីសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម។

ក្នុងវាយតម្លៃថាតើភតិសន្យាមានតម្លៃទាប គណៈគ្រប់គ្រងកំណត់សមាសធាតុសេដ្ឋកិច្ចរបស់ទ្រព្យសកម្មជារួម។

ជម្រើសបន្ថែម និងការបញ្ចប់
ធនាគារកំណត់រយៈពេលភតិសន្យា ជាកិច្ចសន្យាមិនអាចលុបចោលវិញបាន រួមជាមួយនឹងរយៈពេលដែលគ្របដណ្តប់ដោយជម្រើស ក្នុងការបន្តការជួល ប្រសិនបើវាមានហេតុផលជាក់លាក់ដែលត្រូវអនុវត្ត ឬរយៈពេលណាមួយដែលប្រកបដោយជម្រើស ដើម្បីបញ្ចប់ការជួល ប្រសិនបើមានហេតុផលជាក់លាក់បញ្ជាក់ថាមិនអាចអនុវត្តបាន។

ធនាគារមានកិច្ចសន្យាជួលជាច្រើនដែលរួមបញ្ចូលជម្រើសបន្ថែម និងការបញ្ចប់។ ធនាគារអនុវត្តការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើវាមានភាពជាក់លាក់ប្រកបដោយសមហេតុផលថាតើត្រូវប្រើជម្រើសក្នុងការបន្ត ឬបញ្ចប់ការជួល។ ការអនុវត្តនោះ ត្រូវពិចារណាលើកត្តាពាក់ព័ន្ធ ទាំងអស់ដូចជាការកែលម្អអគារ និងទីតាំងដែលបង្កើត ការលើកទឹកចិត្តសេដ្ឋកិច្ចដើម្បីអនុវត្តការបន្ត ឬការបញ្ចប់។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើម ធនាគារបានវាយតម្លៃឡើងវិញនូវរយៈពេលជួល ប្រសិនបើមានព្រឹត្តិការណ៍សំខាន់ ឬការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន និងប៉ះពាល់ដល់សមត្ថភាពរបស់ខ្លួនក្នុងការអនុវត្ត ឬមិនអនុវត្តជម្រើសក្នុងការបន្ត ឬបញ្ចប់។

ទ្រព្យសម្រាប់លក់
នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ធនាគារបានចុះកិច្ចព្រមព្រៀងសេវាកម្មតែងតាំង ជាមួយក្រុមហ៊ុន ម៉ារ៉ូហាន់ អ៊ិនវេសម៊ិន (ខេមបូឌា) ក្នុងការទូទាត់បំណុលទាំងស្រុង ទៅលើ ឥណទានវិចារូបន៍ ជាមួយធនាគារ។ ធនាគារបានពិនិត្យឃើញថា ទ្រព្យទាំងនេះត្រូវបានចាត់ថ្នាក់ថា ទ្រព្យសម្រាប់លក់ នាកាលបរិច្ឆេទនេះ ដោយសារតែហេតុផលដូចខាងក្រោម៖
- ទ្រព្យទាំងនេះអាចលក់បានភ្លាមៗ និងអាចលក់ឱ្យអ្នកទិញក្នុងសភាពបច្ចុប្បន្នរបស់វា និង
- សកម្មភាពដែលចាំបាច់សម្រាប់បញ្ចប់ការលក់ត្រូវបានចាប់ផ្តើម ហើយរំពឹងថានឹងបញ្ចប់បានក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទចាត់ថ្នាក់ដំបូង

២.៦.២ ការប៉ាន់ស្មាន
ការខាតឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុ
ការគណនា ECL របស់ធនាគារ គឺជាលទ្ធផលនៃគំរូស្មុគស្មាញជាមួយនឹងការសន្មតមូលដ្ឋានទាក់ទងនឹងជម្រើសនៃជាតុចូលអថេរ និងទំនាក់ទំនងរបស់ទ្រព្យសកម្មទាំងនោះ។ ជាតុផ្សំនៃគំរូ ECL ដែលត្រូវបានគេពិចារណាការវិនិច្ឆ័យគណនេយ្យ និងការប៉ាន់ស្មានរួមមាន៖
- ការបែងចែកផលបត្រដែលគំរូ ឬវិធីសាស្ត្រ ECL ត្រូវបានប្រើ
- លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃប្រសិនបើមាន SICR ហើយសំវិធានធនសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុបំណុល គួរតែត្រូវបានវាស់វែងលើមូលដ្ឋាន ECL មួយអាយុកាល និងការវាយតម្លៃគុណភាព
- ការបែងចែកទ្រព្យសកម្មបំណុល នៅពេល ECL ត្រូវបានវាយតម្លៃជាសមូហភាព និងមូលដ្ឋានបុគ្គលសម្រាប់អតិថិជនសំខាន់ៗដូចដែលបានកំណត់ដោយគណៈគ្រប់គ្រងរបស់ធនាគារ
- ការអភិវឌ្ឍគំរូ ECL រួមទាំងរូបមន្តផ្សេងៗគ្នា និងជម្រើសនៃជាតុចូល
- ការកំណត់ទំនាក់ទំនងរវាងសេណារីយ៉ូម៉ាក្រូសេដ្ឋកិច្ច និងជាតុចូលសេដ្ឋកិច្ច និងផលប៉ះពាល់លើ PD EADs និង LGDs និង
- ការជ្រើសរើសសេណារីយ៉ូម៉ាក្រូសេដ្ឋកិច្ចដែលព្យាករណ៍នាពេលខាងមុខ និងការប៉ាន់ស្មានអំពីប្រូបាប៊ីលីតេរបស់វាដើម្បីទាញយកជាតុចូលសេដ្ឋកិច្ច ទៅក្នុងគំរូ ECL។

ការទទួលស្គាល់ពន្ធពន្យារជាទ្រព្យសកម្ម
ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ចំពោះរាល់ការខាតបង់ពន្ធដែលមិនបានប្រើប្រាស់ និងភាពខុសគ្នាបណ្តោះអាសន្នក្នុងទំហំដែលអាចនឹងទទួលបានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតបើធៀប នឹងការខាតបង់ដែលអាចបែងចែកបាន។ ការវិនិច្ឆ័យសារៈសំខាន់ ត្រូវបានកំណត់ដើម្បីកំណត់ចំនួននៃពន្ធពន្យារជាទ្រព្យសកម្ម ដែលអាចត្រូវបានទទួលស្គាល់ដោយផ្អែកលើពេលវេលា និងកម្រិតនៃប្រាក់ ចំណូលជាប់ពន្ធនាពេលអនាគតរួមជាមួយនឹងយុទ្ធសាស្ត្រផែនការពន្ធនាពេលអនាគត។

ចំណាយពន្ធលើប្រាក់ចំណូល
ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា មានសភាពថ្មីហើយត្រូវបាន

បែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាធម្មតាពឹងផ្អែកនៃការបកស្រាយ។ សារពើពន្ធ គឺជាកម្មវត្ថុនៃការពិនិត្យ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗ ជាច្រើនដែលមានសមត្ថកិច្ច ក្នុងការផាកពិន័យធ្ងន់ធ្ងរ និងពិន័យជាការប្រាក់។

កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យពន្ធដារលើធនាគារ។ គណៈគ្រប់គ្រងមានការជឿជាក់ថា ខ្លួនបានយល់ដឹងនូវបទប្បញ្ញត្តិពន្ធដារ និងបង់បំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី លទ្ធផលពន្ធចុងក្រោយនៃបញ្ហាទាំងនេះ មានខុសគ្នាពីចំនួនដែលបានកត់ត្រាដំបូង ភាពខុសគ្នាទាំងនេះនឹងប៉ះពាល់ដល់ចំនួនសារពើពន្ធ ដែលបាន កត់ត្រាក្នុងកាលបរិច្ឆេទដែលការកំណត់ត្រូវបានធ្វើឡើង។

អត្ថប្រយោជន៍កាតព្វកិច្ចដែលបានកំណត់

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ផ្អែកលើតួលេខលើវិស័យ ដែលបានកំណត់ដោយគណៈគ្រប់គ្រង ដោយប្រើប្រាស់ការសន្មត។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ថ្លៃដើមសុទ្ធនៃអត្ថប្រយោជន៍រួមបញ្ចូលទាំងអត្រាអប្បហារ។ ការប្រែប្រួលក្នុងការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់លើតម្លៃអត្ថប្រយោជន៍កាតព្វកិច្ចដែលបានកំណត់។

២.៧ ការអនុវត្តទៅលើស្តង់ដាគណនេយ្យដែលបានធ្វើវិសោធនកម្ម

២.៧.១ វិសោធនកម្មលើ CIFRSs បានចេញផ្សាយនិងអនុវត្តដោយធនាគារ

ធនាគារបានអនុវត្តវិសោធនកម្មលើកដំបូងលើការិយបរិច្ឆេទរបាយការណ៍ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥៖

- វិសោធនកម្មលើ CIAS ២១ កង្វះខាតនៃការផ្លាស់ប្តូរ

វិសោធនកម្មដែលបានចែងខាងលើមិនមានផលប៉ះពាល់សំខាន់ ទៅលើចំនួនទឹកប្រាក់ដែលទទួលស្គាល់នៅក្នុងការិយបរិច្ឆេទមុន បច្ចុប្បន្ន ឬអនាគតឡើយ។

២.៧.២ ស្តង់ដា និងវិសោធនកម្មលើ CIFRSs ដែលបានចេញផ្សាយប៉ុន្តែមិនទាន់មានសុពលភាព

ស្តង់ដាថ្មី និងស្តង់ដាដែលបានធ្វើវិសោធនកម្ម ហើយបានចេញផ្សាយ ប៉ុន្តែមិនទាន់មានសុពលភាព ឬ ត្រូវបានអនុវត្តមុនកំណត់ដោយធនាគារ និងមិនរំពឹងទុកថានឹងមានផលប៉ះពាល់ជាសារវន្ត រហូតដល់ការិយបរិច្ឆេទចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ បានចែងដូចខាងក្រោម៖

សុពលភាពចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦

- វិសោធនកម្មលើ CIFRS ៩ និង CIFRS ៧ ការចាត់ថ្នាក់ និងការវាស់វែងនៃឧបករណ៍ហិរញ្ញវត្ថុ
- វិសោធនកម្មលើ CIFRS ៩ និង CIFRS ៧ កិច្ចសន្យាដែលយោងទៅលើអគ្គីសនីអាស្រ័យលើធម្មជាតិ
- ការកែលម្អប្រចាំឆ្នាំលើស្តង់ដាគណនេយ្យ CIFRS - ភាគទី១១

សុពលភាពចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៧

- CIFRS ១៨ ការបង្ហាញ និងការលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- CIFRS ១៩ ក្រុមហ៊ុនបុត្រសម្ព័ន្ធដោយគ្មានការទទួលខុសត្រូវជាសាធារណៈ៖ការលាតត្រដាង
- វិសោធនកម្មលើ CIAS ២១ ការប្តូរទៅជារូបិយប័ណ្ណបង្ហាញដែលមានអតិផរណាខ្ពស់

កាលបរិច្ឆេទប្រសិទ្ធភាពបានពន្យារជាអចិន្ត្រៃយ៍

- វិសោធនកម្មលើ CIFRS ១០ របាយការណ៍ហិរញ្ញវត្ថុរួម និង CIAS ២៨ ការលក់ ឬការរួមវិភាគទាននៃទ្រព្យសកម្មរវាងវិនិយោគិន និងសហការី ឬក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៣. សាច់ប្រាក់ក្នុងដៃ

សាច់ប្រាក់ក្នុងដៃបានចែងដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ដុល្លារអាមេរិក	៥៣.៤៩៨.៧៥២	២១៤.៦៩០.៤៩២	៩១.០៩២.៦០២	៣៦៦.៦៤៧.៧២៣
ខ្មែររៀល	៣៣.៧៨៧.៦៤៣	១៣៥.៥៨៩.៨១១	៥៦.២៦៨.៨៥០	២២៦.៤៨២.១២១
យេនជប៉ុន	៥២.១២០	២០៩.១៥៨	៥៣.៨២៧	២១៦.៦៥៤
បាតថៃ	៤៣.២១៧	១៧៣.៤៣០	១៨៨.៩៣៨	៧៦០.៤៧៥
អឺរ៉ូ	៣៧.៧០៨	១៥១.៣២២	៣២.៦៨៧	១៣១.៥៦៥
ផោនអង់គ្លេស	១៨.១២៣	៧២.៧២៨	១៦.៨៥៥	៦៧.៨៤១
ដុល្លារអូស្ត្រាលី	១៧.៨៦១	៧១.៦៧៦	១៦.៥៦៣	៦៦.៦៦៦
យ៉ន់ចិន	១០.០៩៥	៤០.៥១១	៩.៦៦៤	៣៨.៨៩៨
ដុល្លារសិង្ហបុរី	៩៥២	៣.៨២០	៩០០	៣.៦២៣
	៨៧.៤៦៦.៤៧១	៣៥១.០០២.៩៤៨	**១៤៧.៦៨០.៨៨៦**	**៥៩៤.៤១៥.៥៦៦**

សម្រាប់គោលបំណងក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សាច់ប្រាក់ក្នុងដៃ	៨៧.៤៦៦.៤៧១	៣៥១.០០២.៩៤៨	១៤៧.៦៨០.៨៨៦	៥៩៤.៤១៥.៥៦៦
សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា				
គណនីចរន្ត (កំណត់សម្គាល់លេខ ៤)	១៩៤.៦២១.៥៥៥	៧៨១.០១៦.៣០០	២០៤.៤៦៥.០២៣	៨២២.៩៧១.៧១៨
ប្រាក់បញ្ញើរយៈពេលខ្លី (កំណត់សម្គាល់លេខ ៤)	៥១.៨៩៧.៤៨៩	២០៨.២៦៤.៦២៣	៣០.០១៨.៣៨៨	១២០.៨២៤.០១២
សមតុល្យនៅធនាគារផ្សេងៗ				
គណនីចរន្ត (កំណត់សម្គាល់លេខ ៥)	២៩.១៩០.០០៨	១១៧.១៣៩.៥០២	៣៧.០៦១.៨៨២	១៤៩.១៧៤.០៧៥
គណនីសន្សំ (កំណត់សម្គាល់លេខ ៥)	៥៣.៧០១	២១៥.៥០២	៨៣.១៤៦	៣៣៤.៦៦៣
ប្រាក់បញ្ញើរយៈពេលខ្លី (កំណត់សម្គាល់លេខ ៥)	-	-	៣៣.០៩៥.៨៦៣	១៣៣.២១០.៨៤៩
	៣៦៣.២២៩.២២៤	១.៤៥៧.៦៣៨.៨៧៥	**៤៥២.៤០៥.១៨៨**	**១.៨២០.៩៣០.៨៨៣**

៤. សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា

សមតុល្យនៅធនាគារជាតិ នៃ កម្ពុជារួមមាន៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
គណនីចរន្ត	១៩៤.៦២១.៥៥៥	៧៨១.០១៦.៣០០	២០៤.៤៦៥.០២៣	៨២២.៩៧១.៧១៨
ប្រាក់បញ្ញើរយៈពេលខ្លី (i)				
៣ ខែ ឬតិចជាងនេះ	៥១.៨៩៧.៤៨៩	២០៨.២៦៤.៦២៣	៣០.០១៨.៣៨៨	១២០.៨២៤.០១២
លើសពី ៣ខែ ទៅ ១២ ខែ	៧០.០៩៨.៦១៥	២៨១.៣០៥.៧៤៤	១៦.០៥៣.៨៣២	៦៤.៦១៦.៦៧៣
ប្រាក់តម្កល់ជានាលើដើមទុន (ii)	២៩.៦៥១.១១៤	១១៨.៩៨៩.៩២០	២៩.១៩០.៩៨៨	១១៧.៤៩៣.៧២៧
ប្រាក់បម្រុងកាតព្វកិច្ច (iii)	១៤០.០៣៧.៩៧៧	៥៦១.៩៧២.៤០២	១៣៧.៤៩២.៥៤៧	៥៥៣.៤០៧.៥០២
	៤៨៦.៣០៦.៧៥០	**១.៩៥១.៥៤៨.៩៨៩**	**៤១៧.២២០.៧៧៨**	**១.៦៧៩.៣១៣.៦៣២**

(i) ប្រាក់បញ្ញើរយៈពេលខ្លី

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើរយៈពេលខ្លីមានដូចខាងក្រោម៖

	ឆ្នាំ២០២៥	ឆ្នាំ២០២៤
រូបិយប័ណ្ណ	ដុល្លារអាមេរិក	ដុល្លារអាមេរិក
រយៈពេល		
៣ ខែ	០,១៧% ដល់ ០,២៥%	១,០០%
៦ ខែ	០,៦២% ដល់ ១,០០%	១,១៥% ដល់ ១,១៦%
១២ ខែ	១,០៥%	-

(ii) ប្រាក់តម្កល់ជានាលើដើមទុន

យោងតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ គ្រប់ធនាគារត្រូវបានតម្រូវឱ្យ តម្កល់ប្រាក់ចំនួន១០% នៃដើមទុនចុះបញ្ជីនៅធនាគារជាតិ នៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ របស់ធនាគារបានឡើយ ប៉ុន្តែ ធនាគារអាចដកយកវិញបាន នៅពេលដែលធនាគារឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្ម័គ្រចិត្ត។ ប្រាក់តម្កល់ជានាលើដើមទុនទទួលបានអត្រាការប្រាក់ ១,០៦% និង ១,០៣% ក្នុងមួយឆ្នាំសម្រាប់ឆមាសទីមួយ និងឆមាសទីពីរវៀងៗគ្នា (ឆ្នាំ២០២៤៖ ១,២៩% និង ១,៣១% ក្នុងមួយឆ្នាំ)។

(iii) ប្រាក់បម្រុងកាតព្វកិច្ច

តាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជាលេខ ធ៧-០២០-២៣០ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ធនាគារពាណិជ្ជ តម្រូវឱ្យរក្សាប្រាក់បម្រុងកាតព្វកិច្ចនៅធនាគារជាតិ នៃ កម្ពុជា ក្នុងទម្រង់ជាប្រាក់បម្រុងកាតព្វកិច្ច គណនាតាមអត្រា ៧.០% នៃប្រាក់បញ្ញើអតិថិជន និងប្រាក់កម្ចីជារូបិយប័ណ្ណប្រាក់រៀល និងរូបិយប័ណ្ណផ្សេងៗ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជាបានចេញប្រកាសលេខ ធ៧-០២៣-០០៥ ដើម្បីប្រកាសពីការផ្លាស់ប្តូរអត្រាប្រាក់បម្រុងកាតព្វកិច្ច ដែលតម្រូវដូចខាងក្រោម៖

(iii) ប្រាក់បម្រុងកាតព្វកិច្ច (តពីទំព័រមុន)

- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ តម្រូវការប្រាក់បម្រុងកាតព្វកិច្ចត្រូវបានរក្សាទុកជា រូបិយប័ណ្ណបរទេសនឹងត្រូវគណនាក្នុងអត្រា ៩% នៃប្រាក់បញ្ញើ និងប្រាក់កម្ចីសរុប និង
- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ ប្រាក់បម្រុងកាតព្វកិច្ចត្រូវបានរក្សាទុកជា រូបិយប័ណ្ណបរទេសនឹងត្រូវគណនាក្នុង អត្រា ១២,៥% នៃប្រាក់បញ្ញើ និងប្រាក់កម្ចីសរុប
- ប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណក្នុងស្រុករក្សានៅដដែល។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជាបានចេញលិខិតឆ្លើយតបទៅសមាគមធនាគារនៃកម្ពុជា ដោយអនុញ្ញាតឱ្យធនាគារពាណិជ្ជរក្សានូវប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសនៅ ៧% ដែលមានសុពលភាព រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ធនាគារជាតិ នៃ កម្ពុជាបានចេញលិខិតជូន គ្រប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ឱ្យបន្តរក្សានូវប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសនូវអត្រា ៧%ដែលមានសុពលភាព រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

ក្នុងអំឡុងការិយបរិច្ឆេទនេះ ចំណូលការប្រាក់ពីសមតុល្យនៅ ធនាគារជាតិ នៃ កម្ពុជា មានចំនួន ១.០២២.០០៧ ដុល្លារអាមេរិក ឬ ៤.០៩៩.២៧០ ពាន់រៀល (ឆ្នាំ២០២៤៖ ១.០៨១.០១៨ដុល្លារអាមេរិក ឬ ៤.៤០០.៨២៤ ពាន់រៀល) (កំណត់សម្គាល់លេខ ២២)។

៥. សមតុល្យនៅធនាគារផ្សេងៗ

សមតុល្យនៅធនាគារផ្សេងៗមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
គណនីចរន្ត	២៩.១៩០.០០៨	១១៧.១៣៩.៥០២	៣៧.០៦១.៨៨២	១៤៩.១៧៤.០៧៥
គណនីសន្សំ	៥៣.៧០១	២១៥.៥០២	៨៣.១៤៦	៣៣៤.៦៦៣
ប្រាក់បញ្ញើរយៈពេលខ្លី (i)				
តិចជាង ៣ ខែ	-	-	៣៣.០៩៥.៨៦៣	១៣៣.២១០.៨៤៩
៣ ទៅ ១២ ខែ	១៥.១៩៤.២៤៧	៦០.៩៧៤.៥១៤	១២.០៦៧.៩៩១	៤៨.៥៧៣.៦៦៣
សមតុល្យដុលជាមួយធនាគារផ្សេងៗ	**៤៤.៤៣៧.៩៥៦**	**១៧៨.៣២៩.៥១៨**	**៨២.៣០៨.៨៨២**	**៣៣១.២៩៣.២៥០**
សំវិធានធនសម្រាប់ ECLs	(៣០០.៨១៥)	(១.២០៧.១៧១)	(៤០៦.១៩៦)	(១.៦៣៤.៩៣៩)
សមតុល្យសុទ្ធជាមួយធនាគារផ្សេងៗ	**៤៤.១៣៧.១៤១**	**១៧៧.១២២.៣៤៧**	**៨១.៩០២.៦៨៦**	**៣២៩.៦៥៨.៣១១**

អត្រាការប្រាក់

	ឆ្នាំ២០២៥	ឆ្នាំ២០២៤
ប្រាក់បញ្ញើរយៈពេលខ្លី	៤,០០% ដល់ ៥,០០%	៤,០០% ដល់ ៦,៥០%
គណនីចរន្ត	០,២៥% ដល់ ០,៧៥%	០,២៥%
គណនីសន្សំ	០,៥០% ដល់ ១,៥០%	០,៥០% ដល់ ២,០០%

ក្នុងអំឡុងការិយបរិច្ឆេទ ចំណូលការប្រាក់ពីសមតុល្យនៅធនាគារផ្សេងៗមានចំនួន ១.៧៧៧.៣៧២ ដុល្លារអាមេរិក ឬ ៧.១២៩.០៣៩ ពាន់រៀល (ឆ្នាំ២០២៤៖ ២.៦៧៨.០៣៧ ដុល្លារអាមេរិក ឬ ១០.៩០២.២៨៩ ពាន់រៀល) (កំណត់សម្គាល់លេខ ២២)។

៥. សមតុល្យនៅធនាគារផ្សេងៗ (តពីទំព័រមុន)

បម្រែបម្រួលសំវិធានធនសម្រាប់ ECL មានដូចខាងក្រោម

	ឆ្នាំ២០២៥		ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សមតុល្យនាថ្ងៃទី១ ខែមករា	៤០៦.១៩៦	១.៦៣៤.៩៣៩	៥៥៥.៨០១	២.២៧០.៤៤៧
ការកត់ត្រាបញ្ច្រាស លើ ECL កំណត់សម្គាល់ លេខ ២៧)	(១០៥.៣៨១)	(៤២២.៦៨៣)	(១៤៩.៦០៥)	(៦០៩.០៤២)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	(៥.០៨៥)	-	(២៦.៤៦៦)
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ	**៣០០.៨១៥**	**១.២០៧.១៧១**	**៤០៦.១៩៦**	**១.៦៣៤.៩៣៩**

៦. ឥណទានទៅអតិថិជន

ព័ត៌មានលម្អិតពីឥណទានទៅអតិថិជនមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
អាជីវកម្មលក់រាយ	៨២២.៥៨៤.៨៩៧	៣.៣០១.០៣៣.១៩២	៨១៣.២០០.៦៩០	៣.២៧៣.១៣២.៧៧៧
ឥណទានបុគ្គល	៣៨៩.១០៧.១៩៨	១.៥៦១.៤៨៧.១៨៦	៣៧០.៤៣០.០២៧	១.៤៩០.៩៨០.៨៥៩
ពាណិជ្ជកម្ម	៣៨៥.៤១៦.៧៩៣	១.៥៤៦.៦៧៧.៥៩០	៣៣៥.៤២៥.២៣១	១.៣៥០.០៨៦.៥៥៥
លំនៅដ្ឋាន	២៣៦.១១៨.៧៤២	៩៤៧.៥៤៤.៥១២	២៣៧.១១៥.៨២៨	៩៥៤.៣៩១.២០៨
កសិកម្ម	១៨០.៥៦៤.២៦៩	៧២៤.៦០៤.៤១១	១៨៨.៦៦៥.២២០	៧៥៩.៣៧៧.៥១១
វិចារូបន៍	២៣.១៤៣.៧២៧	៩២.៨៧៥.៧៧៦	៥២.៦២៦.៤៤៩	២១១.៨២១.៤៥៧
ឥណទានបុគ្គលិក	១៨.៩៧៧.១២៣	៧៦.១៥៥.១៩៥	២៥.៨៣១.៧៦៩	១០៣.៩៧២.៨៧០
បំណុលឥណទាន	៣.៩៨៥.៨៦៤	១៥.៩៩៣.៦៦៦	៤.១៩១.១២៨	១៦.៨៦៩.២៩០
ឥណទានទៅអតិថិជនដុល	**២.០៥៩.៨៩៨.២១៣**	**៨.២៦៦.៣៧១.៥២៨**	**២.០២៧.៤៨៦.៣៤២**	**៨.១៦០.៦៣២.៥២៧**
ការប្រាក់ត្រូវទទួល	៣៩.៩១២.៨៧២	១៦០.១៧០.៣៥៥	៣០.៦៤០.១១៧	១២៣.៣២៦.៤៧១
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**
សំវិធានធនលើ ECL	(៤៩.១៤៤.៤៩០)	(១៩៧.២១៦.៨៣៨)	(៣៨.៩៦០.៣១០)	(១៥៦.៨១៥.២៤៨)
ថ្លៃដើមប្រតិបត្តិការមិនទាន់រំលស់	(៧.៦៥៨.៣៤១)	(៣០.៧៣២.៩២២)	(៩.៧០៧.៧៩៥)	(៣៩.០៧៣.៨៧៥)
សមតុល្យឥណទានទៅអតិថិជន - សុទ្ធ	**២.០៤៣.០០៨.២៥៤**	**៨.១៩៨.៥៩២.១២៣**	**២.០០៩.៤៥៨.៣៥៤**	**៨.០៨៨.០៦៩.៨៧៥**

៦. ឥណទានទៅអតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមលើឥណទានទៅអតិថិជនមានដូចខាងក្រោម៖ (តពីទំព័រមុន)

(i) បម្រែបម្រួលនៃសំវិធានធនលើ ECL

	ឆ្នាំ២០២៥				
	ដំណាក់កាលទី១	ដំណាក់កាលទី២	ដំណាក់កាលទី៣	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សមតុល្យនាថ្ងៃទី១ ខែមករា	**៤.៦៣០.៧៨១**	**៤.២២២.៣២០**	**៣០.១០៧.២០៩**	**៣៨.៩៦០.៣១០**	**១៥៦.៨១៥.២៤៨**
ទ្រព្យសកម្មបង្កើតថ្មី	១៨១.២៥៦	១២.០០២.៥០៥	៨៥៦.៨៨៩	១៣.០០០.៦៥០	៥២.១៤៥.៦០៧
ការទូទាត់ និងទ្រព្យសកម្មដែលឈប់ទទួលស្គាល់	២.២៣១.៩៧០	(៩.៩៥៥.១៨៦)	៣៤.០៨៧.១១០	២៦.៣៦៣.៨៩៤	១០៥.៧៤៥.៥៧៩
ផលប៉ះពាល់ពីការខាតឥណទានរំពឹងទុកដែលផ្ទេរតាមដំណាក់កាល	-	(៨១.៧៥៧)	២២៤.៨២២	១៤៣.០៦៥	៥៧៣.៨៣៤
ផ្ទេរទៅដំណាក់កាលទី ១	១.៤១៧.៦៥៧	(១.៤០៥.៧៥៩)	(១១.៨៩៨)	-	-
ផ្ទេរទៅដំណាក់កាលទី ២	(៨៦.០៩៧)	៨៤៤.៨០៥	(៧៥៨.៧០៨)	-	-
ផ្ទេរទៅដំណាក់កាលទី ៣	(២.៩៨៩.៦៨០)	(១៨១.២០៤)	៣.១៧០.៨៨៤	-	-
សមតុល្យដែលបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតក្នុងការិយបរិច្ឆេទ	**៧១៥.១០៦**	**១.២២៣.៤០៤**	**៣៧.៥៦៩.០៩៩**	**៣៩.៥០៧.៦០៩**	**១៥៨.៤៦៥.០២០**
ឥណទានលុបចោល	-	-	(២៩.៣២៣.៤២៩)	(២៩.៣២៣.៤២៩)	(១១៧.៦១៦.២៧៤)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	-	(៤៤៧.១៥៦)
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ	**៥.៣៤៥.៨៨៧**	**៥.៤៤៥.៧២៤**	**៣៨.៣៥២.៨៧៩**	**៤៩.១៤៤.៤៩០**	**១៩៧.២១៦.៨៣៨**

	ឆ្នាំ២០២៤				
	ដំណាក់កាលទី១	ដំណាក់កាលទី២	ដំណាក់កាលទី៣	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សមតុល្យនាថ្ងៃទី១ ខែមករា	**២.៥២៣.៨៤៩**	**១.២២១.១៥២**	**៣៦.៩៥៨.២៧៩**	**៤០.៧០៣.២៨០**	**១៦៦.២៧២.៨៩៩**
ទ្រព្យសកម្មថ្មី	១.៦៩២.៥០៥	៥៩៩.៨០៣	៦៩៤.០០០	២.៩៨៦.៣០៨	១២.១៥៧.២៦០
ការទូទាត់ និងទ្រព្យសកម្មដែលឈប់ទទួលស្គាល់	១.៧៨៨.៨៩០	(៣.៩៣៩.២២៨)	១៥៣.៧៣៥	(១.៩៩៦.៦០៣)	(៨.១២៨.១៧១)
ផលប៉ះពាល់ពីការខាតឥណទានរំពឹងទុកដែលផ្ទេរតាមដំណាក់កាល	-	២.៨១៩.១៦០	១១.៧០៣.៦៥១	១៤.៥២២.៨១១	៥៩.១២២.៣៦៤
ផលប៉ះពាល់ឥណទានដែលបានបិទក្នុងអំឡុងការិយបរិច្ឆេទ	(៩៤៥.៦៩៨)	(២២៨.៨៦៤)	(៦.២៧០.៩៩៦)	(៧.៨៤៥.១៥៨)	(៣០.៣០៩.២៣៨)
ផ្ទេរទៅដំណាក់កាលទី ១	២២៨.៣៥៥	(៣៦.៧៦៦)	(១៩១.៥៨៩)	-	-
ផ្ទេរទៅដំណាក់កាលទី ២	(៤៦៧.៥៣៨)	៤.២៩១.៦៨៣	(៣.៨២៤.១៤៥)	-	-
ផ្ទេរទៅដំណាក់កាលទី ៣	(១៨៩.៥៨២)	(៥០៥.០២០)	៦៩៤.៦០២	-	-
សមតុល្យដែលបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតក្នុងការិយបរិច្ឆេទ	**២.១០៦.៩៣២**	**៣.០០១.១៦៨**	**២.៩៥៩.២៥៨**	**៨.០៦៧.៣៥៩**	**៣២.៨៤២.២១៨**
ឥណទានលុបចោល	-	-	(៩.៨១០.៣២៩)	(៩.៨១០.៣២៩)	(៣៩.៩៣៧.៨៤៩)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	-	(២.៣៦២.០២០)
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ	**៤.៦៣០.៧៨១**	**៤.២២២.៣២០**	**៣០.១០៧.២០៩**	**៣៨.៩៦០.៣១០**	**១៥៦.៨១៥.២៤៨**

៦. ឥណទានទៅអតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមលើឥណទានទៅអតិថិជនមានដូចខាងក្រោម៖ (តពីទំព័រមុន)

(**ii**) តាមវិស័យ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ពាណិជ្ជកម្ម - លក់ដុំ និងលក់រាយ	៦០៥.៥៨៧.៣៨១	២.៤៣០.២២២.១៦០	៥៦៨.៧៩៩.០១០	២.២៨៩.៤១៦.០១៥
កម្ចីផ្ទាល់ខ្លួន	៤១២.៧១២.១២៣	១.៦៥៦.២១៣.៧៥០	៣៩៦.៧៤៧.០៨០	១.៥៩៦.៩០៦.៩៩៧
សេវាកម្ម	៣៣០.២៥៤.២៣០	១.៣២៥.៣១០.២២៥	៣២១.៤៣៤.៥១៨	១.២៩៣.៧៧៣.៩៣៥
ការសាងសង់ និងអចលនទ្រព្យ	២៨៨.៨៦២.៥៧០	១.១៥៩.២០៥.៤៩៣	២៩៤.៩០៨.០១១	១.១៨៧.០០៤.៧៤៤
សេវាបញ្ចាំ	២៤២.៦៣៣.១១០	៩៧៣.៦៨៦.៦៧០	២៤៥.០៨០.២៦៤	៩៨៦.៤៤៨.០៦៣
វិស័យកសិកម្ម	១៩១.៦៨៥.៦១៩	៧៦៩.២៣៤.៣៨៩	១៩៧.៩៥០.៤១៥	៧៩៦.៧៥០.៤២០
គ្រឹះស្ថានហិរញ្ញវត្ថុ	២៧.៩១៦.៩៨២	១១២.០៣០.៨៤៩	៣២.៩៤៤.៨១៩	១៣២.៦០២.៨៩៦
ផ្សេងៗ	១៥៩.០៧០	៦៣៨.៣៤៧	២៦២.៣៤២	១.០៥៥.៩២៨
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**

(**iii**) តាមកាលវិសាន្ត

យោងតាមកំណត់សម្គាល់លេខ ៣២ ស្តីពីព័ត៌មាននៃកាលវិសាន្តរបស់ទ្រព្យសកម្ម និងបំណុល។

(**iv**) តាមនិវាសនដ្ឋាន ទំនាក់ទំនង ហានិភ័យ និងកម្រិតអត្រាការប្រាក់

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
និវាសនដ្ឋាន៖				
និវាសនជន	២.០៩៩.៨១១.០៨៥	៨.៤២៦.៥៤១.៨៨៣	២.០៥៨.១២៦.៤៥៩	៨.២៨៣.៩៥៨.៩៩៨
អនិវាសនជន	-	-	-	-
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**
ទំនាក់ទំនង៖				
ភាគីពាក់ព័ន្ធ	៤.១៧៥.២៦០	១៦.៧៥៥.៣១៨	២៧.៧២៣.៦៣៣	១១១.៥៨៧.៦២៣
ភាគីមិនពាក់ព័ន្ធ	២.០៩៥.៦៣៥.៨២៥	៨.៤០៩.៧៨៦.៥៦៥	២.០៣០.៤០២.៨២៦	៨.១៧២.៣៧១.៣៧៥
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**
ហានិភ័យ៖				
ហានិភ័យធំ	-	-	-	-
ហានិភ័យទាប	២.០៩៩.៨១១.០៨៥	៨.៤២៦.៥៤១.៨៨៣	២.០៥៨.១២៦.៤៥៩	៨.២៨៣.៩៥៨.៩៩៨
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**

៦. ឥណទានទៅអតិថិជន (តពីទំព័រមុន)

ការវិភាគបន្ថែមលើឥណទានទៅអតិថិជនមានដូចខាងក្រោម៖ (តពីទំព័រមុន)

(**iv**) តាមនិវាសនដ្ឋាន ទំនាក់ទំនង ហានិភ័យ និងកម្រិតអត្រាការប្រាក់ (តពីទំព័រមុន)

អត្រាការប្រាក់ប្រចាំឆ្នាំមានដូចខាងក្រោម៖	ឆ្នាំ២០២៥	ឆ្នាំ២០២៤
អតិថិជនខាងក្រៅ	៣,៧៥% ដល់ ១៩,២០%	៣,០០% ដល់ ១៩,២០%
ឥណទានបុគ្គលិក	៥,៥០% ដល់ ៧,៥០%	៥,៥០% ដល់ ៧,៥០%

ក្នុងអំឡុងការិយបរិច្ឆេទ ចំណូលការប្រាក់ លើឥណទានទៅអតិថិជនមានចំនួន ២២១.២៨៣.៣០២ ដុល្លារអាមេរិក ឬ ៨៨៧.៥៦៧.៣២៤ ពាន់រៀល (ឆ្នាំ២០២៤៖ ២៣២.៤២២.៩៤៦ ដុល្លារអាមេរិក ឬ ៩៤៦.១៩៣.៨១៣ ពាន់រៀល) (កំណត់សម្គាល់លេខ ២២)។

(**v**) ចំណាត់ថ្នាក់ឥណទាន រួមទាំងការប្រាក់ដែលត្រូវទទួលសុទ្ធ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ដំណាក់កាលទី ១	១.៤១០.៨០១.៩៦៤	៥.៦៦១.៥៤៨.២៨២	១.៥០១.៦៧៦.២៣០	៦.០៤៤.២៤៦.៨២៦
ដំណាក់កាលទី ២	៤៣៤.៧៤៣.៦២៦	១.៧៤៤.៦២៦.១៧១	៣៧៩.៧៣៣.៨៧៦	១.៥២៨.៤២៨.៨៥១
ដំណាក់កាលទី ៣	២៥៤.២៦៥.៤៩៥	១.០២០.៣៦៧.៤៣០	១៧៦.៧១៦.៣៥៣	៧១១.២៨៣.៣២១
	២.០៩៩.៨១១.០៨៥	**៨.៤២៦.៥៤១.៨៨៣**	**២.០៥៨.១២៦.៤៥៩**	**៨.២៨៣.៩៥៨.៩៩៨**

៧. ការវិនិយោគផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ការវិនិយោគមូលបត្របំណុលនៅ ថ្លៃដើមរំលស់ (*)	៩.៩៦៧.៦០៥	៤០.០០០.០០០	៩.៩៣៧.៨៨៨	៤០.០០០.០០០
មូលបត្រមូលធនដែលមិនបានចុះបញ្ជី តាម FVTPL (**)	៩៣.៧៥០	៣៧៦.២១៩	៩៣.៧៥០	៣៧៧.៣៤៤
	១០.០៦១.៣៥៥	**៤០.៣៧៦.២១៩**	**១០.០៣១.៦៣៨**	**៤០.៣៧៧.៣៤៤**
ការប្រាក់ត្រូវទទួលបាន	១៦.៦១៣	៦៦.៦៦៨	១៦.៥៦៣	៦៦.៦៦៦
	១០.០៧៧.៩៦៨	**៤០.៤៤២.៨៨៧**	**១០.០៤៨.២០១**	**៤០.៤៤៤.០១០**

(*) តំណាងឱ្យការវិនិយោគរបស់ធនាគារលើមូលបត្របំណុលរដ្ឋាភិបាល ត្រូវបានចាត់ថ្នាក់និងវាស់វែងតាមថ្លៃដើមរំលស់។ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ និងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ធនាគារបានវិនិយោគក្នុងមូលបត្របំណុលរដ្ឋាភិបាល ដែលចេញផ្សាយដោយធនាគារជាតិ នៃ កម្ពុជា ("NBC")។ មូលបត្របំណុលរដ្ឋាភិបាល មានកាលវិសាន្តរយៈពេល ២ឆ្នាំ និង ៣ឆ្នាំ ជាមួយនឹងអត្រាការប្រាក់ ៤,០០% និង៤,៥០% ក្នុងមួយឆ្នាំរៀងៗគ្នា។

៧. ការវិនិយោគផ្សេងៗ (តពីទំព័រមុន)

បម្រែបម្រួលនៃការវិនិយោគមូលបត្របំណុលនៅថ្លៃដើមរំលស់

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
នាថ្ងៃទី១ ខែមករា	៩.៩៣៧.៨៨៨	៤០.០០០.០០០	-	-
បន្ថែម	-	-	៩.៩៣៧.៨៨៨	៤០.០០០.០០០
ចំណេញលើការប្តូរប្រាក់បិយប័ណ្ណមិនទាន់ទទួលស្គាល់	២៩.៧១៧	-	-	-
នាថ្ងៃទី៣១ ខែធ្នូ	**៩.៩៦៧.៦០៥**	**៤០.០០០.០០០**	**៩.៩៣៧.៨៨៨**	**៤០.០០០.០០០**

ក្នុងអំឡុងការិយបរិច្ឆេទ ការប្រាក់បានពីការវិនិយោគនេះ មានចំនួន ៤២៣.៩៨៥ ដុល្លារអាមេរិក ឬ ១.៧០០.៦០៤ ពាន់រៀល (ឆ្នាំ២០២៤៖ ២២៥.៦៨៦ ដុល្លារអាមេរិក ឬ ៩១៨.៧៦៨ ពាន់រៀល) (កំណត់សម្គាល់លេខ ២២)។

(**) តំណាងឱ្យការវិនិយោគរបស់ធនាគារជាមួយ ក្រេឌីត ប្យូរ៉ូ ហូលឌីង (ខេមបូឌា) អិលធីឌី (“CBC”) ត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធនក្នុងតម្លៃសមស្របតាមរបាយការណ៍ចំណេញ ឬខាត (“FVTPL”) ដែលមិនអាចកែប្រែបាន។ តារាងខាងក្រោមបង្ហាញពីចំណូលភាគលាភ ត្រូវបានទទួលស្គាល់សម្រាប់ការវិនិយោគនេះ ក្នុងអំឡុងការិយបរិច្ឆេទ។

ចំណូលភាគលាភ (កំណត់សម្គាល់លេខ ២៣)

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ការវិនិយោគនៅក្រេឌីត ប្យូរ៉ូ ហូលឌីង (ខេមបូឌា)	**១២៣.៣៩២**	**៤៩៤.៩២៥**	**១២០.៤៧៨**	**៤៩០.៨៦៦**

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៨. ទ្រព្យសកម្មផ្សេងៗ

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ប្រាក់បង់មុន	៧.៣៤៧.០១៨	២៩.៤៨៣.៥៨៣	៩.៣១៩.៤៥៨	៣៧.៥១០.៨១៨
ឥណទានពន្ធលើប្រាក់ចំណូល (កំណត់សម្គាល់លេខ ១៩)	៦.៤២៧.៥៦៧	២៥.៧៩៣.៨២៦	៥.០៩៣.១២៥	២០.៤៩៩.៨២៨
បុរេប្រទាននៃអត្ថប្រយោជន៍និយោជិត	២.៧៣៧.២៨១	១០.៩៨៤.៧០៩	៣.៦៥២.៨៤៨	១៤.៧០២.៧១៣
ប្រាក់តម្កល់ដែលអាចប្រមូលមកវិញបាន	២.៥៣៨.៧២១	១០.១៨៧.៨៨៧	២.៣៥៨.៧២០	៩.៤៩៣.៨៤៨
បុរេប្រទានលើការទូទាត់ ឬប្រាក់កក់	១.៧០៩.៦៦២	៦.៨៦០.៨៧៤	១.៨០៨.៤២១	៧.២៧៨.៨៩៥
គណនីត្រូវទទួល	៣៨៥.២៤០	១.៥៤៥.៩៦៨	៥៥៨.៨៧៧	២.២៤៩.៤៨០
ផ្សេងៗ	២៣៥.០៥៤	៩៤៣.២៧១	១៩៣.៤២២	៧៧៨.៥២៣
	២១.៣៨០.៥៤៣	៨៥.៨០០.១១៨	**២២.៩៨៤.៨៧១**	**៩២.៥១៤.១០៥**

៩. ទ្រព្យសម្រាប់លក់

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ធនាគារបានចុះកិច្ចព្រមព្រៀងសេវាកម្មតែងតាំង ជាមួយក្រុមហ៊ុន ម៉ារ៉ូហាន់ អ៊ិនវេសម៊ិន (ខេមបូឌា) ក្នុងការទូទាត់បំណុលទាំងស្រុង ទៅលើ ឥណទានវិចារូបន៍ ជាមួយធនាគារ។ ទ្រព្យសម្រាប់លក់ រួមមានទ្រព្យមិនអាចចល័តបាន ដូចជាដី និងអគារ។ ទ្រព្យទាំងនេះត្រូវបានកាន់កាប់ដោយក្រុមហ៊ុនបរធនបាលដែលដើរតួនាទីក្នុងនាមធនាគារ និងទទួលបានដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

បម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
សមតុល្យនាថ្ងៃទី១ ខែមករា	-	-
បន្ថែម	១៦.៣០៨.១១៩	៦៥.៤១១.៨៦៥
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	៣២.៦១៧
សមតុល្យនាថ្ងៃទី៣១ ខែធ្នូ	**១៦.៣០៨.១១៩**	**៦៥.៤៤៤.៤៨២**

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១០. ទ្រព្យ និងបរិក្ខារ

	គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ	កុំព្យូទ័រ	ម៉ូតូ យានយន្ត	ការកែលម្អអគារជួល	ការងារកំពុងដំណើរការ	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់លេខ ២.៤)
ថ្លៃដើម							
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	២១.២៣៣.៣៩៦	៣១.៤០៧.៣៥២	៤.២៣០.០៥៨	៥.៧៧២.០៦២	៥៥.៨៧៦	៦២.៦៩៨.៧៤៤	២៥២.៣៦២.៤៤៥
ការទិញបន្ថែម	៣២៦.៥១២	១៣៩.០៧២	-	៦៩.៩៤៧	១.១២៧.៥៨៣	១.៦៦៣.១១៤	៦.៦៧០.៧៥០
ការផ្ទេរ	៤៣៥.៨៧៤	៦៣៣.៩៦០	-	១១៣.១៨២	(១.១៨៣.០១៦)	-	-
ការលក់	(៤២.៧២៥)	(៤៥.៤៦៤)	(៩៧.៤៦៥)	-	-	(១៨៥.៦៥៤)	(៧៤៤.៦៥៨)
ការលុបចោល	(១៨២.៣៤៦)	-	-	-	-	(១៨២.៣៤៦)	(៧៣១.៣៩០)
(លម្អៀងពីការបកប្រែរូបិយប័ណ្ណ)	-	-	-	-	-	-	(៧៤៩.៧៩៤)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**២១.៧៧០.៧១១**	**៣២.១៣៤.៩២០**	**៤.១៣២.៥៩៣**	**៥.៩៥៥.១៩១**	**៤៤៣**	**៦៣.៩៩៣.៨៥៨**	**២៥៦.៨០៧.៣៥៣**
រំលស់បង្គរ							
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	១៣.០៥៣.៦៤៧	២១.០០៩.៥៩៨	៤.១៧៥.៥០៥	៣.២៤៧.០៦៨	-	៤១.៤៨៥.៨១៨	១៦៦.៩៨០.៤១៨
រំលស់ (កំណត់សម្គាល់លេខ ២៦)	២.៨០០.៧០៤	៣.៥៦៩.៨៧៩	៤១.០៤០	៨៨៧.៩០០	-	៧.២៩៩.៥២៣	២៩.២៧៨.៣៨៧
ការលក់	(៤២.៧២៥)	(៤៥.៣៤៧)	(៩៧.៤៦៥)	-	-	(១៨៥.៥៣៧)	(៧៤៤.១៨៩)
ការលុបចោល	(១២១.៩១៧)	-	-	-	-	(១២១.៩១៧)	(៤៨៩.០០៩)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	-	-	-	(៤៨៣.៨៤៦)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**១៥.៦៨៩.៧០៩**	**២៤.៥៣៤.១៣០**	**៤.១១៩.០៨០**	**៤.១៣៤.៩៦៨**	-	**៤៨.៤៧៧.៨៨៧**	**១៩៤.៥៤១.៧៦១**
សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**៦.០៨១.០០២**	**៧.៦០០.៧៩០**	**១៣.៥១៣**	**១.៨២០.២២៣**	**៤៤៣**	**១៥.៥១៥.៩៧១**	**៦២.២៦៥.៥៩២**

១០. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

	គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ	កុំព្យូទ័រ	ម៉ូតូ យានយន្ត	ការកែលម្អអគារជួល	ការងារកំពុងដំណើរការ	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់លេខ ២.៤)
ថ្លៃដើម							
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១៩.៤១២.៥៤៨	២៩.០១៧.២៥៨	៤.៣៦៦.៦២៣	៤.៧៨៦.១៧៧	២.៩១៤.៩០០	៦០.៤៩៧.៥០៦	២៤៧.១៣២.៣១២
ការទិញបន្ថែម	៩៩៩.៣០៣	១.៤៧៩.០៨៤	-	៣៧៩.៤១៨	៥៥.៨៧៦	២.៩១៣.៦៨១	១១.៨៦១.៥៩៥
ការផ្ទេរ	៩៨២.៣២៣	១.១៥២.៦១៤	-	៦៧១.៦៦៥	(២.៨០៦.៦០២)	-	-
ការចាត់ថ្នាក់ឡើងវិញនៃកម្មវិធីកុំព្យូទ័រ (កំណត់សម្គាល់លេខ ១១)	-	-	-	-	(១០៥.៦៨១)	(១០៥.៦៨១)	(៤៣០.២២៧)
ការលក់	(១៨៦.២៤៥)	(២១៣.៧៨៨)	(១៣៦.៥៦៥)	(៦៥.១៩៨)	-	(៥៦១.៧៩៦)	(២.២៨៧.០៧២)
ការលុបចោល	(១៤.៥៣៣)	(២៧.៨១៦)	-	-	(២.៦១៧)	(៤៤.៩៦៦)	(១៨៣.០៥៧)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	-	-	-	(៣.៧៣១.១០៦)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**២១.២៣៣.៣៩៦**	**៣១.៤០៧.៣៥២**	**៤.២៣០.០៥៨**	**៥.៧៧២.០៦២**	**៥៥.៨៧៦**	**៦២.៦៩៨.៧៤៤**	**២៥២.៣៦២.៤៤៥**
រំលស់បង្គរ							
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១០.២៥៨.៥៣៥	១៧.៦០១.៨០៩	៤.១៦០.៥៦៦	២.៤៧៨.៧២១	-	៣៤.៤៩៩.៦៣១	១៤០.៩៣០.៩៩៣
រំលស់ (កំណត់សម្គាល់លេខ ២៦)	២.៩៥៤.២៧៩	៣.៦៤៨.៤០២	១៥១.៥០៤	៨៣៣.៥៤៥	-	៧.៥៨៧.៧៣០	៣០.៨៨៩.៦៤៩
ការលក់	(១៨៤.៦៣៤)	(២១២.៧៩៧)	(១៣៦.៥៦៥)	(៦៥.១៩៨)	-	(៥៥៩.១៩៤)	(២.២៧៦.៤៧៩)
ការលុបចោល	(១៤.៥៣៣)	(២៧.៨១៦)	-	-	-	(៤២.៣៤៩)	(១៧២.៤០៣)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	-	-	-	(២.៣៩១.៣៤២)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**១៣.០៥៣.៦៤៧**	**២១.០០៩.៥៩៨**	**៤.១៧៥.៥០៥**	**៣.២៤៧.០៦៨**	-	**៤១.៤៨៥.៨១៨**	**១៦៦.៩៨០.៤១៨**
សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**៨.១៧៩.៧៤៩**	**១០.៣៩៧.៧៥៤**	**៥៤.៥៥៣**	**២.៥២៤.៩៩៤**	**៥៥.៨៧៦**	**២១.២១២.៩២៦**	**៨៥.៣៨២.០២៧**

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ទ្រព្យ និងបរិក្ខារដែលបានរំលស់ទាំងស្រុងជាមួយនឹងថ្លៃដើមប្រវត្តិសាស្ត្រសរុបចំនួន ២៧.០៤៣.៥១៥ ដុល្លារអាមេរិក ឬ ១០៨.៥២៥.៦២៦ ពាន់រៀល (ឆ្នាំ២០២៤៖ ២០.១២៨.៦៣៨ ដុល្លារអាមេរិក ឬ ៨១.០១៧.៧៦៨ ពាន់រៀល) នៅតែស្ថិតក្នុងការប្រើប្រាស់យ៉ាងសកម្មនៅឡើយ។

ក្នុងអំឡុងការិយបរិច្ឆេទ ធនាគារបានលក់នូវទ្រព្យ និងបរិក្ខារដែលមានតម្លៃយោងសរុបចំនួន ១១៧ ដុល្លារអាមេរិក ឬ ៤៧០ ពាន់រៀល ហើយត្រូវបានទទួលស្គាល់ប្រាក់ចំណេញចំនួន ២១.៣៤៧ ដុល្លារអាមេរិក ឬ ៨៥.៦២៣ ពាន់រៀល នៅក្នុងរបាយការណ៍ចំណេញ ឬខាត (ឆ្នាំ២០២៤៖ មានតម្លៃយោងសរុបចំនួន ២.៦០២ ដុល្លារអាមេរិក ឬ ១០.៥៩៣ ពាន់រៀល និង ប្រាក់ចំណេញចំនួន ២១.១៣៨ ដុល្លារអាមេរិក ឬ ៨៦.០៥៣ ពាន់រៀល)។ បន្ថែមពីនេះទៀត ធនាគារបានលុបចោល ទ្រព្យ និងបរិក្ខារ ដែលមានតម្លៃយោងសរុបចំនួន ៦០.៤២៩ ដុល្លារអាមេរិក ឬ ២៤២.៣៨១ ពាន់រៀល និងបានទទួលស្គាល់តម្លៃដូចគ្នានៃការខាតបង់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត (ឆ្នាំ២០២៤៖ ២.៦១៧ ដុល្លារអាមេរិក ឬ ១០.៦៥៤ ពាន់រៀល)។ ចំណេញ ឬខាតលើការលក់ និងលុបចោលនូវទ្រព្យ និងបរិក្ខារត្រូវបានបង្ហាញក្នុងចំណាយទូទៅ និងចំណាយរដ្ឋបាល ជា "ចំណាយផ្សេងៗ" (សូមមើលកំណត់សម្គាល់លេខ ២៦)។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១១. សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម

ធនាគារបានជួលទីតាំងការិយាល័យ សម្រាប់ជាស្នាក់ការកណ្តាល និងសាខា ព្រមទាំងទីតាំង ATM របស់ធនាគារ។ ព័ត៌មានពីភតិសន្យា ដែលធនាគារជាភតិក: ត្រូវបានបង្ហាញដូចខាងក្រោម៖

	ការិយាល័យ	ទីតាំង ATM	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ថ្លៃដើម				
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	៦២.៣៨១.៣២៧	១.១៩៤.៥១១	៦៣.៥៣៥.៨៣៨	២៥៥.៧៣១.៧៤៨
ទិញបន្ថែម	៤.០៥១.៦៥៩	៣០.៤៤១	៤.០៨២.១០០	១៦.៣៧៣.៣០៣
ហួសកាលកំណត់	(៤.៥៨៥.៥៧៣)	(៩៦០.១២០)	(៥.៥៤៥.៦៩៣)	(២២.២៤៣.៧៧៥)
ការវាស់វែងឡើងវិញ	(១.២២០.៩៣៩)	-	(១.២២០.៩៣៩)	(៤.៨៩៧.១៨៦)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	(៧៦៧.៧៩៩)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**៦០.៥៨៦.៤៧៤**	**២៦៤.៨៣២**	**៦០.៨៥១.៣០៦**	**២៤៤.១៩៦.២៩១**
រំលស់បង្គរ				
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	៣០.០៨៧.៥៣៧	៦៦៣.៦៥៦	៣០.៧៥១.១៩៣	១២៣.៧៧៣.៥៥២
រំលស់ (កំណត់សម្គាល់លេខ ២៦)	៦.៩៩៣.១៣៥	៤២១.០១៩	៧.៤១៤.១៥៤	២៩.៧៣៨.១៧២
ហួសកាលកំណត់	(៤.៥៨៥.៥៧៣)	(៨៨៣.៨៨៤)	(៥.៤៦៩.៤៥៧)	(២១.៩៣៧.៩៩២)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ		-	-	(៣៦៥.១២៥)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**៣២.៤៩៥.០៩៩**	**២០០.៧៩១**	**៣២.៦៩៥.៨៩០**	**១៣១.២០៨.៦០៧**
តម្លៃយោងសុទ្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**២៨.០៩១.៣៧៥**	**៦៤.០៤១**	២៨.១៥៥.៤១៦	១១២.៩៨៧.៦៨៤

	ការិយាល័យ	ទីតាំង ATM	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ថ្លៃដើម				
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	៦៣.១៤៩.៥៣៩	២.០៨២.៤៧១	៦៥.២៣២.០១០	២៦៦.៤៧២.៧៦១
ទិញបន្ថែម	១.៧៧៣.០៩៣	១៥៧.៧៧៣	១.៩៣០.៨៦៦	៧.៨៦០.៥៥៥
ហួសកាលកំណត់	(១.៣៦៣.៦០១)	(១.០៤៥.៧៣៣)	(២.៤០៩.៣៣៤)	(៩.៨០៨.៣៩៩)
ការវាស់វែងឡើងវិញ	(១.២១៧.៧០៤)	-	(១.២១៧.៧០៤)	(៤.៩៥៧.២៧៣)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	(៣.៨៣៥.៨៩៦)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**៦២.៣៨១.៣២៧**	**១.១៩៤.៥១១**	**៦៣.៥៣៥.៨៣៨**	**២៥៥.៧៣១.៧៤៨**
រំលស់បង្គរ				
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	២៤.៤២៧.៣៦០	៨៥៨.១៤១	២៥.២៨៥.៥០១	១០៣.២៩១.២៧២
រំលស់ (កំណត់សម្គាល់លេខ ២៦)	៧.០២៣.៧៧៨	៧២៥.៦៥៦	៧.៧៤៩.៤៣៤	៣១.៥៤៧.៩៤៥
ហួសកាលកំណត់	(១.៣៦៣.៦០១)	(៩២០.១៤១)	(២.២៨៣.៧៤២)	(៩.២៩៧.១១៣)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	-	-	(១.៧៦៨.៥៥២)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**៣០.០៨៧.៥៣៧**	**៦៦៣.៦៥៦**	**៣០.៧៥១.១៩៣**	**១២៣.៧៧៣.៥៥២**
តម្លៃយោងសុទ្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**៣២.២៥៣.៧៩០**	**៥៣០.៨៥៥**	៣២.៧៨៤.៦៤៥	១៣១.៩៥៨.១៩៦

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១២. ថ្លៃដើមកម្មវិធីកុំព្យូទ័រ

បម្រែបម្រួលថ្លៃដើមកម្មវិធីកុំព្យូទ័ររបស់ធនាគារមានដូចខាងក្រោម៖

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
ថ្លៃដើម				
នាថ្ងៃទី១ ខែមករា	១៨.២៧៧.៨២៦	៧៣.៥៦៨.២៥០	១៦.៤៨៦.៦៩៩	៦៧.៣៤៨.១៦៥
ទិញបន្ថែម	៥៧៨.៦៦៣	២.៣២១.០១៧	១.៦៩២.០៤៦	៦.៨៨៨.៣១៩
ការចាត់ថ្នាក់ពី/(ទៅ) ទ្រព្យ និងបរិក្ខារ (កំណត់សម្គាល់លេខ ៩)	-	-	១០៥.៦៨១	៤៣០.២២៧
ការលុបចោល	(៤.២៩២)	(១៧.២១៥)	(៦.៦០០)	(២៦.៨៦៩)
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	(២១៨.១៨៥)	-	(១.០៧១.៥៩២)
នាថ្ងៃទី៣១ ខែធ្នូ	**១៨.៨៥២.១៩៧**	**៧៥.៦៥៣.៨៦៧**	**១៨.២៧៧.៨២៦**	**៧៣.៥៦៨.២៥០**
រំលស់បង្គរ				
នាថ្ងៃទី១ ខែមករា	៧.៦៤៣.៧០២	៣០.៧៦៥.៩០១	៦.៤៥៥.៧៣៦	២៦.៣៧១.៦៨១
រំលស់ (កំណត់សម្គាល់លេខ ២៦)	១.៤៣៦.២១៩	៥.៧៦០.៦៧៤	១.១៨៧.៩៦៦	៤.៨៣៦.២១០
លម្អៀងពីការបកប្រែរូបិយប័ណ្ណ	-	(៨៨.៨៥២)	-	(៤៤១.៩៩០)
នាថ្ងៃទី៣១ ខែធ្នូ	**៩.០៧៩.៩២១**	**៣៦.៤៣៧.៧២៣**	**៧.៦៤៣.៧០២**	**៣០.៧៦៥.៩០១**
សមតុល្យយោងសុទ្ធនាថ្ងៃទី៣១ ខែធ្នូ	**៩.៧៧២.២៧៦**	**៣៩.២១៦.១៤៤**	**១០.៦៣៤.១២៤**	**៤២.៨០២.៣៤៩**

១៣. មូលនិធិពាណិជ្ជកម្ម

មូលនិធិពាណិជ្ជកម្ម ទាក់ទងទៅនឹងថ្លៃដើមដែលមានលើសពីតម្លៃសមស្របនៃទ្រព្យសកម្មសុទ្ធដែលបានមកពីការរួមបញ្ចូលគ្នា ស្របច្បាប់រវាងធនាគារ MJB និងស្ថាបនា លីមីតជីត នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ និងពីការទិញភាគហ៊ុនដំបូងរបស់ MJB លើភាគហ៊ុនរបស់ស្ថាបនា លីមីតជីត នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

ពុំមានការខាតបង់អ៊ីមភែរមិន ត្រូវបានទទួលស្គាល់ទៅលើមូលនិធិពាណិជ្ជកម្ម ក្នុងអំឡុងការិយបរិច្ឆេទនេះទេ (ឆ្នាំ២០២៤៖ មិនមាន)។

១៤. ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

ប្រាក់បញ្ញើពីអតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗត្រូវបានវិភាគដូចខាងក្រោម៖

(ក) តាមប្រភេទអតិថិជន

	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)	ដុល្លារអាមេរិក	ពាន់រៀល (កំណត់សម្គាល់ លេខ ២.៤)
គណនីចរន្ត៖				
បុគ្គល	៤២.៩៧៤.៨៣៦	១៧២.៤៥៨.០១៧	៣៧.៧៣៩.១៥៩	១៥១.៩០០.១១៥
ក្រុមហ៊ុន	១៧៣.៦៨១.៣១៥	៦៩៦.៩៨៣.១១៧	៥៨.៧៩៦.៦៦៣	២៣៦.៦៥៦.៥៦៩
រដ្ឋាភិបាល	៩.៧២៣.០៤៩	៣៩.០១៨.៥៩៦	២៨.៧២៨.៤៤៨	១១៥.៦៣២.០០៣
គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១១០.៩៦៥.២១០	៤៤៥.៣០៣.៣៨៨	១៤១.៧៧៥.៩៤៩	៥៧០.៦៤៨.១៩៥
គណនីបញ្ញើសន្សំ៖				
បុគ្គល	៣១៤.៧៦៥.៤៣១	១.២៦៣.១៥៣.៦៧៥	២០២.៨២៦.៧២១	៨១៦.៣៧៧.៥៥២
ក្រុមហ៊ុន	៣៣.១៧០.៩១៥	១៣៣.១១៤.៨៨២	៣៤.៥៦៦.៦២៧	១៣៩.១៣០.៦៧៤
គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១៣.៤១៤.៥៨៧	៥៣.៨៣២.៧៣៨	១៤.១០៥.០៦៦	៥៦.៧៧២.៨៩១
